ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្ដីពី
# ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់
# ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤



**សហការរៀបចំដោយ**

**ក្រសួងផែនការ និងសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា**

**បោះពុម្ពលើកទី១ ឆ្នាំ២០២៤**

**ឧបត្ថម្ភបច្ចេកទេសដោយ**

**ឧបត្ថម្ភថវិកាដោយ**

# របាយការណ៍ស្តីពី
# ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់
# ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤

# មាតិកា


មាតិកា ........ i

បញ្ជីតារាង ........ vi

បញ្ជីក្រាភិក ........ ix

សារលិខិតសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ........ xii

បុព្វកថា ........ xv

សេចក្តីសង្ខេប ........ xvii

ផែនទី ........ xxiv

១. សេចក្តីផ្តើម ........ ១

១.១. សាវតា ........ ១

១.២. គោលបំណង ........ ៦

១.៣. ដែនកំណត់និងការប្រឈម ........ ៧

១.៤. វិធីសាស្ត្រ ........ ៨

១.៥. រចនាសម្ព័ន្ធនៃរបាយការណ៍ ........ ៩

២. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច ........ ១១

២.១. ប្រជាជននិងអំបូរជនជាតិដើមភាគតិច ........ ១២

២.១.១. ចំនួនប្រជាជនជនជាតិដើមភាគតិចសរុប និងអត្រាកំណើន ........ ១២

២.១.២. អំបូរនិងប្រជាជនតាមអំបូរនីមួយៗ និងបម្រែបម្រួល ២០០៨-២០១៩ ........ ១៣

២.១.៣. ជនជាតិដើមភាគតិចនិងទីកន្លែងរស់នៅ ........ ១៦

២.១.៤. រាជធានីខេត្តចំនួន៣ ដែលអំបូរជនជាតិដើមភាគតិចនីមួយៗរស់នៅច្រើនជាងគេ... ២០

២.១.៥. ចំនួនភូមិដែលមានជនជាតិដើមភាគតិចរស់នៅ ........ ២៥

២.១.៦. ជនជាតិដើមភាគតិចក្នុងខេត្តទាំង១៥នៃគោលនយោបាយជាតិ.......................... ២៦
២.២. រចនាសម្ព័ន្ធអាយុភេទនៃប្រជាជនជនជាតិដើមភាគតិច............................................ ២៩
២.២.១. ភាគរយស្ត្រីនិងផលធៀបភេទ ................................................................... ២៩
២.២.២. របាយអាយុប្រជាជន .............................................................................៣២
២.២.៣. ពីរ៉ាមីដប្រជាជន.................................................................................. ៣៦
២.៣. គ្រួសារនិងអាពាហ៍ពិពាហ៍ .......................................................................... ៣៩
២.៣.១. ចំនួនគ្រួសារនិងភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារ...................................... ៣៩
២.៣.២. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ........................................ ៤២
២.៣.៣. អាពាហ៍ពិពាហ៍កាត់ជនជាតិ.....................................................................៤៤
២.៣.៤. អាយុរៀបការដំបូង ..............................................................................៤៥
២.៣.៦. អាពាហ៍ពិពាហ៍វ័យក្មេង ......................................................................... ៤៧
២.៤. លទ្ធភាពមានកូន ......................................................................................៤៩
២.៤.១. អត្រាកំណើតដុល ................................................................................៤៩
២.៤.២. ចំនួនកូនដែលបានបង្កើត.........................................................................៥០
២.៤.៣. អត្រាលទ្ធភាពមានកូនសរុប ....................................................................៥១
២.៤.៤. ការសម្រាលដោយមានវត្តមានបុគ្គលិកសុខាភិបាល ......................................... ៥៣
២.៤.៥. ការចុះបញ្ជីកំណើតរបស់ទារក ................................................................... ៥៣
២.៥. មរណភាព.................................................................................................៥៥
២.៥.១. មរណភាពកុមារ .....................................................................................៥៥
៥.២.២. មរណភាពនៃប្រជាជនជនជាតិដើមភាគតិចតាមក្រុមអាយុជាក់លាក់................... ៥៧
៥.២.៣. មូលហេតុនៃការស្លាប់ ............................................................................ ៥៧
២.៦. ទេសន្តរប្រវេសន៍.........................................................................................៥៩

២.៦.១. ចំនួននិងភាគរយជនទេសន្តរប្រវេសន៍ ..... ៥៩
២.៦.២. លំហូរទេសន្តរប្រវេសន៍ ..... ៦១
២.៦.៣. មូលហេតុទេសន្តរប្រវេសន៍ ..... ៦២
២.៦.៤. របាយអាយុនិងកម្រិតវប្បធម៌ជនទេសន្តរប្រវេសន៍១០ឆ្នាំចុងក្រោយ ..... ៦៣
២.៧. ប្រជាជនវ័យចាស់ ..... ៦៦
២.៧.១. ចំនួននិងភាគរយប្រជាជនវ័យចាស់ ..... ៦៦
២.៧.២. ប្រជាជនវ័យចាស់តាមអំបូរជនជាតិដើមភាគតិច ..... ៦៧
២.៧.៣. ស្ថានភាពអាពាហ៍ពិពាហ៍នៃប្រជាជនវ័យចាស់ ..... ៦៨
២.៧.៤. ជនជាតិដើមភាគតិចវ័យចាស់តាមរាជធានីខេត្ត ..... ៦៩
៣. ស្ថានភាពសង្គម-សេដ្ឋកិច្ចនៃជនជាតិដើមភាគតិច ..... ៧១
៣.១. ការអប់រំ ..... ៧១
៣.១.១. អត្រាអក្ខរភាព ..... ៧១
៣.១.២. អត្រាចូលរៀនសាលា ..... ៧២
៣.១.៣. ភាគរយកំពុងរៀនតាមក្រុមអាយុនិងអំបូរ ..... ៧៥
៣.១.៤. ភាគរយមិនបានចូលរៀន ..... ៧៧
៣.១.៥. អត្រាបោះបង់ការសិក្សា ..... ៧៩
៣.១.៦. ការរៀននៅកម្រិតថ្នាក់ទាបជាងអាយុ ..... ៨០
៣.១.៧. ការទទួលបានការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ..... ៨១
៣.២. ស្ថានភាពកម្លាំងពលកម្ម ការងារ និងសេដ្ឋកិច្ច ..... ៨៤
៣.២.១. ប្រជាជនសកម្មសេដ្ឋកិច្ចនិងអសកម្មសេដ្ឋកិច្ច ..... ៨៤
៣.២.២. អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមភេទនិងក្រុមអាយុ និងតាមអំបូរ ..... ៨៧
៣.២.៣. អត្រាគ្មានការងារធ្វើ តាមភេទនិងក្រុមអាយុ និងតាមអំបូរ ..... ៩០

៣.២.៤. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច ........ ៩១
៣.២.៥. ការងារតាមវិស័យសេដ្ឋកិច្ច ........ ៩៣
៣.២.៦. សហគ្រាសការងាររបស់ជនជាតិដើមភាគតិច ........ ៩៦
៣.២.៧. កម្រិតសិក្សាអប់រំរបស់ជនជាតិដើមភាគតិចដែលមានការងារធ្វើ ........ ៩៧
៣.៣. សុខភាពនិងអនាម័យ ........ ៩៩
៣.៣.១. ការមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ........ ៩៩
៣.៣.២. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ........ ១០០
៣.៣.៣. ការរកសេវាពិគ្រោះនិងព្យាបាលជំងឺ ........ ១០៣
៣.៣.៤. ការបំបៅដោះនិងការចិញ្ចឹមកូន ........ ១០៥
៣.៣.៦. ការចាក់ថ្នាំបង្ការរបស់ទារកអាយុក្រោម២ឆ្នាំ ........ ១០៦
៣.៣.៧. ពិការភាព ........ ១០៧
៣.៣.៨. អនាម័យ ........ ១០៩
៣.៤. សាសនានិងជំនឿ ........ ១១២
៤. លំនៅឋាន ដីធ្លី និងកម្មសិទ្ធសមូហភាព ........ ១១៣
៤.១. ស្ថានភាពលំនៅឋាន ........ ១១៣
៤.១.១. ស្ថានភាពកាន់កាប់លំនៅឋាន ........ ១១៣
៤.១.២. ប្រភពភ្លើងបំភ្លឺនិងប្រភពថាមពលចម្អិន ........ ១១៤
៤.១.៣. សម្ភារៈប្រើប្រាស់ក្នុងផ្ទះ ........ ១១៥
៤.២. **ការចុះបញ្ជីសហគមន៍និងកម្មសិទ្ធិដីសមូហភាព** ........ ១១៧
៤.២.១. សហគមន៍ស្វ័យអត្តសញ្ញាណ ........ ១១៨
៤.២.២. សហគមន៍នីតិបុគ្គល ........ ១១៩
៤.២.៣. ដីនិងកម្មសិទ្ធិសមូហភាព ........ ១២០

៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍......................................................................១២១
៥.១. សេចក្តីសន្និដ្ឋាន...........................................................................................១២១
៥.២. អនុសាសន៍....................................................................................................១២៣
៦. ឧបសម្ព័ន្ធ.............................................................................................................១២៥
ឧបសម្ព័ន្ធទី១. ឈ្មោះនិងចំនួនអំបូរជនជាតិដើមភាគតិច តាមប្រភពផ្សេងៗ.............................១២៥
ឧបសម្ព័ន្ធទី២. ចំនួនគ្រួសារជនជាតិដើមភាគតិចៈ ទិន្នន័យជំរឿនឆ្នាំ២០១៩..........................១២៦
ឧបសម្ព័ន្ធទី៣. ចំនួនប្រជាជនជនជាតិដើមភាគតិចៈ ទិន្នន័យជំរឿនឆ្នាំ២០១៩........................១២៩
ឧបសម្ព័ន្ធទី៤. ចំនួនគ្រួសារជនជាតិដើមភាគតិចៈ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៩.....................១៣២
ឧបសម្ព័ន្ធទី៥. ចំនួនប្រជាជនជនជាតិដើមភាគតិចៈ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៩..................១៣៥
ឧបសម្ព័ន្ធទី៦. ចំនួនប្រជាជនជនជាតិដើមភាគតិចៈ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០២១....................១៣៨
ឧបសម្ព័ន្ធទី៧. ភូមិដែលមានជនជាតិដើមភាគតិច១០នាក់ឡើងទៅ និងចំនួនប្រជាជន..........១៤៣
ឧបសម្ព័ន្ធទី៨. ភូមិដែលមានគ្រួសារជនជាតិដើមភាគតិច១០គ្រួសារឡើងទៅ.......................១៧១
ឧបសម្ព័ន្ធទី៩. សហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ...............១៨៧
ឧបសម្ព័ន្ធទី១០. សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជានីតិបុគ្គល...................១៩៤
ឧបសម្ព័ន្ធទី១១. សហគមន៍ជនជាតិដើមភាគតិចដែលមានដីសហគមន៍បានចុះបញ្ជី............២០២
ឧបសម្ព័ន្ធទី១២. ក្រុមការងារអន្តរស្ថាប័នរៀបចំរបាយការណ៍...........................................២០៨
ឧបសម្ព័ន្ធទី១៣. ប្រវត្តិសកម្មភាពការងារ.....................................................................២១៤
ឧបសម្ព័ន្ធទី១៤. បញ្ជីឈ្មោះអង្គការនិងដៃគូចូលរួមនិងគាំទ្រ............................................២១៦
ឧបសម្ព័ន្ធទី១៥. សទ្ទានុក្រម.........................................................................................២១៧

# បញ្ជីតារាង


តារាងទី ១. ចំនួនប្រជាជននិងអត្រាកំណើនប្រចាំឆ្នាំ ២០០៨-២០១៩ ................................ ១៣

តារាងទី ២. ចំនួនប្រជាជននៃអំបូរនីមួយៗនិងបម្រែបម្រួលៈ ឆ្នាំ២០០៨និង២០១៩ ................ ១៥

តារាងទី ៣. ជនជាតិដើមភាគតិចតាមរាជធានីខេត្ត ........................................................ ១៧

តារាងទី ៤. អំបូរធំៗដែលមានប្រជាជន១.០០០នាក់ឡើងក្នុងអំបូរនីមួយៗ នៅក្នុងខេត្តទាំង៦ ... ១៨

តារាងទី ៥. ឈ្មោះអំបូរដែលមានប្រជាជន១០០-៩៩៩នាក់ក្នុងអំបូរនីមួយៗ នៅក្នុងរាជធានីខេត្ត១៩

តារាងទី ៦. រាជធានីខេត្តចំនួនបី ដែលជនជាតិដើមភាគតិចអំបូរនីមួយៗរស់នៅច្រើនជាងគេ ..... ២៣

តារាងទី ៧. ចំនួនភូមិនៃរាជធានីខេត្ត ដែលមានជនជាតិដើមភាគតិចចាប់ពី៥០នាក់ឡើងទៅ .... ២៥

តារាងទី ៨. ចំនួនជនជាតិដើមភាគតិចដែលកើតនៅក្នុងខេត្តទាំង១៥ តាមខេត្តនិងតាមអំបូរ ..... ២៨

តារាងទី ៩. ចំនួនប្រជាជនតាមភេទនិងទីកន្លែងរស់នៅ ឆ្នាំ២០០៨ និងឆ្នាំ២០១៩ .................. ៣០

តារាងទី ១០. របាយភាគរយនៃក្រុមអាយុ៥ៗឆ្នាំ ............................................................ ៣៣

តារាងទី ១១. ផលធៀបវ័យក្នុងបន្ទុក ........................................................................ ៣៨

តារាងទី ១២. ចំនួនគ្រួសារនិងភាគរយស្ត្រីជាមេគ្រួសារៈ សរុបកម្ពុជានិងជនជាតិដើមភាគតិច ...... ៣៩

តារាងទី ១៣. ស្ថានភាពអាពាហ៍ពិពាហ៍ជនជាតិដើមភាគតិច ................................................ ៤២

តារាងទី ១៤. អាយុពេលរៀបការដំបូង ........................................................................ ៤៦

តារាងទី ១៥. របាយភាគរយនៃអាយុរៀបការដំបូង តាមភេទនិងទីកន្លែងរស់នៅ ឆ្នាំ២០១៩ៈ ជនជាតិដើមភាគតិចនិងកម្ពុជា ........................................................................ ៤៨

តារាងទី ១៦. អត្រាកំណើតនៃជនជាតិដើមភាគតិច ឆ្នាំ២០១៩ .............................................. ៥០

តារាងទី ១៧. ចំនួននិងភាគរយជនទេសន្តរប្រវេសន៍ តាមភេទនិងទីកន្លែងរស់នៅៈ ឆ្នាំ២០១៩...... ៦០

តារាងទី ១៨. មូលហេតុនៃទេសន្តរប្រវេសន៍ .................................................................. ៦៣

តារាងទី ១៩. ចំនួននិងភាគរយប្រជាជនវ័យចាស់ ឆ្នាំ២០០៨និង២០១៩ ................................ ៦៦

តារាងទី ២០. ប្រជាជនវ័យចាស់តាមអំបូរជនជាតិដើមភាគតិច ............................................. ៦៧
តារាងទី ២១. ប្រជាជនវ័យចាស់តាមរាជធានីខេត្ត .................................................................៦៩
តារាងទី ២២. ភាគរយមិនបានទៅរៀន កំពុងរៀន និងឈប់រៀន ............................................៧៣
តារាងទី ២៣. អត្រាចូលរៀនរបស់កុមារនិងយុវវ័យជនជាតិដើមភាគតិចតាមអាយុកម្រិតសិក្សា...... ៧៤
តារាងទី ២៤. កម្រិតសិក្សាខ្ពស់បំផុតដែលបានរៀនចប់ តាមភេទនិងទីកន្លែងរស់នៅ៖ ឆ្នាំ២០១៩ . ៨៣
តារាងទី ២៥. ប្រជាជនសកម្មនិងអសកម្មសេដ្ឋកិច្ច អាយុ៥ឆ្នាំឡើងនិង១៥ឆ្នាំឡើង៖ ឆ្នាំ២០១៩ ...៨៦
តារាងទី ២៦. ការងារតាមវិស័យសេដ្ឋកិច្ចនៃអំបូរនីមួយ ........................................................៩៥
តារាងទី ២៧. សហគ្រាសនៃការងារជនជាតិដើមភាគតិចដែលមានការងារធ្វើ ឆ្នាំ២០១៣និង២០១៩ .........................................................................................................................................៩៦
តារាងទី ២៨. កម្រិតអប់រំខ្ពស់បំផុតរបស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ដែលមានការងារធ្វើ ........................................................................................................................................ ៩៧
តារាងទី ២៩. ជំងឺស្ត្រី .........................................................................................................១០៣
តារាងទី ៣០. ការបំបៅដោះកូនក្រោយកើតរបស់មាតាជនជាតិដើមភាគតិច ........................... ១០៦
តារាងទី ៣១. ការចាក់វ៉ាក់សាំងបង្ការរបស់ទារកអាយុក្រោម២ឆ្នាំ.......................................... ១០៦
តារាងទី ៣២. ចំនួននិងភាគរយអ្នកមានពិការភាពអាយុ៥ឆ្នាំឡើង ......................................... ១០៨
តារាងទី ៣៣. ភាគរយអ្នកមានពិការភាពតាមភេទនិងក្រុមអាយុ............................................ ១០៨
តារាងទី ៣៤. ការប្រើប្រាស់បង្គន់អនាម័យនៃគ្រួសារជនជាតិដើមភាគតិច ............................... ១០៩
តារាងទី ៣៥. ប្រភពទឹកស្អាតសម្រាប់ទទួលទាន .............................................................. ១១១
តារាងទី ៣៦. សាសនា .......................................................................................................១១២
តារាងទី ៣៧. ស្ថានភាពសិទ្ធិកាន់កាប់លំនៅឋានរបស់ជនជាតិដើមភាគតិច............................១១៣
តារាងទី ៣៨. ប្រភពភ្លើងបំភ្លឺ ............................................................................................. ១១៤
តារាងទី ៣៩. ប្រភពឋាមពលចម្អិន ..................................................................................... ១១៥

តារាងទី ៤០.  សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ .......................................................................... ១១៦
តារាងទី ៤១.  ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីនីតិបុគ្គល ........................ ១១៩
តារាងទី ៤២.  ដីសហគមន៍ជនជាតិដើមភាគតិចបានចុះបញ្ជីនិងចែកប័ណ្ណ .............................. ១២០

# បញ្ជីក្រាភិក

ក្រាភិកទី ១. ចំនួននិងភាគរយជនជាតិដើមភាគដែលមានប្រភពកំណើតក្នុងខេត្តកំពុងរស់នៅ..... ២៦
ក្រាភិកទី ២. ភាគរយស្ត្រីនិងផលធៀបភេទតាមអំបូរជនជាតិដើមភាគតិច ឆ្នាំ២០១៩................ ៣០
ក្រាភិកទី ៣. ផលធៀបភេទតាមក្រុមអាយុ៥ៗឆ្នាំ.............................................................. ៣១
ក្រាភិកទី ៤. របាយភាគរយនៃវ័យ ឆ្នាំ២០០៨និងឆ្នាំ២០១៩ ............................................. ៣៤
ក្រាភិកទី ៥. របាយភាគរយនៃវ័យរបស់អំបូរជនជាតិដើមភាគតិចធំៗ .................................. ៣៥
ក្រាភិកទី ៦. ពីរ៉ាមីដប្រជាជន ..........................................................................................៣៧
ក្រាភិកទី ៧. ភាគរយគ្រួសារជនជាតិដើមភាគតិចដែលស្ត្រីជាមេគ្រួសារ តាមអំបូរធំៗ..................៤០
ក្រាភិកទី ៨. ភាគរយគ្រួសារជនជាតិដើមភាគតិចដែលស្ត្រីជាមេគ្រួសារ តាមរាជធានីខេត្ត............៤១
ក្រាភិកទី ៩. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង .................. ៤៣
ក្រាភិកទី ១០. អាពាហ៍ពិពាហ៍កាត់ជនជាតិ ...........................................................................៤៤
ក្រាភិកទី ១១. អាយុពេលរៀបការដំបូង...................................................................................៤៦
ក្រាភិកទី ១២. ចំនួនកូនក្នុងចំណោមស្ត្រីរៀបការហើយ១០០នាក់ តាមក្រុមអាយុស្ត្រី ....................៥០
ក្រាភិកទី ១៣. ផែនទីអត្រាលទ្ធភាពមានកូនឆ្នាំ២០២១-២០២ ............................................ ៥២
ក្រាភិកទី ១៤. ចំនួនកូនជាមធ្យមដែលស្ត្រីបានបង្កើត ឆ្នាំ២០២១-២០២២ .............................. ៥២
ក្រាភិកទី ១៥. វត្តមានបុគ្គលិកសុខាភិបាលពេលសម្រាល .......................................................៥៤
ក្រាភិកទី ១៦. ភាគរយបានចុះបញ្ជីកំណើត ..........................................................................៥៤
ក្រាភិកទី ១៧. អត្រាមរណភាពកុមារៈ ជនជាតិដើមភាគតិច ......................................................៥៦
ក្រាភិកទី ១៨. អត្រាមរណភាពដុលតាមក្រុមអាយុជាក់លាក់ ...................................................... ៥៧
ក្រាភិកទី ១៩. មូលហេតុនៃការស្លាប់របស់កុមារជនជាតិដើមភាគតិចអាយុក្រោម៥ឆ្នាំ ..................៥៨
ក្រាភិកទី ២០. មូលហេតុនៃការស្លាប់របស់ជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង............................៥៩

ក្រាភិកទី ២១. ភាគរយទេសន្តរប្រវេសន៍ក្នុងអំឡុង៥ឆ្នាំចុងក្រោយ...............................................៦១
ក្រាភិកទី ២២. លំហូរទេសន្តរប្រវេសន៍ តាមភេទនិងរយៈពេលតាំងលំនៅ.................................. ៦២
ក្រាភិកទី ២៣. របាយអាយុនៃជនទេសន្តរប្រវេសន៍ក្នុងអំឡុង១០ឆ្នាំចុងក្រោយ.............................៦៤
ក្រាភិកទី ២៤. កម្រិតសិក្សាអប់រំនៃជនទេសន្តរប្រវេសន៍ក្នុងកំឡុង១០ឆ្នាំចុងក្រោយ .....................៦៥
ក្រាភិកទី ២៥. ស្ថានភាពអាពាហ៍ពិពាហ៍នៃប្រជាជនវ័យចាស់ជនជាតិដើមភាគតិច .......................៦៨
ក្រាភិកទី ២៦. អក្ខរភាពភាសាខ្មែររបស់ជនជាតិដើមភាគតិច ឆ្នាំ២០១៣និងឆ្នាំ២០១៩ ...............៧២
ក្រាភិកទី ២៧. ភាគរយកំពុងរៀនតាមក្រុមអាយុនិងអំបូរ៖ ឆ្នាំ២០១៩ ....................................... ៧៦
ក្រាភិកទី ២៨. ភាគរយមិនបានចូលរៀនតាមក្រុមអាយុនិងអំបូរ ............................................... ៧៨
ក្រាភិកទី ២៩. អត្រាបោះបង់ការសិក្សាតាមអាយុនិងភេទ៖ ឆ្នាំ២០១៩..................................... ៧៩
ក្រាភិកទី ៣០. របាយភាគរយនៃកម្រិតថ្នាក់កំពុងរៀន តាមអាយុនាពេលអង្កេត ............................៨១
ក្រាភិកទី ៣១. ភាគរយកម្លាំងពលកម្ម តាមភេទនិងក្រុមអាយុ៖ ឆ្នាំ២០១៩.................................៨៨
ក្រាភិកទី ៣២. អត្រាចូលរួមក្នុងកម្លាំងពលកម្មនៃប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ....៨៩
ក្រាភិកទី ៣៣. ភាគរយអ្នកគ្មានការងារធ្វើ តាមភេទនិងក្រុមអាយុ...............................................៩០
ក្រាភិកទី ៣៤. ភាគរយអ្នកគ្មានការងារធ្វើតាមអំបូរជនជាតិដើមភាគតិច .....................................៩១
ក្រាភិកទី ៣៥. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិចនិងកម្ពុជាអាយុ១៥ឆ្នាំឡើង តាមភេទ.... ៩២
ក្រាភិកទី ៣៦. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច អាយុ១៥ឆ្នាំឡើង តាមភេទនិងក្រុមអាយុ ៩៣
ក្រាភិកទី ៣៧. ការងារតាមវិស័យសេដ្ឋកិច្ច គិតតាមភេទ ..........................................................៩៤
ក្រាភិកទី ៣៨. ការងារតាមវិស័យសេដ្ឋកិច្ច គិតតាមភេទនិងក្រុមអាយុ .........................................៩៥
ក្រាភិកទី ៣៩. ភាគរយអ្នកមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមភេទនិងក្រុមអាយុ ................ ១០០
ក្រាភិកទី ៤០. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ......................................................... ១០១
ក្រាភិកទី ៤១. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមក្រុមអាយុ .....................................១០២

ក្រាភិកទី ៤២. ភាគរយរកសេវាពិគ្រោះនិងព្យាបាល និងភាគរយមានជំងឺចាប់ពី១ឆ្នាំទៅ តាមក្រុមអាយុ ............ ១០៤

ក្រាភិកទី ៤៣. សេវាសុខភាពដែលបានរកមុនគេនិងក្រោយគេបង្អស់ នាពេលឈឺ៣០ថ្ងៃចុងក្រោយ ............ ១០៥

# សារលិខិតសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សារលិខិត**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី៣០**
**និងលើកទី២០ នៅកម្ពុជា**
**ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤**

*- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ !*
*- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ !*
*- បងប្អូនជនជាតិដើមភាគតិច និងបងប្អូនជនរួមជាតិ ជាទីស្រលាញ់ !*

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី៩ ខែសីហា ក្នុងការប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកដើម្បីផ្សព្វផ្សាយអំពីប្រពៃណី ទំនៀមទម្លាប់ ស្វែងយល់អំពីជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច និងដើម្បីការពារអភិរក្សនូវវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសារបស់បងប្អូន។ ក្នុងឱកាសដ៏ប្រពៃនៃទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី៣០ និងលើកទី២០ នៅកម្ពុជា ឆ្នាំ២០២៤ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា មានសេចក្តីសោមនស្សរីករាយក្រៃលែង សូមថ្លែង នូវសារលិខិតជូនបងប្អូនជនជាតិដើមភាគតិចទាំងអស់ជាទីស្រលាញ់ ក្រោមប្រធានបទ "**ការការពារសិទ្ធិរស់នៅ និងប្រាស្រ័យទាក់ទងតាមបែបប្រពៃណីជនជាតិដើមភាគតិចដោយស្ម័គ្រចិត្ត**"។

ជនជាតិដើមភាគតិច ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន៖ កួយ ទំពួន គ្រឹង ចារាយ ព្នង ព្រៅ កាវ៉ែត ស្ទៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្អូច រដែ ខិ អេង ស្ទុង ល្មិន សំរែ និងជនជាតិដើមភាគតិចមួយចំនួនផ្សេងទៀត។ បងប្អូនជនជាតិដើមភាគតិចទាំងអស់មានប្រមាណជា ១,៤% នៃចំនួនប្រជាជនសរុប និងរស់នៅក្នុងខេត្តមួយចំនួនដូចជា៖ រតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ ត្បូងឃ្មុំ ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងនៅតាមតំបន់មួយចំនួនទៀត។ បងប្អូនជនជាតិដើមភាគតិចយើងប្រកាន់យកវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសាផ្សេងៗគ្នាទៅតាមក្រុមរបស់ខ្លួន។

រាជរដ្ឋាភិបាលកម្ពុជាគោរព និងការពារសិទ្ធិជនជាតិដើមភាគតិចដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ ដោយបានធានាពីសិទ្ធិស្មើគ្នាទាំងអស់របស់ប្រជាជនកម្ពុជា

ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ និងសាសនា។ ជាមួយគ្នានេះដែរ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីនីតិវិធីនៃ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច បានបញ្ជាក់យ៉ាងច្បាស់នូវគោលបំណងការពារ និងអភិរក្ស វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសាក៏ដូចជាការលើកស្ទួយដល់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិចផងដែរ។ លើសពីនេះ ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចបានចំនួន ១៥៤ សហគមន៍ និងចូលរួមអនុម័តបទបញ្ជាផ្ទៃក្នុង ស្តីពីការប្រើប្រាស់ និងគ្រប់គ្រងដីជាសមូហភាពសហគមន៍ជនជាតិដើមភាគតិចបានចំនួន ១០១ សហគមន៍។

នេះសបញ្ជាក់យ៉ាងច្បាស់ថា រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងដល់បងប្អូនជនជាតិដើមភាគតិច ក្នុងការការពារ អភិរក្ស និងថែរក្សាតម្លៃសីលធម៌ វប្បធម៌ ប្រពៃណីដ៏ល្អផូរផង់ និងរស់រវើក ជាពិសេសបានផ្តល់ឱកាស និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។ យើងកត់សម្គាល់ឃើញថា ក្នុងរយៈពេលចុងក្រោយនេះ ការងារអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិចមានការរីកចម្រើន និងសម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈ។ ទាំងអស់នេះ កើតឡើងពីការប្តេជ្ញាចិត្ត ការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល និងមានការចូលរួមសហការ និងគាំទ្រយ៉ាងជិតស្និទ្ធពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលនេះបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការយល់ដឹងនូវសារៈសំខាន់នៃការងារអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិច។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានចូលរួមយ៉ាងសកម្មក្នុងការងារលើកកម្ពស់ការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច នាពេលកន្លងមក។ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បន្តសហការដើម្បីជំរុញការងារលើកកម្ពស់ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិចឱ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពថែមទៀត។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ បងប្អូនជនជាតិដើមភាគតិច !**

ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី៣០ និងលើកទី២០ នៅកម្ពុជានេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមផ្តល់ជាអនុសាសន៍ និងគំនិតមួយចំនួនដូចខាងក្រោម៖

ទី១. ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបន្តយកចិត្តទុកដាក់អនុវត្តន៍ការងារលើកកម្ពស់ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច ស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងរៀបចំឯកសារគតិយុត្តពាក់ព័ន្ធផ្សេងៗ ដើម្បីជំរុញឱ្យការងារអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិចកាន់តែមានប្រសិទ្ធភាព។

ទី២. ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបន្តពង្រឹងការសម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងខិតខំស្វែងរកការគាំទ្រ និងកៀរគរធនធានបន្ថែមពីដៃគូអភិវឌ្ឍនានា

អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបង្កើនវឌ្ឍនភាពបន្ថែមលើការងារអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិច ជាពិសេសការចុះបញ្ជី និងការទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច។

ទី៣. ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវយកចិត្តទុកដាក់លើការងារអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិច ដោយខិតខំរៀបចំ និងអភិវឌ្ឍន៍ភូមិជនជាតិដើមភាគតិចទៅជាភូមិគំរូ ផ្អែកលើសក្តានុពលវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងទេសចរណ៍ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។

ទី៤. ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបន្តអប់រំ និងផ្សព្វផ្សាយអំពីភាពចាំបាច់ និងសារៈសំខាន់នៃការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច ឱ្យបានទូលំទូលាយ ទៅដល់គ្រប់សហគមន៍ជនជាតិដើមភាគតិច និងសាធារណជន។

ទី៥. គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវអភិក្រម ការអភិវឌ្ឍដើរទន្ទឹមនឹងការអភិរក្សក្នុងគោលដៅកសាងសង្គមជាតិមួយដែលមានសមាហរណកម្ម សុខដុមនីយកម្ម មិនមានការរើសអើងក្នុងនាមជនជាតិខ្មែរតែមួយ។

ជាទីបញ្ចប់ នៅក្នុងឱកាសអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី៣០និងលើកទី២០ នៅកម្ពុជា ឆ្នាំ២០២៤ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរជនរួមជាតិ ជាពិសេសបងប្អូនជនជាតិដើមភាគតិចទាំងអស់ ប្រកបដោយពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃពុធ ១១ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

ហ៊ុន ម៉ាណែត

# បុព្វកថា

របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤ គឺជាបច្ចុប្បន្នភាពនៃរបាយការណ៍ឆ្នាំ២០២១ អំពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច ដែលបានសហការរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍នៃក្រសួងផែនការ និងអង្គការសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា ដោយប្រើប្រាស់ទិន្នន័យមានស្រាប់របស់វិទ្យាស្ថានជាតិស្ថិតិ និងទិន្នន័យរដ្ឋបាលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការព័ត៌មានដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ លម្អិត ច្បាស់លាស់ និងមានសង្គតិភាព សម្រាប់ការងាររៀបចំផែនការនិងសកម្មភាពការពារ អភិរក្ស និងអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជាឱ្យចំគោលដៅ ស្របតាមបរិបទកម្ពុជា និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល និងសម្រាប់ចែករំលែកទូលំទូលាយដល់អ្នកមានចំណែកពាក់ព័ន្ធ និងសាធារណជន នូវទិន្នន័យនិងព័ត៌មានបច្ចុប្បន្នភាពអំពីជនជាតិដើមភាគតិចនៅកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់ការយល់ដឹងអំពីប្រពៃណី ទំនៀមទម្លាប់ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ស្របតាមខ្លឹមសារនៃ **សារលិខិតសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក លើកទី៣០ និងលើកទី២០នៅកម្ពុជា** នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤។

របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ គឺជាសមិទ្ធផលរួមគ្នារវាងក្រសួងផែនការនិងក្រសួងស្ថាប័នពាក់ព័ន្ធ តាមរយៈ*ក្រុមការងារអន្តរស្ថាប័នផលិតទិន្នន័យសហគមន៍និងរបាយការណ៍ជនជាតិដើមភាគតិច* ដែលរួមមានក្រសួងផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា និងតំណាងដៃគូអភិវឌ្ឍជាសមាជិក និងតំណាងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា ជាអ្នកសង្កេតការណ៍។ របាយការណ៍នេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ សរុបចំនួន៩លើក រវាងក្រុមការងារនៃអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ និងតំណាងសម្ព័ន្ធជនជាតិដើមភាគតិចនៅកម្ពុជា និងរវាងក្រុមការងារអន្តរស្ថាប័ន ដោយមានការចូលរួមពីតំណាងសហគមន៍ជនជាតិដើមភាគតិចដោយផ្ទាល់។ របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤ មាន៥ជំពូក ដែលបង្ហាញពីស្ថានភាពប្រជាសាស្ត្រ និងស្ថានភាពសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅឆ្នាំ២០១៩ និងបម្រែបម្រួលនៃស្ថានភាពទាំងនេះធៀបនឹងឆ្នាំ២០០៨និងឆ្នាំ២០១៣។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងផែនការ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់ រដ្ឋលេខាធិការ ក្រសួងផែនការ ដែលបានដឹកនាំការងារសរសេររបាយការណ៍នេះ និងសូមអរគុណចំពោះ ឯកឧត្តម ជា ចាន់ទុំ អគ្គលេខាធិការ និង

ក្រុមការងាររបស់អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ នៃក្រសួងផែនការ ព្រមទាំង ក្រុមការងារអន្តរស្ថាប័នផលិតទិន្នន័យសហគមន៍និងរបាយការណ៍ជនជាតិដើមភាគតិច និង តំណាងសមាគមនិងសហគមន៍ជនជាតិដើមភាគតិច ដែលបានចូលរួមយ៉ាងសកម្មនិងបានសហការល្អប្រសើរ នៅក្នុងដំណើរការរៀបចំរបាយការណ៍ ក៏ដូចជាការចូលរួមផ្តល់ធាតុចូលបន្ថែមដើម្បីកែលម្អរបាយការណ៍នេះឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទូលំទូលាយ និងសុក្រឹត។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់ដៃគូអភិវឌ្ឍ រួមមានមូលនិធិហេនរេចបូលទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បញ្ចឹម អង្គការជំនួយរបស់វិហារដាណឺម៉ាក មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន អភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព វេទិកានៃអង្គការ មិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការទិន្នន័យអំពីការអភិវឌ្ឍ និងសមាគមជនជាតិដើមភាគតិចទាំងអស់ ដែលបានចូលរួមនិងគាំទ្រទាំងផ្នែកបច្ចេកទេសទាំងផ្នែកហិរញ្ញវត្ថុដល់ការរៀបចំរបាយការណ៍នេះ និងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា **របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤** នឹងផ្តល់នូវព័ត៌មានដ៏មានសារសំខាន់ពាក់ព័ន្ធនឹងស្ថានភាព ប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច ការរស់នៅ និងសហគមន៍នៃជនជាតិដើមភាគតិចនៅកម្ពុជា ដល់អ្នករៀបចំផែនការអភិវឌ្ឍន៍និងការតាមដានត្រួតពិនិត្យការអនុវត្តទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ វិនិយោគិន អ្នកសិក្សាស្រាវជ្រាវ សហគមន៍ជនជាតិដើមភាគតិច និងអ្នកមានចំណែកពាក់ព័ន្ធក្នុងកិច្ចការការពារ អភិរក្ស និងអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា សំដៅរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច ឱ្យកាន់តែល្អប្រសើរ ដោយមិនទុកចោលនរណាម្នាក់និងទីកន្លែងណាមួយឡើយ។ ៩ រោច

ថ្ងៃព្រហស្បតិ៍ ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ក្រសួងផែនការ**

ក្រសួងផែនការ

**ប៊ិន ត្រឈៃ**

# សេចក្តីសង្ខេប

**របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា** ត្រូវបានរៀបចំឡើងជាលើកទីមួយដោយអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍ (អ.ប.អ.) នៃក្រសួងផែនការ និងបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទិន្នន័យថ្នាក់ជាតិអំពីជនជាតិដើមភាគតិច សម្រាប់ការអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា។ តម្រូវការទិន្នន័យនេះ គឺជាបញ្ហាប្រឈមចម្បង ដែលបានអនុម័តនៅក្នុង ***សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិអំពីគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច*** កាលពីថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ដែលរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការគាំទ្រពីនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (UNDESA) និងមានការចូលរួមពីក្រសួងពាក់ព័ន្ធ អង្គការជនជាតិដើមភាគតិច និងសង្គមស៊ីវិលជាច្រើន។

**របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤** នេះ គឺជារបាយការណ៍ទី២ ដែលបានរៀបចំឡើងដោយ អ.ប.អ. ផ្អែកលើទិន្នន័យមានស្រាប់ថ្មីៗពីជំរឿននិងអង្កេតនានា ក្នុងគោលបំណងផ្តល់នូវទិន្នន័យនិងព័ត៌មានបច្ចុប្បន្នភាពគ្រប់ជ្រុងជ្រោយ សម្រាប់ការរៀបចំផែនការនិងសកម្មភាពការពារ អភិរក្ស និងអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជាឱ្យចំគោលដៅ និងសម្រាប់ចែករំលែកទូលំទូលាយដល់អ្នកមានចំណែកពាក់ព័ន្ធនិងសាធារណជន នូវព័ត៌មានបច្ចុប្បន្នភាពអំពីជនជាតិដើមភាគតិចនៅកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់ការយល់ដឹងអំពីប្រពៃណី ទំនៀមទម្លាប់ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។

យោងតាមឯកសារនានា ជនជាតិដើមភាគតិចនៅកម្ពុជា គិតជាឈ្មោះមានចំនួន២៧អំបូរ។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចកត់ត្រាជនជាតិដើមភាគតិចចំនួន២៤អំបូរ ជំរឿនកត់ត្រាចំនួន២២អំបូរ និងទិន្នន័យឃុំសង្កាត់កត់ត្រាចំនួយ១៩អំបូរ។ ក្នុងស្ថានភាពនេះ យើងចាំបាច់ត្រូវធ្វើការស្រាវជ្រាវស៊ីជម្រៅជាបន្ថែមទៀត អំពីឈ្មោះនិងចំនួនអំបូរជាក់លាក់ និងអំពីព័ត៌មានពាក់ព័ន្ធនានាអំពីជនជាតិដើមភាគតិចនៅកម្ពុជា។

ជំរឿន កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជាដោយភាសានិយាយពីកំណើត។ រីឯអង្កេតនានា គ្មានសូចនាករជាក់លាក់ដើម្បីកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចឡើយ ក្រៅពីព័ត៌មានអំពីជនជាតិភាគតិច។

យោងតាមទិន្នន័យជំរឿនឆ្នាំ២០១៩ ជនជាតិដើមភាគតិចមានចំនួន២២អំបូរ និងមានប្រជាជនសរុបចំនួន ១៧២.៩៨០នាក់ (ស្មើនឹង១,១១% នៃប្រជាជនកម្ពុជាសរុប) ដែលភាគច្រើន (៩៤% នៃជនជាតិដើមភាគតិច) រស់នៅក្នុងខេត្តខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តកំពង់ធំ។ អំបូរធំៗទាំង៦ដែលមានប្រជាជនចាប់ពីមួយម៉ឺននាក់ឡើងទៅ មានៈ ១)ជនជាតិពូនងសរុបចំនួន ៣៦.៥៨៥នាក់, ២)ជនជាតិទំពួនសរុបចំនួន ៣៦.៣៧៣នាក់, ៣) ជនជាតិចារ៉ាយសរុបចំនួន ២៦.៩២២នាក់, ៤) ជនជាតិគ្រឹងសរុបចំនួន ២១.៤៥៣នាក់, ៥) ជនជាតិកួយសរុបចំនួន ១៦.៧៦២នាក់, និង ៦) ជនជាតិព្រៅសរុបចំនួន១០.០៨៦នាក់ ដែលសរុបប្រជាជនទាំង៦អំបូរ មានចំនួនសរុប ១៤៨.១៨១នាក់ ស្មើនឹង ៨៥,៧% នៃប្រជាជនជនជាតិដើមភាគតិចទាំងអស់។

គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ បញ្ជាក់ថាជនជាតិដើមភាគតិចមានប្រភពដើមកំណើតនៅក្នុងខេត្តចំនួន១៥ក្នុងប្រទេសកម្ពុជា។ ទិន្នន័យឆ្នាំ២០១៩បង្ហាញថាជាសរុបមានជនជាតិដើមភាគតិចចំនួន១៦៧.៨០១នាក់ (ស្មើនឹង៩៧,០%នៃជនជាតិដើមភាគតិចទាំងអស់) កំពុងរស់នៅក្នុងខេត្តទាំង១៥ខាងលើ និងចំនួន១៥៨.៨៥២នាក់ (ស្មើនឹង៩៤,៧% នៃជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងខេត្តទាំង១៥) កើតនិងរស់នៅក្នុងខេត្តទាំង១៥នេះ។

## ១. ស្ថានភាពប្រជាសាស្ត្រ

ប្រជាជននៃជនជាតិដើមភាគតិចនៅបន្តជាប្រជាជនវ័យក្មេង ដែលមានអាយុមេដ្យានស្មើនឹង២១ឆ្នាំ (ធៀបនឹងអាយុមេដ្យាន២៦ឆ្នាំនៃប្រជាជនកម្ពុជាសរុប)។ ទោះយ៉ាងនេះក្ដី របាយអាយុនៃប្រជាជនជនជាតិដើមភាគតិច កំពុងប្រែប្រួលតាមនិន្នាការនៃរបាយអាយុប្រជាជនកម្ពុជា ដែលប្រជាជនវ័យក្រោម១៥ឆ្នាំបានថយចុះ និងប្រជាជនវ័យធ្វើការបានកើនឡើងគួរកត់សម្គាល់ ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៩ គឺប្រជាជនវ័យក្រោម១៥ឆ្នាំបានថយចុះពី៤១,៧% មក៣៤,៨%, ប្រជាជនវ័យ១៥-៥៩ឆ្នាំ បានកើនឡើងពី៥៣,១% មក៥៩,២%, និងប្រជាជនវ័យ៦០ឆ្នាំឡើងកើនឡើងតិចតួច ពី៥,៥% មក៦,០% ដែលការប្រែប្រួលរបាយអាយុនេះ ធ្វើឱ្យអនុបាទវ័យក្នុងបន្ទុកថយចុះ ពិសេសវ័យក្មេងក្នុងបន្ទុក។ ដោយបំបែកតាមក្រុមវ័យលម្អិត ទិន្នន័យឆ្នាំ២០១៩បង្ហាញថា វ័យទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំមានចំនួន១០,២%, វ័យកុមារនិងជំទង់ក្នុងវ័យសិក្សាអាយុ៥-១៧ឆ្នាំមានចំនួន៣១,៦%, មជ្ឈិមវ័យបឋមអាយុ១៨-៣៥ឆ្នាំមាន ចំនួន៣២,១%, មជ្ឈិមវ័យកណ្ដាលអាយុ៣៦-៥៩ឆ្នាំមានចំនួន២០,២%។ របាយអាយុទាំងនេះខុសៗគ្នាទៅតាមអំបូរជនជាតិដើមភាគតិច។

នៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចមានចំនួន៣៧.៩១៩គ្រួសារ ដែលទំហំគ្រួសារជាមធ្យមស្មើនឹង៤,៦នាក់ក្នុងមួយគ្រួសារ។ ជនជាតិដើមភាគតិចរៀបការនៅអាយុ២៤ឆ្នាំចំពោះបុរស និងនៅអាយុ២០,៦ឆ្នាំចំពោះស្ត្រី គឺឆាប់រៀបការជាងប្រជាជនកម្ពុជាប្រមាណពី២ទៅ៣ឆ្នាំ ទាំងបុរសទាំងស្ត្រី ទាំងនៅជនបទទាំងនៅទីប្រជុំជន។ ស្ត្រីជនជាតិដើមភាគតិចដែលរៀបការនៅអាយុ១៦-១៩ឆ្នាំ មានចំនួន ៤៩,៥% នៅទីប្រជុំជន និង៥៥,៩%នៅជនបទ (ដែលក្នុងចំណោមស្ត្រីកម្ពុជា តួលេខនេះមានចំនួនត្រឹម ២៩,៦%នៅទីប្រជុំជន និង៣៨,១%នៅជនបទ)។ បុរសជនជាតិដើមភាគតិចដែលរៀបការនៅអាយុ ១៦-១៩ឆ្នាំ មានចំនួន ២១,៥%នៅទីប្រជុំជន និង២៤,៧%នៅជនបទ (ដែលក្នុងចំណោមបុរសកម្ពុជា តួលេខនេះមានចំនួនត្រឹម៩,៥%នៅទីប្រជុំជន និង១៤,៥%នៅជនបទ)។

អាពាហ៍ពិពាហ៍ឆ្លងជនជាតិជាព្រឹត្តិការណ៍ទូទៅក្នុងសង្គម ដែលក្នុងចំណោមអាពាហ៍ពិពាហ៍ជនជាតិដើមភាគតិច មាន ៨៣,៥% ជាអាពាហ៍ពិពាហ៍ដែលស្វាមីនិងភរិយាជាជនជាតិដើមភាគតិចដូចគ្នា, ១០,២% ជាអាពាហ៍ពិពាហ៍រវាងស្វាមីជាជនជាតិដើមភាគតិចនិងភរិយាជាជនជាតិផ្សេង, និង៦,៣% ជាអាពាហ៍ពិពាហ៍រវាងស្វាមីជាជនជាតិផ្សេងនិងភរិយាជាជនជាតិដើមភាគតិច។

ទោះជាលទ្ធភាពមានកូនថយចុះក្តី ស្ត្រីជនជាតិដើមភាគតិចមៅមានចំនួនកូនច្រើនជាងស្ត្រីកម្ពុជា ដូចជា៖ អត្រាកំណើតដុលស្មើនឹង១៨នាក់ អត្រាលទ្ធភាពមានកូនទូទៅស្មើនឹង៦៦នាក់ និងផលធៀបកុមារ-ស្ត្រីស្មើនឹង៣៨០នាក់ ដែលតួលេខនេះខ្ពស់នៅជនបទជាងនៅទីប្រជុំជន។ ទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាព ក៏បង្ហាញថា ស្ត្រីនៅក្នុងខេត្តដែលមានជនជាតិភាគតិចច្រើន ឆាប់រៀបការជាង ឆាប់មានកូនជាង មានអត្រាលទ្ធភាពមានកូនសរុបខ្ពស់ជាង និងមានចំនួនកូនដែលបានបង្កើតច្រើនជាងស្ត្រីនៅតាមរាជធានីខេត្តឯទៀត ហើយសូចនាករទាំងនេះ កាន់តែខ្ពស់ក្នុងចំណោមស្ត្រីដែលមានការអប់រំទាប មានសន្ទស្សន៍ទ្រព្យសម្បត្តិតិចតួច និងរស់នៅទីជនបទ។

ជនជាតិដើមភាគតិចមិនសូវធ្វើទេសន្តរប្រវេសន៍ដូចប្រជាជនកម្ពុជាទូទៅទេ (គឺ ៦% ធៀបនឹង ២១,៥% រៀងគ្នា) ថ្វីត្បិតតែភាគរយអ្នកធ្វើទេសន្តរប្រវេសន៍កើន ពិសេសទេសន្តរប្រវេសន៍ក្នុងអំឡុង៥ឆ្នាំមុនពេលប្រមូលទិន្នន័យ (ចំនួន៤១%នៃអ្នកផ្លាស់ទីសរុប) ដែលភាគច្រើនគឺផ្លាស់ទីពីជនបទទៅជនបទ (៥៩%ក្នុងចំណោមបុរស និង៤៧%ក្នុងចំណោមស្ត្រី)។ ក៏ប៉ុន្តែ ស្ត្រីមាននិន្នាការផ្លាស់ទីពីជនបទទៅទីប្រជុំជនច្រើនជាងបុរស (៣០,៣% ធៀបនឹង ២៣,២% រៀងគ្នា)។ មូលហេតុចម្បងនៃទេសន្តរប្រវេសន៍គឺហេតុផលគ្រួសារ (គ្រួសារផ្លាស់ទី ៣៤% និងរៀបការ៣០,៧%) និងហេតុផលការងារ (ស្វែងរកការងារ ១៥,២% និងផ្ទេរកន្លែងធ្វើការ ៧,៥%)។

## ២. ស្ថានភាពសង្គម-សេដ្ឋកិច្ច

**ការអប់រំ៖** ស្ថានភាពនៃការអប់រំរបស់ជនជាតិដើមភាគតិច មានការរីកចម្រើនគួរកត់សម្គាល់ ក៏ដូចជាការថយចុះនៃគម្លាតយេនឌ័រ បើប្រៀបធៀបទៅនឹងស្ថានភាពឆ្នាំ២០១៣។ នៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចអាយុ៧ឆ្នាំឡើងចេះអាននិងសរសេរភាសាខ្មែរ មានចំនួន៥៦,៥% (៦២,៥%ក្នុងចំណោមបុរស និង៥០,៨%ក្នុងចំណោមស្ត្រី) ដែលកើនឡើងពី៣៤,៣% នៅឆ្នាំ២០១៣ (៤១,៩%ក្នុងចំណោមបុរស និង២៧,៣%ក្នុងចំណោមស្ត្រី)។ ភាគរយកំពុងរៀនបានកើនឡើងពី៤៩%នៅឆ្នាំ២០១៣មក៧៥,៤%នៅឆ្នាំ២០១៩ក្នុងចំណោមកុមារអាយុ៦-១៣ឆ្នាំ និងបានកើនឡើងពី៤៤%នៅឆ្នាំ២០១៣មក៦៧%នៅឆ្នាំ២០១៩ក្នុងចំណោមកុមារអាយុ៦-១៨ឆ្នាំ។ រីឯភាគរយមិនបានរៀន ថយឡើងពី៤៩,៤% នៅឆ្នាំ២០១៣មក២២,៨%នៅឆ្នាំ២០១៩ក្នុងចំណោមកុមារអាយុ៦-១៣ឆ្នាំ និងថយចុះពី៤៨%នៅឆ្នាំ២០១៣មក២២,៦%នៅឆ្នាំ២០១៩ក្នុងចំណោមកុមារអាយុ៦-១៨ឆ្នាំ។

ទោះជាយ៉ាងនេះក្តី កុមារនិងយុវវ័យជនជាតិដើមភាគតិចទទួលបានការអប់រំទាបជាងប្រជាជនកម្ពុជា និងប្រឈមនឹងបញ្ហាមិនបានចូលរៀន ចូលរៀនយឺត រៀននៅកម្រិតថ្នាក់ទាបជាងអាយុ និងបោះបង់ ការសិក្សាច្រើន ដែលមានភាពខុសគ្នារវាងអំបូរជនជាតិដើមភាគតិចនីមួយៗ។ ភាគច្រើននៃជនជាតិដើមភាគតិចអាយុ២៥ឆ្នាំឡើង ទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា (៧៤,៦%នៅជនបទ និង៤៦,៨%នៅទីប្រជុំជន) និងមធ្យមសិក្សាបឋមភូមិ (១៤,៥%នៅជនបទ និង២៣,៨%នៅទីប្រជុំជន) ប៉ុណ្ណោះ។ ចំណែកឯអ្នករៀនដល់មធ្យមសិក្សាទុតិយភូមិ មានចំនួនត្រឹម ៥,៤%ក្នុងចំណោមអ្នកនៅជនបទ និង១៦,០%ក្នុងចំណោមអ្នកនៅទីប្រជុំជន និងអ្នកដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនត្រឹមតែ ០,២%ក្នុងចំណោមអ្នកនៅជនបទ និង០,៦%ក្នុងចំណោមអ្នកនៅទីប្រជុំជន។

**ការចូលរួមកម្លាំងពលកម្មនិងការងារ៖** ជនជាតិដើមភាគតិច មានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងប្រជាជនកម្ពុជាសរុប ពិសេសស្ត្រី។ ជាសរុប ៨៥,២%នៃប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ជាប្រជាជនសកម្មសេដ្ឋកិច្ច (បុរស ៨៧,០% និង ស្ត្រី ៨៣,៥%) ដែលក្នុងនោះ អត្រានិកម្មភាពមានត្រឹមតែ ០,៧%ប៉ុណ្ណោះ។ ភាគច្រើននៃប្រជាជនអសកម្មសេដ្ឋកិច្ច គឺជាសិស្សនិស្សិត និងអ្នកធ្វើកិច្ចការផ្ទះ។ ជនជាតិដើមភាគតិច ដែលមានអត្រាចូលរួមកម្លាំងពលកម្មច្រើន មានក្រោល ថ្មូន មិល កួយ ស្ទៀង គ្រឹង ចារ៉ាយ និងពូនង។

ក៏ប៉ុន្តែ ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិច ប្រកបរបររកស៊ីដោយខ្លួនឯង (៤៤%) ឬធ្វើការងារគ្មានប្រាក់កម្រៃ (៤៩,៣%) ជាពិសេសគឺក្នុងចំណោមស្ត្រីអាយុ១៥ឆ្នាំឡើង (បុរស ២៥% និងស្ត្រី

៧៣% ធ្វើការងារគ្មានប្រាក់កម្រៃ)។ គិតតាមវិស័យសេដ្ឋកិច្ច ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិច អាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ ប្រកបរបរក្នុងវិស័យកសិកម្ម (សរុប៩២,២% បុរស៩០,៧% និង ស្ត្រី៩៣,៦%) និងតិចតួចដែលធ្វើការក្នុងវិស័យឧស្សាហកម្ម (សរុប១,៧% បុរស១,៩% និងស្ត្រី១,៦%) និងវិស័យសេវាកម្ម (សរុប៦,១% បុរស៧,៤% និងស្ត្រី៤,៨%) ដែលភាគរយនេះខុសគ្នាតិចតួចបើធៀប នឹងទិន្នន័យឆ្នាំ២០១៣។

**<u>សុខភាពនិងអនាម័យ</u>**៖ យោងតាមទិន្នន័យអង្កេតសង្គម-សេដ្ឋកិច្ច ១៤%នៃជនជាតិភាគតិចក្នុង ស្រុកទាំងអស់ ធ្លាប់មានជំងឺ និង ០,០៧% ធ្លាប់មានរបួស ក្នុងរយៈពេល៣០ថ្ងៃមុនពេលធ្វើអង្កេត ដែល កុមារាឈឺច្រើនជាងកុមារី និងបុរសវ័យចាស់ឈឺច្រើនជាងស្ត្រីវ័យចាស់។ ជំងឺដែលធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃ ចុងក្រោយ ភាគច្រើនមានជំងឺគ្រុនផ្តាសាយ(៣០,១%) ជំងឺគ្រុនឈាម(១៤,១%) ជំងឺគ្រុនសន្និ (៩,៩%) ជំងឺក្រពះ(៩,៣%) ជំងឺទាក់ទងនឹងសន្លាក់ឆ្អឹង(៩,២%) និងជំងឺរាគរូស(៧,៤%)។ រីឯអ្នក ធ្លាប់មានជំងឺផ្លូវដង្ហើមមានតែ២,៨% ជំងឺគ្រុនចាញ់មាន២% និងជំងឺអាសន្នរោគមានត្រឹមតែ០,៧% ប៉ុណ្ណោះ។ ដោយឡែក កុមារអាយុក្រោម៥ឆ្នាំច្រើនមានជំងឺគ្រុនផ្តាសាយ(៥៦,៦%) ជំងឺគ្រុនឈាម (១៥%) ជំងឺរាគរូស(១១,៤%) ជំងឺផ្លូវដង្ហើម(៦,៩%) និងជំងឺអាសន្នរោគ(៤,៨%)។ សេវាពិគ្រោះ និងព្យាបាលជំងឺដែលបានស្វែងរកមុនគេបង្អស់នាពេលឈឺ គឺឱសថស្ថាន គ្លីនិកឯកជន មន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព រីឯសេវាពិគ្រោះនិងព្យាបាលជំងឺ ដែលអ្នកធ្លាប់ឈឺបានស្វែងរកចុង ក្រោយបង្អស់ មានមន្ទីរពេទ្យបង្អែកខេត្ត មន្ទីរពេទ្យឯកជន គ្លីនិកឯកជន ឱសថស្ថាន និងមន្ទីរពេទ្យបង្អែក ស្រុក។

**<u>ពិការភាព</u>**៖ ទិន្នន័យអំពីពិការភាព បង្ហាញថាជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង ចំនួន៥,៣% មានពិការភាពក្នុងកម្រិតណាមួយ (ស្ត្រី ៥,៧% និងបុរស ៤,៨%) ដែលភាគច្រើនមានពិការភាពអំពីការ មើលនិងការស្តាប់។

**<u>អនាម័យ</u>**៖ គ្រួសារជនជាតិដើមភាគតិចប្រហែល៥៦% គ្មានបង្គន់ប្រើប្រាស់ (ចំនួន៣ដងច្រើន ជាងកម្ពុជាសរុប ដែលមានត្រឹម១៧,២%) (២៧,៨% ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង៥៨% ក្នុង ចំណោមគ្រួសារនៅជនបទ។ ចំពោះប្រភពទឹកស្អាតសម្រាប់បរិភោគ គ្រួសារជនជាតិដើមភាគតិច៥២% ប្រើប្រាស់ទឹកអណ្តូង (៣៦%នៅទីប្រជុំជន និង ៥៤%នៅជនបទ), ជិត១០% មានទឹកបំពង់បណ្តាញ ប្រើប្រាស់ (២៧% នៅទីប្រជុំជន និង ៨% នៅជនបទ)។ ជារួម ភាគរយគ្រួសារជនជាតិដើមភាគតិច ដែលមានប្រភពទឹកស្អាតប្រើប្រាស់ បានកើនឡើង បើធៀបទៅនឹងតួលេខក្នុងរបាយការណ៍ដំបូង។

## ៣. លំនៅឋាន និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

ស្ថានភាពនៃការកាន់កាប់លំនៅឋាន មិនខុសគ្នាទេរវាងឆ្នាំ២០០៨និង២០១៩។ នៅឆ្នាំ២០១៩ ជាង៩៣%នៃគ្រួសារជនជាតិដើមភាគតិចមានលំនៅឋានខ្លួនឯង (៩៣,%នៅជនបទ និង៨៩,១% នៅទីប្រជុំជន), ៥,៨% រស់នៅក្នុងលំនៅឋានគេឱ្យស្នាក់នៅ (៥,៩% នៅជនបទ និង៤,១% នៅទីប្រជុំជន) និងជិត១% ជួលផ្ទះគេនៅ (០,៣% នៅជនបទ និង៦,៦% នៅទីប្រជុំជន)។ ទិន្នន័យអំពីប្រភពភ្លើងបំភ្លឺ ប្រភពឋាមពលចម្អិនអាហារ និងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន បង្ហាញពីស្ថានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់នៃគ្រួសារជនជាតិដើមភាគតិច ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ជាពិសេស គឺចំពោះគ្រួសារជនជាតិដើមភាគតិចដែលរស់នៅក្នុងទីប្រជុំជន។

ប្រភពចម្បងនៃភ្លើងបំភ្លឺ ខុសគ្នាគួរកត់សម្គាល់ក្នុងចន្លោះពេលនេះ ដោយសារការកើនឡើងនៃការប្រើប្រាស់អាគុយ (៤១,៦%នៅឆ្នាំ២០០៨ ធៀបនឹង៦១%នៅឆ្នាំ២០១៩) និងអគ្គិសនីរដ្ឋ (៥%នៅឆ្នាំ២០០៨ ធៀបនឹង៣១,៣%នៅឆ្នាំ២០១៩) ជំនួសចង្កៀងប្រេងកាត (៦៦,២%នៅឆ្នាំ២០០៨ ធៀបនឹង២%នៅឆ្នាំ២០១៩)។ ការប្រើប្រាស់អាគុយជាភ្លើងបំភ្លឺច្រើនមានចំពោះគ្រួសារនៅជនបទ ឯការប្រើប្រាស់អគ្គិសនីរដ្ឋច្រើនមានចំពោះគ្រួសារនៅទីប្រជុំជន។ ឧស នៅបន្តជាប្រភពចម្បងនៃឋាមពលចម្អិនរបស់គ្រួសារជនជាតិភាគតិច ពិសេសចំពោះគ្រួសារនៅជនបទ ឯការប្រើប្រាស់ហ្គាសជាប្រភពចម្អិនច្រើនមានចំពោះគ្រួសារនៅទីប្រជុំជន។

ចំពោះសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ការកើនឡើងនៃភាគរយគ្រួសារមានទូរទស្សន៍ ទូរស័ព្ទដៃ ម៉ូតូ រថយន្ត និងគោយន្ត និងការថយចុះនៃភាគរយគ្រួសារប្រើប្រាស់វិទ្យុនិងកង់ បង្ហាញពីស្ថានភាពរីកចម្រើនល្អប្រសើរជាងមុនរបស់គ្រួសារជនជាតិភាគតិចនៅឆ្នាំ២០១៩។ ជាក់ស្តែង ក្នុងចំណោមគ្រួសារជនជាតិដើមភាគតិច ជិត១ភាគ៤នៃគ្រួសារមានទូរទស្សន៍ប្រើប្រាស់ (៥២,៣%នៅទីប្រជុំជន និង២១,១%នៅជនបទ), ៧៨,៧% មានទូរស័ព្ទដៃប្រើប្រាស់ (៨៥,៨%នៅទីប្រជុំជន និង៧៨,២%នៅជនបទ), ៧៨,៥%មានម៉ូតូ (៨៣,៥%នៅទីប្រជុំជន និង៧៨,១%នៅជនបទ), ២,៧%មានរថយន្ត (១០,៧% នៅទីប្រជុំជន និង២,១%នៅជនបទ), ៣,៦%មានទូរទឹកកក (១៨,៦%នៅទីប្រជុំជន និង២,៥%នៅជនបទ), ២,៣%មានកុំព្យូទ័រ (១០,៥%នៅទីប្រជុំជន និង១,៧%នៅជនបទ), និង២០,១%មានគោយន្ត (៦,១%នៅទីប្រជុំជន និង២១,២%នៅជនបទ)។

## ៤. ការចុះបញ្ជីសហគមន៍និងកម្មសិទ្ធិដីសមូហភាព

យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៣១និងមាត្រា៤៤ និងច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៣ ក៏ដូចជាគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ សហគមន៍ជនជាតិដើមភាគតិចត្រូវបានកំណត់ដោយការធ្វើស្វ័យអត្តសញ្ញាណដោយជនជាតិដើមភាគតិច ថាខ្លួនជាផ្នែកឬសមាជិកនៃក្រុមអំបូរឬសហគមន៍ជាក់លាក់មួយ នៅក្នុងមូលដ្ឋានដែនដីដែលខ្លួនកំពុងរស់នៅ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនៅមូលដ្ឋានដែលពួកគាត់រស់នៅ បានចំនួន១៩៨សហគមន៍ ដែលមានជនជាតិដើមភាគតិចចំនួន ១៤អំបូរ ស្ថិតនៅក្នុងភូមិនៃខេត្តចំនួន១៤ ក្នុងចំណោមសហគមន៍សរុបប្រហែល៤៥៨សហគមន៍។ ក្រសួងមហាផ្ទៃ ក៏បានចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជាសហគមន៍នីតិបុគ្គល សរុបចំនួន១៥៤សហគមន៍ ស្ថិតនៅក្នុងភូមិនៃខេត្តចំនួន៨ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤។ គិតត្រឹមខែសីហា ឆ្នាំ ២០២៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏បានចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច បានចំនួន៤២ភូមិសហគមន៍ និងបានផ្តល់កម្មសិទ្ធិដីសមូហភាពចំនួន១ ១០៥ប័ណ្ណ លើផ្ទៃដី៤១ ៥៣៩ហិកតា ដែលគ្របដណ្តប់៤ ១៥៩គ្រួសារ ក្នុងខេត្តរតនៈគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង ។

## ៥. សេចក្តីសន្និដ្ឋាន

បច្ចុប្បន្ន ជនជាតិដើមភាគតិចកំពុងមានស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចល្អប្រសើរជាងមុន ប្រើធៀបទៅនឹងទិន្នន័យឆ្នាំកម្លងទៅ។ ទោះជាយ៉ាងនេះក្តី ស្ថានភាពទាំងនេះនៅមិនទាន់ល្អប្រសើរដូចប្រជាជនកម្ពុជានៅឡើយ នៅគ្រប់ទិដ្ឋភាពសង្គម-សេដ្ឋកិច្ចទាំងអស់។ ជនជាតិដើមភាគតិចនៅជួបបញ្ហាប្រឈមជាច្រើនដែលត្រូវគិតគូរថែមទៀត ទៅលើការស្រាវជ្រាវនិងវិភាគស៊ីជម្រៅអំពីឈ្មោះនិងចំនួនអំបូរ និងព័ត៌មានពាក់ព័ន្ធនានា ដើម្បីជាមូលដ្ឋានសម្រាប់ការការពារ ការអភិរក្ស និងការអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា ស្របតាមសារលិខិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលោកទី៣០ និងលើកទី២០នៅកម្ពុជា នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ ដែលបានជំរុញការអភិវឌ្ឍភូមិជនជាតិដើមភាគតិចទៅជាភូមិគំរូ ផ្អែកលើសក្តានុពលវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងទេសចរណ៍ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល និងការបន្តអប់រំនិងផ្សព្វផ្សាយពីភាពចាំបាច់និងសារសំខាន់នៃការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច ឱ្យបានទូលំទូលាយ ទៅដល់គ្រប់សហគមន៍ជនជាតិដើមភាគតិច និងសាធារណជន។

# ផែនទី

ចំនួនប្រជាជនជនជាតិដើមភាគតិចនៅតាមខេត្តនីមួយៗនៃប្រទេសកម្ពុជា




ភាគរយនៃប្រជាជនជនជាតិដើមភាគតិចអាយុ ១៥-៥៩ ឆ្នាំដែលចេះអក្សរខ្មែរនៅតាមខេត្តនីមួយៗនៃប្រទេសកម្ពុជា



# ១. សេចក្តីផ្តើម

## ១.១. សាវតា

ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលមានដើមកំណើតនិងរស់នៅលើទឹកដីនៃប្រទេសកម្ពុជាយូរលង់មកហើយ និងមានប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា ភាសា និងរបៀបរបបរស់នៅដោយឡែក តែជាផ្នែកនៃសង្គមវប្បធម៌របស់ប្រទេសកម្ពុជាទាំងមូល។ ជាប្រវត្តិសាស្ត្រ ការរស់នៅរបស់ជនជាតិដើមភាគតិច ពឹងផ្អែកទាំងស្រុងទៅលើបរិស្ថានធម្មជាតិ ដោយផ្សារភ្ជាប់នឹងដីធ្លីនិងព្រៃឈើ ដើម្បីប្រកបមុខរបរចម្បងសម្រាប់ចិញ្ចឹមជីវិត ដែលមានការធ្វើស្រែចំការវិលជុំ ការប្រមូលអនុផលព្រៃឈើ ការប្រមាញ់ ការនេសាទ និងការចិញ្ចឹមសត្វ។ល។

យោងតាមឯកសារនានាដែលមាន ជនជាតិដើមភាគតិចនៅកម្ពុជា ជាឈ្មោះមានចំនួន២៧អំបូរ គឺ ពូនង ក្ួយ ទំពួន ចារ៉ាយ គ្រឹង ព្រៅ ការ៉ែត ស្ទៀង គ្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្អូច រដែ ខិ រអង ស្តុង ល្មឺន សំរែ គ្លឹង កាជ្រុក និងមន។ រីឯចំនួនអំបូរពិតប្រាកដ គេពិបាកនឹងកំណត់ណាស់ ព្រោះប្រភពទិន្នន័យផ្សេងគ្នាបង្ហាញពីចំនួនខុសៗគ្នា កង្វះឯកសារគ្រប់ជ្រុងជ្រោយ កង្វះការស្រាវជ្រាវបន្ថែម និងការបាត់បង់ភាសានិយាយ[១] ដូចជា គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចមាន២៤អំបូរ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាមាន២២អំបូរ និងទិន្នន័យឃុំសង្កាត់មាន ១៩អំបូរ ដែលបានរៀបរាប់ (ឧបសម្ព័ន្ធទី ១)។ ក្រៅពីចំនួនអំបូរខុសៗគ្នា ឈ្មោះអំបូរក៏មានខុសគ្នាដែរ ដូចជាជនជាតិគ្លឹង កាជ្រុក និងមន ឃើញមានតែនៅក្នុងទិន្នន័យជំរឿនតែប៉ុណ្ណោះ។

ទោះយ៉ាងណាក្តី អំបូរជនជាតិដើមទាំងនេះ មានប្រភពវប្បធម៌ និងភាសាដើមផ្សេងៗគ្នា ដែលភាគច្រើនជាអំបូរនិយាយភាសាអូស្ត្រូអាស៊ាទិច ពិសេសអំបូរមនខ្មែរ (Austroasiatic speaking, Especially Mon-Khmer) (ដូចជា ព្រៅ គ្រឹង ទំពួន ពូនង និង ក្ួយ ជាដើម)[២] និងចារ៉ាយជាអំបូរនិយាយ ភាសាអូស្ត្រូណេស៊ាន (Austronesian speaking)។ អំបូរមួយចំនួន ជាផ្នែកនៃជនជាតិ ដើមភាគតិចនៅក្នុងតំបន់ជាប់គ្នានៃប្រទេសកម្ពុជា ឡាវ និងវៀតណាម។

---

[១] https://m.freshnewsasia.com/index.php/en/localnews/129551-2019-08-01-11-39-04.html

[២] ១) Cambodia: Indigenous Peoples in ASEAN, ២០១៥, Asian Indigenous Peoples Pac; and ២) Indigenous Peoples in Cambodia. NGO Forum on Cambodia, ២០០៦. https://preylang.net/wp-content/uploads/២០១៧/០៩/indigenous_peoples_cambodia.pdf

កន្លងមក មានការយល់ច្រឡំរវាងពាក្យស័ព្ទជនជាតិដើមភាគតិចនិងជនជាតិភាគតិច ដែលរស់នៅលើទឹកដីនៃប្រទេសកម្ពុជា (Indigenous Peoples and Ethnic Minorities) ដោយសារមាននិយមន័យជាច្រើនខុសៗគ្នានិងមានភាពមិនច្បាស់លាស់ ហើយការប្រើប្រាស់និយមន័យទាំងនេះអាស្រ័យទៅតាមគោលបំណងផ្សេងៗគ្នា។ ឯកសារជាច្រើនបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីភាពខុសគ្នារវាងជនជាតិដើមភាគតិច និងជនជាតិភាគតិច ដូចជា៖

- ជនជាតិភាគតិចនៅកម្ពុជា (Ethnic Minorities or Non-Indigenous Ethnic Minorities) គឺជាជនជាតិដែលមានដើមកំណើតនៅក្នុងប្រទេសឬតំបន់ផ្សេងៗ តែបានចូលមករស់នៅក្នុងទឹកដីនៃប្រទេសកម្ពុជា ដោយបន្តរក្សាវប្បធម៌ ប្រពៃណីនិងទំនៀមទម្លាប់ដើមរបស់ខ្លួននៅ ក្នុងប្រទេសកម្ពុជា ដូចជាជនជាតិភាគតិចឡាវ វៀតណាម ចាម ជាដើម។ ជាទូទៅ ជនជាតិភាគតិច គឺជាជនជាតិនៃពូជសាសន៍ដទៃដែលកំពុងរស់នៅលើទឹកដីមួយ ដែលមិនមែនជាប្រទេសកំណើត របស់ខ្លួន។ ជនជាតិភាគតិចនៅក្នុងប្រទេសមួយ មានចំនួនប្រជាជនតិចតួច ធៀបទៅនឹងចំនួន ប្រជាជននៃប្រទេសដែលខ្លួនចូលមករស់នៅ និងដែលគ្មានគោលជំហរគ្របដណ្តប់ទៅលើ គោលជំហររបស់ប្រជាជននៃប្រទេសដែលខ្លួនកំពុងរស់នៅ (Non-dominant position)។
- ជនជាតិដើម[៣] ឬហៅថាជនជាតិដើមភាគតិច (Indigenous Peoples or Indigenous Groups or Indigenous Minorities) នៅកម្ពុជា គឺជាក្រុមជនជាតិដែលមានដើមកំណើតរស់នៅលើទឹកដីកម្ពុជាយូរលង់មកហើយ ដែលមាននិងបន្តរក្សាជំនឿ ប្រពៃណី ទំនៀមទម្លាប់ ភាសា និងរបៀបរបបរស់នៅដោយឡែករបស់ខ្លួន ដូចជាជនជាតិពូនង ព្រៅ កួយ ជាដើម។
- យោងតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ ជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនជាតិទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើ ប្រាស់ដីជាសមូហភាព[៤]។
- នៅក្នុងក្របខ័ណ្ឌផែនការសម្រាប់អភិវឌ្ឍជនជាតិដើមភាគតិច នៃគម្រោងផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ (IPPF-WSSIP) ឆ្នាំ២០១៨ ធនាគារពិភពលោកបានគូសបញ្ជាក់ថា ជន

---

[៣] United Nations Declaration on the Rights of Indigenous Peoples No. ៦១/២៩៥ on ១៣ September ២០១៩ (Khmer translation: www.un.org/esa/socdev/unpfii/documents/UNDRIP_khmer.pdf)

[៤] ក្រសួងអភិវឌ្ឍន៍ជនបទ (២០០៩) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩, រាជរដ្ឋាភិបាលកម្ពុជា។

ជាតិ ដើមភាគតិចត្រូវបានគេស្គាល់ថាជាក្រុមដាច់ដោយឡែកពីក្រុមជនជាតិភាគតិច ដូចជាជនជាតិឡាវដែលរស់នៅក្នុងតំបន់ឦសាននៃប្រទេសកម្ពុជា ឬជនជាតិវៀតណាម ឬ ជនជាតិឥស្លាម ដែលរស់នៅតាមតំបន់នានានៃប្រទេស ដែលក្រុមទាំងនេះមិនត្រូវបានចាត់ ទុកជាជនជាតិដើមភាគតិចទេ[៥]។ នៅក្នុងផែនការនិងគម្រោងអភិវឌ្ឍន៍របស់ខ្លួន ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានបញ្ជាក់ច្បាស់ថា ជនជាតិភាគតិច ដូចជាជនជាតិវៀតណាម ឥស្លាម ចិន ខុសពីជនជាតិដើមភាគតិច[៦]។

របាយការណ៍នេះកំណត់យកនិយមន័យជនជាតិដើមភាគតិច ទៅតាមគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនជាតិទាំងនោះ បង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅ តាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព។

ប្រទេសកម្ពុជា បានបោះឆ្នោតគាំទ្រសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ក្នុងឆ្នាំ ២០០៧ និងអនុលោមតាមសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពី សិទ្ធិជនជាតិដើមភាគតិច ដែលក្នុងនោះមាន៖

- មាត្រា៣, ៩, ១១, និង ៣៣ ទទួលស្គាល់ការរស់នៅ ការការពារ និងការកំណត់អត្តសញ្ញាណស្របតាមប្រពៃណី ទំនៀមទំលាប់របស់ខ្លួន
- មាត្រា១៧ ចែងអំពីការមានសិទ្ធិទទួលបានយ៉ាងពេញលេញនូវសិទ្ធិគ្រប់យ៉ាង ដែលមានចែងក្នុងច្បាប់ជាតិនិងអន្តរជាតិ
- មាត្រា២៦និង២៧ ចែងថា "រដ្ឋទទួលស្គាល់និងការពារផ្លូវច្បាប់ចំពោះដីធ្លីនិងធនធាននានា ដែលប្រព្រឹត្តទៅតាមទំនៀម ទំលាប់ប្រពៃណី និងប្រព័ន្ធកាន់កាប់ដីធ្លី និងលក្ខណៈវិនិច្ឆ័យសិទ្ធិរបស់ជនជាតិដើមភាគតិច"។

នៅក្នុងឆ្នាំ២០០៩ កម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដែលស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជា ដែលទទួលស្គាល់ជនជាតិដើមភាគតិចថាជាពលរដ្ឋកម្ពុជា។ កម្ពុជាក៏មាន

---

[៥] https://documents១.worldbank.org/curated/ar/៥៧១១១១៥៣៨៧២៦៣០៦០៩៥/pdf/SFG៤៦៨២-V១-REVISED-IPP-P១៦៣៨៧៦-PUBLIC-Disclosed-២-៦-២០១៩.pdf

[៦] https://www.adb.org/sites/default/files/publication/២៨០២១/indigenous-peoples-cambodia.pdf

ច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងៗជាច្រើនទៀត ដែលសំដៅផ្តល់ការការពារដល់ជនជាតិដើមភាគតិចនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បាននិងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិចនៅកម្ពុជា ពិសេសគឺចាប់ពីដើមទសវត្សឆ្នាំ៩០នៃសតវត្សទី២០មក ពីព្រោះជនជាតិដើមភាគតិចមានជាតិពន្ធុ សង្គម-សេដ្ឋកិច្ច វប្បធម៌ ប្រពៃណីនិងទំនៀមទម្លាប់ របៀបរស់នៅ និងភាសាដោយឡែកៗពីគ្នាទៅតាមក្រុមអំបូររបស់ខ្លួន ដែលបង្ហាញពីភាពចម្រុះនៃជាតិពន្ធុ សង្គម-សេដ្ឋកិច្ច វប្បធម៌ ប្រពៃណីនិងទំនៀមទម្លាប់ របៀបរស់នៅ និងភាសានៅក្នុងប្រទេសកម្ពុជាយើង។

ដោយជនជាតិដើមភាគតិចត្រូវបានចាត់ទុកថាជាក្រុមងាយទទួលភាពរងគ្រោះ ដែលចាំបាច់ត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេស នៅក្នុងដំណើរអភិវឌ្ឍសង្គម-សេដ្ឋកិច្ច រាជរដ្ឋាភិបាលបាននិងកំពុងបន្តយកចិត្តទុកដាក់ខ្ពស់ដល់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច តាមរយៈការរៀបចំឯកសារគតិយុត្តិស្ថាប័នទទួលបន្ទុក និងគម្រោងនិងផែនការសកម្មភាពជាបន្តបន្ទាប់ ដើម្បីអភិរក្សនិងអភិវឌ្ឍជនជាតិដើមភាគតិច និងទទួលស្គាល់សហគមន៍និងកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច។ ឯកសារគតិយុត្តិសំខាន់ៗពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលមានពាក់ព័ន្ធនឹងជនជាតិដើមភាគតិច មានដូចជា៖

- រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ទទួលស្គាល់ថាជនជាតិដើមភាគតិចគឺជាពលរដ្ឋកម្ពុជា និង ចែងថាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះច្បាប់ និងមានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចៗគ្នា ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ទំនោរផ្នែកនយោបាយ កំណើត ប្រភពដើម ស្ថានភាពសង្គម ធនធាន និងស្ថានភាពឯទៀតឡើយ (មាត្រា ៣១.២)។
- ច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ជាម្ចាស់អចលនវត្ថុ ជាដីរបស់ពួកគេដែលមានប័ណ្ណកម្មសិទ្ធិសមូហភាព។
- ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការបន្តការប្រើប្រាស់ និងចូលទៅកាន់តំបន់ព្រៃឈើមួយចំនួន ដែលក្រុមទាំងនេះប្រើប្រាស់តាមបែបប្រពៃណី និងការអនុវត្តរបៀបរស់នៅរបស់ពួកគេក្នុងការអាស្រ័យផលពីព្រៃឈើ។
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ២០០៨ (មាត្រា២២) ទទួលស្គាល់និងធានាសិទ្ធិប្រើប្រាស់ តាមលក្ខណៈប្រពៃណី ទំនៀមទំលាប់ ជំនឿ សាសនា របស់សហគមន៍។
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ មានគោលដៅកែលម្អជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច ដោយផ្តោតលើវិស័យចំនួន១០ រួមមាន វប្ប

ធម៌ ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្មនិងធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។ សារាចរណ៍ណែនាំ នីតិវិធី និងវិធីសាស្ត្រអនុវត្តគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិ ដើមភាគតិច ផ្តោតទៅលើការផ្សព្វផ្សាយគោលនយោបាលជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគ តិច លក្ខណៈវិនិច្ឆ័យ និងកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច។

- គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់របស់សហគមន៍ជនជាតិដើមភាគតិចឆ្នាំ ២០០៩ ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការកាន់កាប់និងប្រើប្រាស់ដីជាកម្មសិទ្ធិជាសមូហភាពរបស់ជនជាតិដើមភាគតិច
- អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិភាគតិចឆ្នាំ២០០៩ ដែលក្រសួងអភិវឌ្ឍន៍ជនបទមានភារកិច្ចកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនិងសហគមន៍ ក្រសួងមហាផ្ទៃមានភារកិច្ចចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព
- យុទ្ធសាស្ត្រទី៧ នៃគោលនយោបាយស្តីពីបរិស្ថាននិងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៩ ទទួលស្គាល់ថា ក្រុមជនជាតិដើមភាគតិចជាក្រុមងាយទទួលរងគ្រោះ ដែលត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេស និងធានាថា រាល់ការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានណាមួយដល់ជីវភាពរស់នៅ ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិចឡើយ[៧]

ទោះជាយ៉ាងនេះក្តី កង្វះទិន្នន័យនិងការស្រាវជ្រាវជាបញ្ហាចម្បងក្នុងការអនុវត្តនិងការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពនានា សំដៅអភិរក្សនិងអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា។ ដើម្បីរួមចំណែកបន្ថែមទៀតក្នុងការពង្រឹងនិងពង្រីកការយកចិត្តទុកដាក់និងការអនុវត្តដើម្បីសម្រេចបាននូវគោលដៅនៃគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេសដើម្បីមានទិន្នន័យផ្លូវការអំពីជនជាតិដើមភាគតិច សម្រាប់ការងារអនុវត្តនិងការងារតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយពាក់ព័ន្ធ **របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច របស់**

---

[៧] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១៩), គោលនយោបាយស្តីពី បរិស្ថាន និងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, www.ncdd.gov.kh/wp-content/uploads/2019/06/NCDD_ESS-Policy_approval.pdf

**ជនជាតិដើមភាគតិចនៅកម្ពុជា** ត្រូវបានរៀបចំឡើងលើកដំបូងជាប្រវត្តិសាស្ត្រ នៅឆ្នាំ២០១៩ និង បានផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១។ របាយការណ៍នោះប្រើប្រាស់ទិន្នន័យផ្លូវការដែលមានស្រាប់ ដូចជាទិន្នន័យជំរឿនឆ្នាំ២០០៨ ទិន្នន័យអង្កេតចន្លោះជំរឿនឆ្នាំ២០១៣ ទិន្នន័យអង្កេតសង្គមកិច្ចសេដ្ឋកិច្ចឆ្នាំ២០១៥ និងទិន្នន័យរដ្ឋបាលមួយចំនួនដែលពាក់ព័ន្ធ។ របាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ជាប្រភេទរបាយការណ៍ជាស៊េរី ដែលត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់រាល់ពេលមានទិន្នន័យថ្មី ដើម្បីផ្តល់ព័ត៌មានអំពី វឌ្ឍនភាពនិងនិន្នាការនៃស្ថានភាពប្រជាសាស្ត សង្គម-សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិច។ ឈរលើមូលដ្ឋាននេះ របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ ត្រូវបានឯកភាពរៀបចំឡើង ដោយសារ ការមានទិន្នន័យថ្មីៗជាច្រើន ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិចនៅកម្ពុជា ពិសេសគឺទិន្នន័យ ជំរឿនឆ្នាំ២០១៩ ទិន្នន័យអង្កេតសង្គមកិច្ចសេដ្ឋកិច្ចឆ្នាំ២០១៩-២០២០ ទិន្ន័យប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០២១-២០២២ និងទិន្នន័យរដ្ឋបាលជាច្រើនទៀត។

របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះមានឈ្មោះថា **របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ បច្ចុប្បន្នភាពឆ្នាំ២០២៤** (ដែលអាចហៅកាត់ថា **របាយការណ៍ជនជាតិដើមភាគតិច ឆ្នាំ២០២៤**)។

## ១.២. គោលបំណង

របាយការណ៍ជនជាតិដើមភាគតិច បច្ចុប្បនភាពឆ្នាំ២០២៤ នេះ ក៏ដូចជារបាយការណ៍លើកដំបូងដែរ គឺផ្តោតលើជនជាតិដើមភាគតិចនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា។ គោលបំណងចម្បងៗ នៃការធ្វើបច្ចុប្បន្នភាពរបាយការណ៍ជនជាតិដើមភាគតិច បច្ចុប្បនភាពឆ្នាំ២០២២ មានដូចខាងក្រោម៖

១. ធ្វើបច្ចុប្បន្នភាពទិន្នន័យនិងព័ត៌មានអំពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច ក៏ដូចជាការរស់នៅរបស់ជនជាតិដើមភាគតិច ដោយប្រើប្រាស់ទិន្នន័យថ្មីៗ គឺទិន្នន័យពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣

២. រំលេចពីភាពខុសគ្នា អំពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច ក៏ដូចជាការរស់នៅរបស់ជនជាតិដើមភាគតិច រវាងជនជាតិដើមភាគតិចនៅកម្ពុជា និងប្រជាជនកម្ពុជាទាំងអស់ ក្នុងឆ្នាំនៃទិន្នន័យថ្មីបំផុត និងនិន្នាការនៃការប្រែប្រួលនៃភាពខុសគ្នានេះរវាងឆ្នាំនៃទិន្នន័យមុន និងឆ្នាំនៃទិន្នន័យថ្មីបំផុត

៣. បន្ថែមសូចនាករមួយចំនួន ដោយយោងតាមស្ថានភាពជាក់ស្តែងនៃទិន្នន័យដែលមាន និង អនុសាសន៍ដែលទទួលបាននៅក្នុងពិធីផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់ របាយការណ៍ស្តីពី ស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា កាលពីឆ្នាំ ២០២១ ដូចជាព័ត៌មានអំពីវប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធ និងសហគមន៍ជនជាតិ ដើមភាគតិច ជាដើម។

## ១.៣. ដែនកំណត់និងការប្រឈម

ដូចរបាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិច នៅកម្ពុជាលើកទីមួយដែរ របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ បន្តផ្តោតលើស្ថានភាព និងការប្រែ ប្រួលប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច របស់ក្រុមប្រជាជននៃជនជាតិដើមភាគតិចនៅកម្ពុជា ដោយផ្អែកទាំងស្រុងលើទិន្នន័យផ្លូវការដែលមានស្រាប់ ដូចជាទិន្នន័យជំរឿន ទិន្នន័យអង្កេត និងទិន្នន័យ និងរដ្ឋបាលពីក្រសួងស្ថាប័នពាក់ព័ន្ធ។

របាយការណ៍នេះ សំដៅតែលើជនជាតិដើមភាគតិចយោងតាមនិយមន័យជនជាតិដើមភាគតិចនៅកម្ពុជា ដូចបានលើកឡើងនៅខាងលើ ដែលកំណត់ជនជាតិដើមភាគតិចជាក្រុមជាតិពន្ធុដោយឡែកខុសពីជនជាតិភាគតិចទូទៅ។ តាមនិយមន័យនេះ ជនជាតិដើមភាគតិចត្រូវបានកំណត់អត្តសញ្ញាណតាមរយៈភាសានិយាយពីកំណើតនៃទិន្នន័យជំរឿន ដែលបង្ហាញភាសានិយាយពីកំណើតរបស់ជនជាតិដើមភាគតិចចំនួន២២ភាសា។ នេះមានន័យថា អាចមានក្រុមជនជាតិដើមភាគតិច ដែលមិនអាចកំណត់អត្តសញ្ញាណបានតាមទិន្នន័យដែលមានស្រាប់។ លើសពីនេះទៀត ចំនួនពិតប្រាកដនៃប្រជាជនជនជាតិដើមភាគតិចដែលមានក្នុងទិន្នន័យ អាចតិចជាងការពិត ដោយហេតុថា កូនឬចៅជនជាតិដើមភាគតិចខ្លះនិយាយភាសាខ្មែរពីកំណើត ឬយកភាសាខ្មែរដែលបានរៀននិងកំពុងប្រើប្រាស់ថាជាភាសាកំណើតរបស់ខ្លួន។

រីឯការប្រើនិងសរសេរឈ្មោះអំបូរជនជាតិដើមភាគតិច គឺយោងតាមឈ្មោះដែលប្រើនៅក្នុងរបាយការណ៍ដំបូង ដែលមានទទួលការឯកភាពគ្នាពីក្រុមការងារផលិតរបាយការណ៍រួចមកហើយ។ ដោយឡែកពាក្យ *ព្នង* ត្រូវបានលើកយកមកពិគ្រោះយោបល់បន្ថែមជាច្រើនលើក ទាំងក្នុងកិច្ចប្រជុំក្រុមការងារ ទាំងជាមួយភាគីពាក់ព័ន្ធនិងជនជាតិដើមភាគតិចនៅមូលដ្ឋាន។ កន្លងមកគេច្រើនសរសេរជា *ព្នង* ទាំងនៅក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច២០០៩។ តាមការពន្យល់បកស្រាយរបស់ជនជាតិដើមភាគតិចនៅតាមមូលដ្ឋាន ភាសានិយាយគឺ ពូ-នង មិនមែន ព្នង ទេ ដែលសំណេរគួរជា *ពូនង* ឬ *ប៊ូនង* ជាភាសាជនជាតិពូនង ដែលមានសូរ Bu-nong។ យោងតាមវចនានុក្រមសម្តេចជួន ណាត ព្នងគឺ ″

*មនុស្សពួកមួយ កើតនៅតែក្នុងព្រៃ, ស្លៀកប៉ឹងរំលួ, មានសណ្តាប់ធ្នាប់ផ្សេងពីពួកមនុស្ស អ្នកស្រុក...ក្រោយប្រទេសកម្ពុជាទទួលបានឯករាជ្យ ព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម បានបញ្ញត្តឱ្យលែងហៅ ព្នង និងឱ្យហៅថា ខ្មែរលើ វិញ, ពួកខ្មែរលើក៏មានសភាពលូតលាស់ចម្រើនតាមលំដាប់មក*"។ សារព័ត៌មានកម្ពុជាថ្មី[៩] បានចុះផ្សាយនាថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ថា ***ប៊ូនង*** (Bunong) គឺជាភាសាសរសេរត្រឹមត្រូវតាមអក្សរព្នង-ខ្មែរ (ឬ Bunong-Latin) ដែលបង្កើតឡើងអំឡុងឆ្នាំ២០០០ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ក៏ប៉ុន្តែភាសាខ្មែរគ្មានពាក្យ***ប៊ូនង*** ទេ។ ម្យ៉ាងវិញទៀត ជនជាតិ***ប៊ូនង*** យល់ថា ការហៅថា ព្នង ឬភ្នង គឺជាការរើសអើងយ៉ាងធ្ងន់ធ្ងរ។ ក្នុងន័យនេះ របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ ប្រើពាក្យ **ពូនង** ដែលជាសំណេរតាមភាសាខ្មែរទៅតាមសូរនៃការនិយាយរបស់ជនជាតិដើមភាគតិច។

ប្រភពទិន្នន័យខុសគ្នា ផ្តល់តួលេខខុសគ្នាដែលពិបាកធ្វើការប្រៀបធៀប។ ដូចក្នុងរបាយការណ៍លើកដំបូងបានគូសបញ្ជាក់ ទិន្នន័យជំរឿននិងទិន្នន័យឃុំសង្កាត់ផ្តល់តួលេខខុសគ្នា ដែលទិន្នន័យឃុំសង្កាត់ជាទូទៅផ្តល់តួលេខធំជាងទិន្នន័យជំរឿន (សូមមើលឧបសម្ព័ន្ធទី៦ ទី៧ ទី៨ និងទី៩)។ ភាពខុសគ្នានេះអាចបណ្តាលមកពីភាពខុសគ្នានៃប្រភពនៃទិន្នន័យ ដែលទិន្នន័យឃុំសង្កាត់អាស្រ័យលើទីលំនៅអចិន្ត្រៃយ៍របស់ប្រជាពលរដ្ឋនិងទិន្នន័យរដ្ឋបាល ឯទិន្នន័យជំរឿនអាស្រ័យលើទីកន្លែងស្នាក់នៅជាក់ស្តែងនាពេលធ្វើជំរឿននិងការសម្ភាសន៍។

គួរកត់សម្គាល់ផងដែរថា យើងពុំមានទិន្នន័យអំពីហេដ្ឋារចនាសម្ព័ន្ធនៃសហគមន៍ជនជាតិដើមភាគតិចទេ។

## ១.៤. វិធីសាស្ត្រ

របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ ជាប្រភេទការស្រាវជ្រាវដែលប្រើប្រាស់ ទិន្នន័យមានស្រាប់ ដែលមានការវិភាគទិន្នន័យបន្ថែមតាមការចាំបាច់ទៅលើប្រធានបទនីមួយៗ ទៅតាម តម្រូវការរបស់ភាគីអ្នកប្រើប្រាស់របាយការណ៍។

ការប្រៀបធៀបនានា ដើម្បីពិនិត្យមើលការរីកចម្រើននិងនិន្នាការនៃការប្រែប្រួល អំពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច ក៏ដូចជាការរស់នៅរបស់ជនជាតិដើមភាគតិច និងបម្រែបម្រួលនៃភាព

[៩] https://www.kampucheathmey.com/belief/257887

ខុសគ្នារវាងស្ថានភាពជនជាតិដើមភាគតិចនិងស្ថានភាពប្រជាជនកម្ពុជាទាំងអស់ ត្រូវបានផ្តោតជាចម្បងទៅលើទិន្នន័យជំរឿនឆ្នាំ២០០៨និងឆ្នាំ២០១៩ និងទិន្នន័យរដ្ឋបាល ពីព្រោះជាប្រភេទទិន្នន័យដូចគ្នាដែលអាចផ្តល់ភាពត្រឹមត្រូវបំផុតក្នុងការប្រៀបធៀប។

ទោះជាយ៉ាងនេះក្តី ប្រភពទិន្នន័យដទៃទៀត នៅតែមានតម្លៃប្រើប្រាស់បន្ថែមសម្រាប់របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ ដូចជាទិន្នន័យអង្កេតសង្គមកិច្ចសេដ្ឋកិច្ចឆ្នាំ២០១៩-២០២០ និងឆ្នាំ២០២២ ទិន្នន័យប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០២១-២០២២ ទិន្នន័យសហគមន៍ពាក់ព័ន្ធ និងទិន្នន័យរដ្ឋបាលរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។ ទិន្នន័យទាំងនេះ ត្រូវបានយកមកប្រើប្រាស់បន្ថែមនៅក្នុងរបាយការណ៍បច្ចុប្បន្នភាពនេះ ទៅតាមប្រធានបទពាក់ព័ន្ធ។

ដោយឡែក ការវិភាគទិន្នន័យនិងការរៀបចំរបាយការណ៍ ត្រូវបានធ្វើឡើងដោយកុងស៊ុលតង់បង្គោល និងបានឆ្លងកាត់ការត្រួតពិនិត្យនិងឯកភាពពីក្រុមការងារចំពោះកិច្ចមួយ រវាងក្រសួងផែនការនិងតំណាងអង្គការជនជាតិដើមភាគតិចនៅកម្ពុជា និងពីក្រុមការងារអន្តរស្ថាប័នផលិតទិន្នន័យសហគមន៍និងរបាយការណ៍ជនជាតិដើមភាគតិច ដែលមានក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងអង្គការជនជាតិដើមភាគតិចនៅកម្ពុជា និងដៃគូអភិវឌ្ឍន៍ ជាសមាជិក និងមានតំណាងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជារបស់អង្គការសហប្រជាជាតិ ជាអ្នកសង្កេតការណ៍ផងដែរ។

យោងតាមទិន្នន័យដែលមាន ទិន្នន័យស្ថិតិដែលជាលទ្ធផលវិភាគអំពីជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍នេះ ត្រូវបានបង្ហាញជាគោលការណ៍ទៅតាមប្រធានបទ ដោយ៖

១. ពិនិត្យមើលនិន្នាការប្រែប្រួល រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩

២. ប្រៀបធៀបជាមួយនឹងស្ថិតិនៃប្រជាជនកម្ពុជាសរុប

៣. ប្រៀបធៀបរវាងក្រុមអំបូរនៃជនជាតិដើមភាគតិចដែលមានចំនួនប្រជាជនច្រើនគ្រប់គ្រាន់

៤. ប្រៀបធៀបរវាងទីកន្លែងរស់នៅ (ជនបទនិងទីប្រជុំជន) រវាងភេទ និងរវាងក្រុមអាយុ។

## ១.៥. រចនាសម្ព័ន្ធនៃរបាយការណ៍

រចនាសម្ព័ន្ធនៃរបាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២២ យកលំនាំតាមរបាយការណ៍លើកទីមួយ តែមានការសម្រួលនិងបន្ថែមចំណុចខ្លះៗ ដើម្បីឱ្យប្រធានបទនីមួយៗមានចរិតគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពជាងមុន ដែលរួមមាន៖

១. សេចក្តីផ្តើម
២. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច
៣. ស្ថានភាពសង្គម-សេដ្ឋកិច្ចនៃជនជាតិដើមភាគតិច
៤. លំនៅឋាន និងដីធ្លីនិងកម្មសិទ្ធិសមូហភាព
៥. សេចក្តីសន្និដ្ឋាន
៦. ឧបសម្ព័ន្ធ

## ២. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច

ជាសេចក្តីរំលឹក សម្រាប់របាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២៤នេះ ក៏ដូចជារបាយការណ៍ដំបូងដែរ ជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជន ជាតិទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព។ ជនជាតិភាគតិចដទៃទៀតដែលរស់នៅក្នុងប្រទេសកម្ពុជា ដូចជាជនជាតិវៀតណាម ថៃ ឡាវ កូរ៉េ ចិន ឥស្លាម។ល។ ជាជាតិសាសន៍ដទៃទៀត ដែលមិនរាប់ជាជនជាតិដើមភាគតិចក្នុងរបាយការណ៍នេះទេ។ យោងតាមទិន្នន័យជំរឿន ជនជាតិដើមភាគតិចត្រូវបានកំណត់តាមរយៈភាសានិយាយពីកំណើត ដែល ខុសពីភាសាខ្មែរនិងភាសាជាតិសាសន៍ដទៃទៀត។ ដោយឡែក អង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ចកម្ពុជា គ្មានទិន្នន័យអំពីភាសានិយាយពីកំណើត សម្រាប់កំណត់អត្តសញ្ញាណជនជាតិដើមភាគតិច ដូចទិន្នន័យ ជំរឿនទេ។ ក៏ប៉ុន្តែ អង្កេតនេះ បានបំបែកប្រជាជនដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ជា ១) ជនជាតិខ្មែរ ២) ជនជាតិភាគតិចដទៃទៀត (ដូចជាឥស្លាម ចិន ថៃ  វៀតណាម ឡាវ ជាដើម) និង ៣) ជនជាតិ ភាគតិចក្នុងស្រុកដទៃទៀត (Other local ethnic groups)។ ក្នុងន័យនេះ របាយការណ៍បច្ចុប្បន្នភាពនេះ កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចទៅតាមភាសានិយាយពីកំណើត សម្រាប់ទិន្នន័យជំរឿន និងទៅ តាមក្រុមជនជាតិភាគតិចក្នុងស្រុកដទៃទៀត សម្រាប់ទិន្នន័យអង្កេត។

គួរកត់សម្គាល់ថា គ្មានឯកសារឬទិន្នន័យដែលចង្អុលបង្ហាញថា នៅកម្ពុជាសព្វថ្ងៃមានជនជាតិដើមភាគតិច ចំនួនប៉ុន្មានអំបូរពិតប្រាកដទេ។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ២០០៩[៩] បានរៀបរាប់ឈ្មោះចំនួន២៤អំបូរ រួមនឹងពាក្យជនជាតិដើមផ្សេងៗទៀត។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា បានបំបែកប្រជាជនជា៣៤ក្រុម ដោយយោងតាមភាសានិយាយ ពីកំណើតដែលក្នុងនោះមាន ភាសាខ្មែរ ភាសាជនជាតិភាគតិចចំនួន៨ក្រុម ភាសាជនជាតិឥស្លាម ភាសាជនជាតិដើមភាគតិចចំនួន២២ក្រុម ភាសាផ្សេងទៀតចំនួន១ក្រុម និងភាសាមិនបានបញ្ជាក់ចំនួន១ក្រុម។ ដូចនេះ ដោយប្រើទិន្នន័យជំរឿន យើងអាចទាញបានត្រឹមជនជាតិដើមភាគតិចចំនួន ២២អំបូរប៉ុណ្ណោះ។ ឯអំបូរជនជាតិដើមភាគតិចផ្សេងទៀតទំនងជាក្រុមប្រជាជនតូចៗ និងមិនអាចកំណត់អត្តសញ្ញាណបាន ព្រោះអាចស្ថិតនៅក្នុងក្រុមភាសាផ្សេងទៀត ឬក្នុងក្រុមភាសាមិនបានបញ្ជាក់។

---

[៩] ក្រសួងអភិវឌ្ឍន៍ជនបទ

## ២.១. ប្រជាជននិងអំបូរជនជាតិដើមភាគតិច

### ២.១.១. ចំនួនប្រជាជនជនជាតិដើមភាគតិចសរុប និងអត្រាកំណើន

ទិន្នន័យជំរឿនឆ្នាំ២០១៩បង្ហាញថា ជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួន២២អំបូរ ដែលអាចកំណត់អត្តសញ្ញាណបាន និងមានប្រជាជនសរុបចំនួន ១៧២.៩៨០នាក់ ស្មើនឹង១,១១% នៃប្រជាជនកម្ពុជាសរុប (តារាងទី១)[១០]។ ប្រជាជនជនជាតិដើមភាគតិចនៅឆ្នាំ២០១៩ មានចំនួនតិចជាងនៅឆ្នាំ២០០៨ ដោយចំនួន ៦.២១៣នាក់ គឺថយចុះក្នុងអត្រាកំណើនប្រចាំឆ្នាំចំនួន -០,៣២% ក្នុងចន្លោះឆ្នាំនេះ។ គួរកត់សម្គាល់ថា ភាសាកំណើតផ្សេងទៀតដែលជាក្រុមមួយក្នុងភាសានិយាយពីកំណើត ដែលមានប្រជាជនចំនួន៦.១៥១នាក់នៅឆ្នាំ២០០៨ និងចំនួន៧.៤១៣នាក់នៅឆ្នាំ២០១៩ មិនបានរាប់បញ្ចូលជាចំនួនជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍នេះទេ ទាំងនៅឆ្នាំ២០០៨ទាំងនៅឆ្នាំ២០១៩ ដោយសារកង្វះភាពច្បាស់លាស់នៃទិន្នន័យ[១១]។

ការថយចុះនៃចំនួនប្រជាជនជនជាតិដើមភាគតិចនៅកម្ពុជាតាមទិន្នន័យជំរឿន អាចបណ្តាលមកពីកត្តាគួបផ្សំជាច្រើន ដែលយើងត្រូវយកចិត្តទុកដាក់ ជាជាងការសន្និដ្ឋានថាប្រជាជនជនជាតិដើមភាគតិចនៅកម្ពុជាកំពុងបាត់បង់។ ទីមួយ គឺការធ្វើស្វ័យអត្តសញ្ញាណអំពីភាសាកំណើតរបស់ប្រជាជនជនជាតិដើមភាគតិចវ័យក្មេង ដែលកំពុងរស់នៅនិងធ្វើការក្នុងសង្គមធំដែលនៅដាច់ឆ្ងាយពីគ្រួសារនិងសហគមន៍របស់ខ្លួន (ឬរស់នៅរាយប៉ាយ ឬរស់នៅដាច់ឆ្ងាយពីគ្រួសារដោយហេតុផលផ្សេងៗទៀត)។ ទីពីរ គឺការរៀបការជាមួយជនជាតិឬជាតិសាសន៍ផ្សេង ដែលអាចធ្វើឱ្យកូនចៅរបស់ពួកគេផ្លាស់ប្តូរភាសានិយាយពីកំណើត។ ទីបី គឺការអាចបន្តមានសតិអារម្មណ៍ភ័យខ្លាចដោយសារសម្ពាធនិងការគម្រាមកំហែងដែលបន្សល់ទុកតាំងពីជំនាន់ ប៉ុល ពត ដែលកាលនោះក្រុមជនជាតិដើមភាគតិចខ្លះ ភ័យខ្លាចក្នុងការបង្ហាញអត្តសញ្ញាណខ្លួនថាជាជនជាតិដើមភាគតិច។ ទី៤ គឺការម៉ាក់ងាយនិងរើស អើងក្នុងសង្គមរបស់មនុស្សមួយចំនួនតូច ដែលធ្វើឱ្យជនជាតិដើមភាគតិចខ្លះលាក់អត្តសញ្ញាណរបស់ ខ្លួន។ ទី៥ គឺការខុសឆ្គងដែលអាចបណ្តាលមកពីការសន្មតអំពីភាសាកំណើតនាពេលប្រមូលទិន្នន័យ ដោយយោងតាមអត្តសញ្ញាណប័ណ្ណ

---

[១០] យោងតាមទិន្នន័យឃុំសង្កាត់ ជនជាតិដើមភាគតិចជាសរុបមានចំនួន ២៦៤៥៣១នាក់ (៦៤៤៨៣គ្រួសារ) នៅឆ្នាំ២០១៩ និងចំនួន២៥២៣៣៧នាក់នៅឆ្នាំ២០១៤។ ក្នុងចន្លោះពេល៥ឆ្នាំនេះ ប្រជាជនជនជាតិដើមភាគតិចបានកើនឡើងតិចតួចក្នុងអត្រាកំណើនប្រចាំឆ្នាំស្មើនឹង០,៩៤%។

[១១] បើបញ្ចូលភាសាកំណើតផ្សេងទៀតថាជាភាសានិយាយពីកំណើតរបស់ជនជាតិដើមភាគតិច នោះជនជាតិដើមភាគតិចមានចំនួន ១៨៧.៤៥១នាក់នៅឆ្នាំ២០០៨ និង១៨២.៤១២នាក់នៅឆ្នាំ២០១៩។

ពលរដ្ឋដែលជាជនជាតិខ្មែរ ឬដែលអាចបណ្តាលមកពីវិធីសាស្ត្រ ប្រមូលទិន្នន័យ ដែលអ្នកសម្ភាសន៍មិនមែនជនជាតិដើមភាគតិច។

តារាងទី ១. ចំនួនប្រជាជននិងអត្រាកំណើនប្រចាំឆ្នាំ ២០០៨-២០១៩

| | ចំនួនប្រជាជន | | អត្រាកំណើនប្រចាំឆ្នាំ |
|---|---|---|---|
| | **២០០៨** | **២០១៩** | **២០០៨-២០១៩** |
| កម្ពុជាសរុប | ១៣.៣៩៥.៦៨២ | ១៥.៥៥២.២១១ | ១,៣៦ |
| ជនជាតិដើមភាគតិច | ១៧៩.១៩៣ | ១៧២.៩៨០ | -០,៣២ |
| ភាគរយជនជាតិដើមភាគតិច | ១,៣៤% | ១,១១% | |
| ចំនួនអំបូរជនជាតិដើមភាគតិច | ២២ | ២២ | |

### ២.១.២. អំបូរនិងប្រជាជនតាមអំបូរនីមួយៗ និងបម្រែបម្រួល ២០០៨-២០១៩

ជនជាតិដើមភាគតិចមាន២២អំបូរ និងមានចំនួននិងបម្រែបម្រួលប្រជាជនខុសៗគ្នាយ៉ាងច្រើន ពីអំបូរមួយទៅអំបូរមួយទៀត ដោយអំបូរខ្លះមានប្រជាជនច្រើន អំបូរខ្លះមានប្រជាជនតិច អំបូរខ្លះមានប្រជាជនកើន និងអំបូរខ្លះទៀតមានប្រជាជនថយចុះគួរឱ្យកត់សម្គាល់។ តារាងទី២ បង្ហាញពីចំនួនប្រជាជនតាមអំបូរនីមួយៗ នៅឆ្នាំ ២០០៨ និងឆ្នាំ២០១៩ និងបម្រែបម្រួលនៃចំនួនប្រជាជននៃអំបូរនីមួយៗ រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩៖

- យោងតាមចំនួនប្រជាជនជនជាតិដើមភាគតិចនៅឆ្នាំ២០១៩ (តារាងទី២) អំបូរធំៗនៃជនជាតិដើមភាគតិចដែលមានប្រជាជនចាប់ពីមួយម៉ឺននាក់ឡើងទៅ (១០.០០០នាក់ឡើង) មានចំនួន៦អំបូរ គឺ ១) ជនជាតិពូនងដែលមានប្រជាជនសរុបចំនួន ៣៦.៥៨៥នាក់, ២) ជនជាតិទំពួនដែលមានប្រជាជនសរុបចំនួន ៣៦.៣៧៣នាក់, ៣) ជនជាតិចារ៉ាយដែលមានប្រជាជនសរុបចំនួន ២៦.៩២២នាក់, ៤) ជនជាតិគ្រឹងដែលមានប្រជាជនសរុបចំនួន ២១.៤៥៣នាក់, ៥) ជនជាតិកួយដែលមានប្រជាជនសរុបចំនួន១៦.៧៦២នាក់, និង ៦) ជនជាតិព្រៅដែលមានប្រជាជនសរុបចំនួន១០.០៨៦នាក់។ ប្រជាជននៃអំបូរទាំង៦ មានចំនួនសរុប ១៤៨.១៨១នាក់ ស្មើនឹង ៨៥,៧% នៃប្រជាជនជនជាតិដើមភាគតិចទាំងអស់។
- អំបូរជនជាតិដើមភាគតិច ដែលមានប្រជាជនចាប់ពីមួយពាន់នាក់ដល់ក្រោមមួយម៉ឺននាក់ (១.០០០ - ៩.៩៩៩នាក់) មានចំនួន៥អំបូរ គឺ ១) ជនជាតិកាវ៉ែត, ២) ជនជាតិក្រោល,

៣) ជនជាតិស្ទៀង, ៤) ជនជាតិថ្មូន, និង ៥) ជនជាតិលុន ដែលមានប្រជាជនសរុបចំនួន ២០.៣០៤នាក់ ស្មើនឹង១១,៧% នៃប្រជាជនជនជាតិដើមភាគតិចទាំងអស់នៅឆ្នាំ ២០១៩។

- អំបូរជនជាតិដើមភាគតិច ដែលមានប្រជាជនចាប់ពីប្រាំរយនាក់ដល់ក្រោមមួយពាន់នាក់ (៥០០-៩៩៩នាក់) មានចំនួន៤អំបូរ គឺ ១) ជនជាតិមិល, ២) ជនជាតិព័រ, ៣) ជនជាតិស្អួយ, និង ៤) ជនជាតិរអង ដែលមានប្រជាជនសរុបចំនួន ៣.២៧៦នាក់ ស្មើនឹង ១,៩% នៃប្រជាជនជនជាតិដើមភាគតិចទាំងអស់នៅឆ្នាំ២០១៩។
- អំបូរតូចៗ ដែលមានប្រជាជនចាប់ពី១០០ដល់ក្រោម៥០០នាក់ មានចំនួន៥អំបូរ គឺ ១) ជនជាតិគ្លឹង, ២) ជនជាតិកាជ្រុក, ៣) ជនជាតិស្អូច, ៤) ជនជាតិរដែ, និង ៥) ជនជាតិខោញ ដែលមានប្រជាជនសរុបចំនួន ១.១៧៦នាក់ ស្មើនឹង ០,៧% ប្រជាជនជនជាតិដើមភាគតិចទាំងអស់នៅឆ្នាំ២០១៩។
- អំបូរជនជាតិដើមភាគតិចចំនួន២ ដែលមានប្រជាជនតិចជាងគេបំផុត គឺជនជាតិមន (ចំនួន ២៧នាក់) និងជនជាតិកាចក់ (ចំនួន១៦នាក់)។

ជាសរុប ប្រជាជនជនជាតិដើមភាគតិចថយចុះ ៣,៥% (ចំនួន ៦.២១៣នាក់) ក្នុងអំឡុងពេល ១១ឆ្នាំ ចាប់ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៩។ ក៏ប៉ុន្តែការប្រែប្រួលចំនួនប្រជាជនក្នុងអំឡុងពេល១១ឆ្នាំនេះ ខុសៗគ្នាគួរឱ្យកត់សម្គាល់ ពីអំបូរមួយទៅអំបូរមួយ ដោយអំបូរខ្លះកើនខ្លាំង ឯអំបូរខ្លះទៀតថយចុះខ្លាំង។ ជារួម ១១អំបូរមានចំនួនប្រជាជនកើន និង១១អំបូរទៀតមានចំនួនប្រជាជនថយ។

**អំបូរដែលមានប្រជាជនកើន មាន៖**

- អំបូរធំៗ (ប្រជាជនពី១០.០០០នាក់ឡើងទៅ) ដែលមានប្រជាជនកើនឡើង មានទំពួន (កើន១៧,៣%), ព្រៅ (កើន១១,៨%), គ្រឹង (កើន៧,៣%), និងចារ៉ាយ (កើន ២,២%)។
- អំបូរមធ្យម (ប្រជាជនពី៥០០នាក់ ដល់៩.៩៩៩នាក់) ដែលមានប្រជាជនកើនឡើង មានលុន (កើន២១៥,៩%) ថ្មូន (កើន៣៤,៦%) និងក្រោល (កើន៣៤%)។

**អំបូរដែលមានប្រជាជនថយចុះ មាន៖**

- អំបូរធំៗដែលមានប្រជាជនថយចុះ គឺកួយ (ថយចុះ ៤១,៤%) និងពូនង (ថយចុះ២,៥%)។
- អំបូរមធ្យមដែលមានប្រជាជនថយចុះ មាន ស្ទៀង (ថយចុះ២៥%) មិល (ថយចុះ៤២%) ព័រ (ថយចុះ៤៨,៣%) ស្អួយ (ថយចុះ ៩,៦%) និងរអង (ថយចុះ៦៨,៧%)។

តារាងទី ២.  ចំនួនប្រជាជននៃអំបូរនីមួយៗនិងបម្រែបម្រួលៈ ឆ្នាំ២០០៨និង២០១៩

| អំបូរទាំង២២ នៃ ជនជាតិដើមភាគតិច | | ចំនួនប្រជាជន | | របាយភាគរយ | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | | ២០០៨ | ២០១៩ | ឆ្នាំ២០១៩ | ចំនួន | ភាគរយ |
| ១ | ពូនង | ៣៧.៥០៧ | ៣៦.៥៨៥ | ២១,១% | -៩២២ | -២,៥ |
| ២ | ទំពួន | ៣១.០១៣ | ៣៦.៣៧៣ | ២១,០% | ៥.៣៦០ | ១៧,៣ |
| ៣ | ចារ៉ាយ | ២៦.៣៣៥ | ២៦.៩២២ | ១៥,៦% | ៥៨៧ | ២,២ |
| ៤ | គ្រឹង | ១៩.៩៨៨ | ២១.៤៥៣ | ១២,៤% | ១.៤៦៥ | ៧,៣ |
| ៥ | កួយ | ២៨.៦១២ | ១៦.៧៦២ | ៩,៧% | -១១.៨៥០ | -៤១,៤ |
| ៦ | ព្រៅ | ៩.០២៥ | ១០.០៨៦ | ៥,៨% | ១.០៦១ | ១១,៨ |
| ៧ | កាវ៉ែត | ៦.២១៨ | ៧.៥៦៩ | ៤,៤% | ១.៣៥១ | ២១,៧ |
| ៨ | ក្រោល | ៤.២០២ | ៥.៦៣០ | ៣,៣% | ១.៤២៨ | ៣៤,០ |
| ៩ | ស្ទៀង | ៦.៥៤១ | ៤.៩០៨ | ២,៨% | -១.៦៣៣ | -២៥,០ |
| ១០ | ថ្មូន | ៨៦៥ | ១.១៦៤ | ០,៧% | ២៩៩ | ៣៤,៦ |
| ១១ | លុន | ៣២៧ | ១.០៣៣ | ០,៦% | ៧០៦ | ២១៥,៩ |
| ១២ | មិល | ១.៦៩៧ | ៩៨៤ | ០,៦% | -៧១៣ | -៤២,០ |
| ១៣ | ព័រ | ១.៨២៧ | ៩៤៤ | ០,៥% | -៨៨៣ | -៤៨,៣ |
| ១៤ | ស្មួយ | ៨៥៧ | ៧៧៥ | ០,៤% | -៨២ | -៩,៦ |
| ១៥ | រអង | ១.៨៣១ | ៥៧៣ | ០,៣% | -១.២៥៨ | -៦៨,៧ |
| ១៦ | ក្លឹង | ៧០២ | ៤១៣ | ០,២% | -២៨៩ | -៤១,២ |
| ១៧ | កាជ្រូក | ៤០៨ | ២៦៦ | ០,២% | -១៤២ | -៣៤,៨ |
| ១៨ | ស្អួច | ៤៤៥ | ២០៩ | ០,១% | -២៣៦ | -៥៣,០ |
| ១៩ | រដែ | ២១ | ១៧៩ | ០,១% | ១៥៨ | ៧៥២,៤ |
| ២០ | ខោញ | ៧៤៣ | ១០៩ | ០,១% | -៦៣៤ | -៨៥,៣ |
| ២១ | មន | ១៩ | ២៧ | ០,០% | ៨ | ៤២,១ |
| ២២ | កាចក់ | ១០ | ១៦ | ០,០% | ៦ | ៦០,០ |
| | ចំនួនសរុប | ១៧៩.១៩៣ | ១៧២.៩៨០ | ១០០,០% | -៦.២១៣ | -៣,៥ |

### ២.១.៣. ជនជាតិដើមភាគតិចនិងទីកន្លែងរស់នៅ

#### ក. ជនជាតិដើមភាគតិចតាមរាជធានីខេត្ត

ជនជាតិដើមភាគតិចនៅកម្ពុជាច្រើនរស់នៅក្នុងខេត្តនៃតំបន់ភាគឧត្តរ ឦសាន និងបូព៌ានៃប្រទេសកម្ពុជា។ ថ្វីបើបច្ចុប្បន្នគេឃើញមានជនជាតិដើមភាគតិចរស់ស្ទើរគ្រប់រាជធានីខេត្ត ក៏ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចបន្តរស់នៅក្នុងតំបន់ខាងលើដដែល។

បើគិតតាមរបាយភាគរយជនជាតិដើមភាគតិចតាមរាជធានីខេត្ត កូឡោនទី៥នៃតារាងទី៣ខាងក្រោមបង្ហាញថា មានខេត្តចំនួន ៦ ដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ ដែលជាសរុបមានជនជាតិដើមភាគតិចចំនួន ៩៤% រស់នៅក្នុងខេត្តទាំង៦។ រាជធានីភ្នំពេញមានជនជាតិដើមភាគតិចប្រហែល ១% និងបណ្តាខេត្តឯទៀតចំនួន១៨ខេត្តមានជនជាតិដើមភាគតិចចំនួនប្រហែល ៥%។ ខេត្តទាំង៦ ដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ គឺ៖

- ខេត្តរតនគិរី (៥៤,៤៦% នៃជនជាតិដើមភាគតិចទាំងអស់)
- ខេត្តមណ្ឌលគិរី (១៨,០០% នៃជនជាតិដើមភាគតិចទាំងអស់)
- ខេត្តក្រចេះ (១០,៤៤%នៃជនជាតិដើមភាគតិចទាំងអស់)
- ខេត្តព្រះវិហារ (៥,៣៧%នៃជនជាតិដើមភាគតិចទាំងអស់)
- ខេត្តស្ទឹងត្រែង (៣,៤៧% នៃជនជាតិដើមភាគតិចទាំងអស់) និង
- ខេត្តកំពង់ធំ (២,៣៤% នៃជនជាតិដើមភាគតិចទាំងអស់)។

តារាងទី៣ក៏បានបង្ហាញពីភាគរយប្រជាជនជនជាតិដើមភាគតិច ធៀបនឹងប្រជាជនក្នុងរាជធានីខេត្តនីមួយៗ (កូឡោនទី៤) ដែលខេត្តដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ គឺ៖

- ខេត្តរតនគិរី (៤៣,៣២% នៃប្រជាជនខេត្តទាំងអស់)
- ខេត្តមណ្ឌលគិរី (៣៧,៧៦% នៃប្រជាជនខេត្តទាំងអស់)
- ខេត្តក្រចេះ (៤៣,៣២% នៃប្រជាជនខេត្តទាំងអស់)
- ខេត្តព្រះវិហារ (៣,៦៤% នៃប្រជាជនខេត្តទាំងអស់)
- ខេត្តស្ទឹងត្រែង (៣,៦៣% នៃប្រជាជនខេត្តទាំងអស់) និង
- ខេត្តកំពង់ធំ (០,៥៩% នៃប្រជាជនខេត្តទាំងអស់)។

តារាងទី ៣. ជនជាតិដើមភាគតិចតាមរាជធានីខេត្ត

| រាជធានី/ខេត្ត (១) | | ចំនួនប្រជាជនកម្ពុជាសរុប (២) | ជនជាតិដើមភាគតិច | | |
|---|---|---|---|---|---|
| | | | ចំនួន (៣) | ភាគរយក្នុងខេត្ត (៤) | ភាគរយតាមខេត្ត (៥) |
| ១ | បន្ទាយមានជ័យ | ៨៦១.៨៨៣ | ១.១០៧ | ០,១៣% | ០,៦៤% |
| ២ | បាត់ដំបង | ៩៩៧.១៦៩ | ៦០៩ | ០,០៦% | ០,៣៥% |
| ៣ | កំពង់ចាម | ៨៩៩.៧៩១ | ៧៤៥ | ០,០៨% | ០,៤៣% |
| ៤ | កំពង់ឆ្នាំង | ៥២៧.០២៧ | ២២០ | ០,០៤% | ០,១៣% |
| ៥ | កំពង់ស្ពឺ | ៨៧៧.៥២៣ | ១.១៣២ | ០,១៣% | ០,៦៥% |
| ៦ | កំពង់ធំ | ៦៨១.៥៤៩ | ៤.០៤៣ | ០,៥៩% | ២,៣៤% |
| ៧ | កំពត | ៥៩៣.៨២៩ | ៣២៤ | ០,០៥% | ០,១៩% |
| ៨ | កណ្ដាល | ១.២០១.៥៨១ | ៧៦១ | ០,០៦% | ០,៤៤% |
| ៩ | កោះកុង | ១២៥.៩០២ | ១៨០ | ០,១៤% | ០,១០% |
| ១០ | ក្រចេះ | ៣៧៤.៧៥៥ | ១៨.០៦៧ | ៤,៨២% | ១០,៤៤% |
| ១១ | មណ្ឌលគិរី | ៩២.២១៣ | ៣១.១២៨ | ៣៣,៧៦% | ១៨,០០% |
| ១២ | ភ្នំពេញ | ២.២៨១.៩៥១ | ១.៧២២ | ០,០៨% | ១,០០% |
| ១៣ | ព្រះវិហារ | ២៥៤.៨២៧ | ៩.២៨៦ | ៣,៦៤% | ៥,៣៧% |
| ១៤ | ព្រៃវែង | ១.០៥៧.៧២០ | ៣៥៦ | ០,០៣% | ០,២១% |
| ១៥ | ពោធិ៍សាត់ | ៤១៩.៩៥២ | ៣៧៥ | ០,០៩% | ០,២២% |
| ១៦ | រតនគិរី | ២១៧.៤៥៣ | ៩៤.២០៤ | ៤៣,៣២% | ៥៤,៤៦% |
| ១៧ | សៀមរាប | ១.០១៤.២៣៤ | ៦៤៦ | ០,០៦% | ០,៣៧% |
| ១៨ | ព្រះសីហនុ | ៣១០.០៧២ | ១២២ | ០,០៤% | ០,០៧% |
| ១៩ | ស្ទឹងត្រែង | ១៦៥.៧១៣ | ៦.០១០ | ៣,៦៣% | ៣,៤៧% |
| ២០ | ស្វាយរៀង | ៥២៥.៤៩៧ | ២៨២ | ០,០៥% | ០,១៦% |
| ២១ | តាកែវ | ៩០០.៩១៤ | ៧៣៦ | ០,០៨% | ០,៤៣% |
| ២២ | ឧត្ដរមានជ័យ | ២៧៦.០៣៨ | ៤៨៧ | ០,១៨% | ០,២៨% |
| ២៣ | កែប | ៤២.៦៦៥ | ១៩ | ០,០៤% | ០,០១% |
| ២៤ | ប៉ៃលិន | ៧៥.១១២ | ១៤ | ០,០២% | ០,០១% |
| ២៥ | ត្បូងឃ្មុំ | ៧៧៦.៨៤១ | ៤០៥ | ០,០៥% | ០,២៣% |
| សរុប | | ១៥.៥៥២.២១១ | ១៧២.៩៨០ | ១,១១% | ១០០,០០% |

## ខ. រាជធានីខេត្តដែលមានជនជាតិដើមភាគ ចាប់ពី១០០០នាក់ឡើងទៅក្នុងអំបូរនីមួយៗ

ក្នុងចំណោមខេត្តទាំង៦ដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ (តារាងទី៤) អំបូរជនជាតិដើមភាគតិចដែលមានប្រជាជនចាប់ពី១.០០០នាក់ឡើងទៅ[១២] មានចំនួន៩អំបូរ គឺ៖

- ជនជាតិទំពួន ចារ៉ាយ គ្រឹង ព្រៅ និងកាវ៉ែត នៅក្នុងខេត្តរតនគិរី
- ជនជាតិពូនង និងក្រោល ក្នុងខេត្តមណ្ឌលគិរី
- ជនជាតិពូនង ក្រោល ស្ទៀង និងកួយ នៅក្នុងខេត្តក្រចេះ
- ជនជាតិកួយ នៅក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ
- ជនជាតិកាវ៉ែត នៅក្នុងខេត្តស្ទឹងត្រែង

តារាងទី ៤. អំបូរធំៗដែលមានប្រជាជន១.០០០នាក់ឡើងក្នុងអំបូរនីមួយៗ នៅក្នុងខេត្តទាំង៦

| ខេត្ត | ឈ្មោះអំបូរជនជាតិដើមភាគតិច | | | | | ចំនួនអំបូរ |
|---|---|---|---|---|---|---|
| រតនគិរី | ទំពួន | ចារ៉ាយ | គ្រឹង | ព្រៅ | កាវ៉ែត | ៥ |
| មណ្ឌលគិរី | ពូនង | ក្រោល | | | | ២ |
| ក្រចេះ | ពូនង | ក្រោល | ស្ទៀង | កួយ | | ៤ |
| ព្រះវិហារ | កួយ | | | | | ១ |
| ស្ទឹងត្រែង | កាវ៉ែត | | | | | ១ |
| កំពង់ធំ | កួយ | | | | | ១ |
| សរុបចំនួន ៩ អំបូរ | | | | | | |

## គ. រាជធានីខេត្តដែលមានជនជាតិដើមភាគ ១០០-៩៩៩នាក់ក្នុងអំបូរនីមួយៗ

ក្រៅពីអំបូរធំៗនៅក្នុងខេត្តទាំង៦ខាងលើ ក៏មានរាជធានីខេត្តចំនួន២២ ដែលមានប្រជាជនជនជាតិដើមភាគតិចរស់នៅ ពី១០០នាក់ដល់៩៩៩នាក់ក្នុងអំបូរនីមួយ (តារាងទី៥ខាងក្រោម)។ ជារួមគេសង្កេតឃើញជនជាតិចារ៉ាយច្រើនរស់នៅរាយប៉ាយក្នុងបណ្តារាជធានីខេត្តជាច្រើន ច្រើនជាងអំបូរជនជាតិដើមភាគតិចដទៃទៀតទាំងអស់។ ជនជាតិដើមភាគតិចដទៃទៀត ច្រើនរស់នៅផ្តុំក្នុងខេត្តតែមួយ ឬពីរ ឬបី

[១២] ដូចបានបញ្ជាក់រួចមកហើយ ចំនួនអំបូរ ចំនួនគ្រួសារ និងចំនួនប្រជាជន គឺខុសៗគ្នារវាងទិន្នន័យឃុំសង្កាត់និងទិន្នន័យជំរឿន (សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធទី៦ដល់ទី១១)។ ទិន្នន័យឃុំសង្កាត់បង្ហាញជនជាតិដើមភាគតិចចំនួន១៩អំបូរ ឯទិន្នន័យជំរឿនចំនួន២២អំបូរ។

ប៉ុណ្ណោះ ដូចជាជនជាតិស្ទួយរស់នៅតែក្នុងខេត្តកំពង់ស្ពឺ ជនជាតិព្រៅនៅក្នុងខេត្តស្ទឹងត្រែង ជនជាតិរអង និងការវែតនៅរាជធានីភ្នំពេញ ជនជាតិថ្មូននិងមិលនៅក្នុងខេត្តក្រចេះ ជនជាតិព័រនៅក្នុងខេត្តព្រះវិហារនិង ពោធិ៍សាត់ ជនជាតិលុននៅក្នុងខេត្តរតនគិរីនិងស្ទឹងត្រែង និងជនជាតិកួយនៅក្នុងខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី និងស្ទឹងត្រែង ជាដើម។

តារាងទី ៥. ឈ្មោះអំបូរដែលមានប្រជាជន១០០-៩៩៩នាក់ក្នុងអំបូរនីមួយៗ នៅក្នុងរាជធានីខេត្ត

| ខេត្ត | | អំបូរជនជាតិដើមភាគតិច | ចំនួនអំបូរ |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | ចារ៉ាយ កួយ | ២ |
| ២ | បាត់ដំបង | ចារ៉ាយ | ១ |
| ៣ | កំពង់ចាម | ចារ៉ាយ | ១ |
| ៤ | កំពងឆ្នាំង | ចារ៉ាយ | ១ |
| ៥ | កំពង់ស្ពឺ | ចារ៉ាយ ស្ទួយ | ២ |
| ៦ | កំពង់ធំ | ចារ៉ាយ | ១ |
| ៧ | កំពត | ចារ៉ាយ | ១ |
| ៨ | កណ្តាល | ចារ៉ាយ | ១ |
| ៩ | កោះកុង | ក្រោល | ១ |
| ១០ | ក្រចេះ | ថ្មូន មិល | ២ |
| ១១ | មណ្ឌលគិរី | ស្មៀង | ១ |
| ១២ | ភ្នំពេញ | ចារ៉ាយ ការ៉ែត ពូនង ស្មៀង រអង | ៥ |
| ១៣ | ព្រះវិហារ | ព័រ | ១ |
| ១៤ | ព្រៃវែង | ចារ៉ាយ | ១ |
| ១៥ | ពោធិ៍សាត់ | ព័រ | ១ |
| ១៦ | រតនគិរី | កួយ លុន ពូនង | ៣ |
| ១៧ | សៀមរាប | ចារ៉ាយ | ១ |
| ១៨ | ស្ទឹងត្រែង | កួយ គ្រឹង លុន ពូនង ព្រៅ | ៥ |
| ១៩ | ស្វាយរៀង | ចារ៉ាយ | ១ |
| ២០ | តាកែវ | ចារ៉ាយ | ១ |
| ២១ | ឧត្តរមានជ័យ | កួយ | ១ |
| ២២ | ត្បូងឃ្មុំ | ចារ៉ាយ | ១ |

### ២.១.៤. រាជធានីខេត្តចំនួន៣ ដែលអំបូរជនជាតិដើមភាគតិចនីមួយៗរស់នៅច្រើនជាងគេ

ការរស់នៅផ្តុំក្នុងកន្លែងមួយឬរស់នៅរាយប៉ាយតាមទីកន្លែងជាច្រើនផ្សេងៗគ្នា អាចចង្អុលបង្ហាញអំពីការបន្តប្រតិបត្តិប្រពៃណីទំនៀមទម្លាប់ពីមុន ឬអំពីកម្រិតនៃសមាហរណកម្មទៅក្នុងសង្គមតាមរយៈការធ្វើទេសន្តរប្រវេសន៍ដោយហេតុផលផ្សេងៗ ដូចជាការសិក្សា ការងារ ឬការរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិដទៃជាដើម។ តារាងខាងក្រោមបង្ហាញពីកម្រិតនៃការរស់នៅផ្តុំគ្នានៃអំបូរជនជាតិដើមភាគតិចនីមួយៗក្នុងរាជធានីខេត្តចំនួន៣ដែលមានចំនួនប្រជាជនតាមអំបូរនីមួយៗច្រើនជាងគេ ដើម្បីពិនិត្យមើលថា តើអំបូរជនជាតិដើមភាគតិចនីមួយៗច្រើនរស់នៅក្នុងរាជធានីខេត្តណាខ្លះ។

ការពណ៌នាខាងក្រោម ផ្តោតតែលើជនជាតិដើមភាគតិចចំនួន១៥អំបូរដែលមានប្រជាជនច្រើនជាងគេ និងរាជធានី ខេត្តចំនួន៣ ដែលមានចំនួនជនជាតិដើមភាគតិចរស់នៅច្រើនប៉ុណ្ណោះ សម្រាប់អំបូរនីមួយៗ។ រីឯអំបូរផ្សេងទៀតចំនួន៧ មានបង្ហាញក្នុងតារាងទី៦ខាងក្រោម គឺជាអំបូរដែលមានចំនួនប្រជាជនតិច និងច្រើនរស់នៅរាយប៉ាយក្នុងរាជធានី ខេត្ត ជាច្រើន។ អំបូរទាំង១៥ គឺៈ

១. ជនជាតិពូនង ដែលមានចំនួន ២១,១% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្ត មណ្ឌលគិរី (៧៩%) ខេត្តក្រចេះ (១៥,៦%) និងខេត្តរតនគិរី (២,៥%)។ ជាសរុប ៩៧,២% នៃ ជនជាតិពូនង រស់នៅក្នុងខេត្តទាំងបីនេះ។

២. ជនជាតិទំពួន ដែលមានចំនួន ២១% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅតែក្នុងខេត្តរតនគិរីមួយប៉ុណ្ណោះ (៩៩%) និងមានតិចតួចនៅក្នុងខេត្តមណ្ឌលគិរី (០,២%) និងខេត្តកណ្តាល (០,១%)។

៣. ជនជាតិចារ៉ាយ ដែលមានប្រមាណ ១៥,៦% នៃជនជាតិដើមភាគតិចទាំងអស់ និងដែលរស់នៅរាយប៉ាយក្នុងរាជធានីខេត្តជាច្រើន មានប្រជាជនច្រើនលើសលប់រស់នៅក្នុងខេត្តរតនគិរី (៨៥,២%) និងមានតិចតួចរស់នៅរាជធានីភ្នំពេញ (ចំនួន១,៩%) និងខេត្តបន្ទាយមានជ័យ (ចំនួន១,៩%)។

៤. ជនជាតិគ្រឹង ដែលមានចំនួន ១២,៤% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តតែមួយប៉ុណ្ណោះ គឺខេត្តរតនគិរី (៩៨,៧%) បន្ទាប់មកគឺខេត្តស្ទឹងត្រែងដែលមានចំនួន ០,៦% និងខេត្ត បាត់ដំបងដែលមានចំនួន០,២% ។

៥. ជនជាតិកួយ ដែលមានចំនួនជិត ១០% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តបី គឺខេត្តព្រះវិហារចំនួន៥១,១% ខេត្តកំពង់ធំចំនួន២១,២% និងខេត្តក្រចេះចំនួន ១៧,៨%។ ជាសរុប ៩០,១% នៃជនជាតិកួយ រស់នៅក្នុងខេត្តទាំងបីនេះ។

៦. ជនជាតិព្រៅ ដែលមានចំនួនជិត ៦% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តរតនគិរី (៩៤%) ខេត្តស្ទឹងត្រែង (៣,៥%) និងរាជធានីភ្នំពេញ (០,៤%)។

៧. ជនជាតិការ៉ែត ដែលមានចំនួន ៤,៤% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តចំនួនពីរ គឺខេត្តស្ទឹងត្រែង (៤៩,៨%) និងខេត្តរតនគិរី (៣៧,៤%)។ រីឯរាជធានីភ្នំពេញ ជាខេត្តទី៣ដែលជនជាតិការ៉ែតរស់នៅ ក្នុងចំនួន៤,២%។

៨. ជនជាតិក្រោល ដែលមានចំនួន ៣,៣% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តចំនួនពីរ គឺខេត្តស្ទឹងត្រែង (៤៩,៨%) និងខេត្តរតនគិរី (៣៧,៤%)។ ឯខេត្តទី៣ គឺខេត្តកោះកុង ដែលមានជនជាតិក្រោលចំនួន ១,៩% រស់នៅ។

៩. ជនជាតិស្ទៀង ដែលមានចំនួន ២,៨% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តចំនួនពីរ គឺខេត្តក្រចេះ (៧៣,២%) និងខេត្តមណ្ឌលគិរី (១០,៥%)។ ឯខេត្តទី៣ គឺរាជធានីភ្នំពេញ ដែលមានស្ទៀងចំនួន២,១%រស់នៅ។

១០. ជនជាតិថ្មូន ដែលមានចំនួន ០,៧% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅតែក្នុងខេត្តក្រចេះ (ប្រមាណ៨៤%) ខេត្តមណ្ឌលគិរី (៤,៦%) និងរាជធានីភ្នំពេញ (១,៨%) ដែលសរុបក្នុង ខេត្តទាំង៣ មានចំនួន ៩០,៥% នៃជនជាតិថ្មូនទាំងអស់។

១១. ជនជាតិលុន ដែលមានចំនួន ០,៦% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅតែក្នុងខេត្តរតនគិរី (៦១%) ខេត្តស្ទឹងត្រែង (៣០,៨%) និងខេត្តកំពង់ចាម (១%) ដែលសរុបក្នុងខេត្តទាំង៣ មានចំនួន ៩២,៧% នៃជនជាតិលុនទាំងអស់។

១២. ជនជាតិមិល ដែលមានចំនួន ០,៦% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តក្រចេះ (៧៥,៤%) និងមានខ្លះៗនៅខេត្តត្បូងឃ្មុំ (៥,៤%) និងរាជធានីភ្នំពេញ (៤,៧%) ដែលសរុបក្នុងខេត្តទាំង៣ មានចំនួន ៨៥,៥% នៃជនជាតិមិលទាំងអស់។

១៣. ជនជាតិព័រ ដែលមានចំនួន ០,៥% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងខេត្តព្រះវិហារ (៥៧,២%) ខេត្តពោធិ៍សាត់ (២១,៩%) និងខេត្តបាត់ដំបង (៧,៨%) ដែលសរុបក្នុងខេត្តទាំង៣ មានចំនួន ៨៧% នៃជនជាតិព័រទាំងអស់។

១៤. ជនជាតិស្ទួយ ដែលមានចំនួន ០,៤% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅតែក្នុងខេត្តកំពង់ស្ពឺ (ប្រមាណ៩០%) រាជធានីភ្នំពេញ (ជិត៣%) និងខេត្តបាត់ដំបង (ជិត២%) ដែលសរុបក្នុងខេត្តទាំង៣ មានចំនួនជិត ៩៥% នៃជនជាតិស្ទួយទាំងអស់។

១៥. ជនជាតិរអង ដែលមានចំនួន ០,៣% នៃជនជាតិដើមភាគតិចទាំងអស់ ច្រើនរស់នៅក្នុងរាជធានី ខេត្តជាច្រើន ដែលក្នុងរាជធានីខេត្តចំនួនបីដែលមានជនជាតិនេះច្រើនជាងគេ មានចំនួនសរុបត្រឹម តែ៤០,៥%ប៉ុណ្ណោះនៃជនជាតិរអងទាំងអស់ គឺនៅរាជធានីភ្នំពេញចំនួន១៨,២% ខេត្តតាកែវចំនួន១២,៤% និងខេត្តកំពង់ចាមចំនួនជិត ១០%។

តារាងទី ៦.  រាជធានីខេត្តចំនួនបី ដែលជនជាតិដើមភាគតិចអំបូរនីមួយៗរស់នៅច្រើនជាងគេ

| | ខេត្តបីដែលជនជាតិដើមភាគតិចរស់នៅច្រើនតាមអំបូរនីមួយៗ | | | សរុបខេត្តទាំង៣ | | ភាគរយក្នុងខេត្តនីមួយៗ | | |
|---|---|---|---|---|---|---|---|---|
| | ខេត្តទី១ | ខេត្តទី២ | ខេត្តទី៣ | ចំនួន | ភាគរយ | ខេត្តទី១ | ខេត្តទី២ | ខេត្តទី៣ |
| ពូនង | មណ្ឌលគិរី (២៨.៩២០) | ក្រចេះ (៥.៧២២) | រតនគិរី (៩២៤) | ៣៥.៥៦៦ | ៩៧,២ | ៧៩,០ | ១៥,៦ | ២,៥ |
| ទំពួន | រតនគិរី (៣៦.០០២) | មណ្ឌលគិរី (៧៣) | កណ្តាល (៤០) | ៣៦.១១៥ | ៩៩,៣ | ៩៩,០ | ០,២ | ០,១ |
| ចារ៉ាយ | រតនគិរី (២២.៩៣០) | ភ្នំពេញ (៥២១) | បន្ទាយមានជ័យ (៥១៩) | ២៣.៩៧០ | ៨៩,០ | ៨៥,២ | ១,៩ | ១,៩ |
| គ្រឹង | រតនគិរី (២១.១៧០) | ស្ទឹងត្រែង (១២៧) | បាត់ដំបង (៤០) | ២១.៣៣៧ | ៩៩,៥ | ៩៨,៧ | ០,៦ | ០,២ |
| កួយ | ព្រះវិហារ (៨.៥៦១) | កំពង់ធំ (៣.៥៥២) | ក្រចេះ (២.៩៨៩) | ១៥.១០២ | ៩០,១ | ៥១,១ | ២១,២ | ១៧,៨ |
| ព្រៅ | រតនគិរី (៩.៤៨៤) | ស្ទឹងត្រែង (៣៥១) | ភ្នំពេញ (៣៧) | ៩.៨៧២ | ៩៧,៩ | ៩៤,០ | ៣,៥ | ០,៤ |
| កាវ៉ែត | ស្ទឹងត្រែង (៣.៧៦៦) | រតនគិរី (២.៨៣២) | ភ្នំពេញ (៣១៨) | ៦.៩១៦ | ៩១,៤ | ៤៩,៨ | ៣៧,៤ | ៤,២ |
| ក្រោល | ក្រចេះ (៣.៨០១) | មណ្ឌលគិរី (១.៤៥៧) | កោះកុង (១០៨) | ៥.៣៦៦ | ៩៥,៣ | ៦៧,៥ | ២៥,៩ | ១,៩ |
| ស្ទៀង | ក្រចេះ (៣.៥៩២) | មណ្ឌលគិរី (៥១៦) | ភ្នំពេញ (១០២) | ៤.២១០ | ៨៥,៨ | ៧៣,២ | ១០,៥ | ២,១ |
| ថ្មូន | ក្រចេះ (៩៧៩) | មណ្ឌលគិរី (៥៤) | ភ្នំពេញ (២១) | ១.០៥៤ | ៩០,៥ | ៨៤,១ | ៤,៦ | ១,៨ |
| លុន | រតនគិរី (៦៣០) | ស្ទឹងត្រែង (៣១៨) | កំពង់ចាម (១០) | ៩៥៨ | ៩២,៧ | ៦១,០ | ៣០,៨ | ១,០ |
| មិល | ក្រចេះ (៧៤២) | ត្បូងឃ្មុំ (៥៣) | ភ្នំពេញ (៤៦) | ៨៤១ | ៨៥,៥ | ៧៥,៤ | ៥,៤ | ៤,៧ |
| ព័រ | ព្រះវិហារ (៥៤០) | ពោធិ៍សាត់ (២០៧) | បាត់ដំបង (៧៤) | ៨២១ | ៨៧,០ | ៥៧,២ | ២១,៩ | ៧,៨ |
| ស្អួយ | កំពង់ស្ពឺ (៦៩៧) | ភ្នំពេញ (២២) | បាត់ដំបង (១៣) | ៧៣២ | ៩៤,៥ | ៨៩,៩ | ២,៨ | ១,៧ |
| រអង | ភ្នំពេញ (១០៤) | តាកែវ (៧១) | កំពង់ចាម (៥៧) | ២៣២ | ៤០,៥ | ១៨,២ | ១២,៤ | ៩,៩ |

| | ខេត្តបីដែលជនជាតិដើមភាគតិចរស់នៅច្រើនតាមអំបូរនីមួយៗ | | | សរុបខេត្តទាំង៣ | | ភាគរយក្នុងខេត្តនីមួយៗ | | |
|---|---|---|---|---|---|---|---|---|
| | ខេត្តទី១ | ខេត្តទី២ | ខេត្តទី៣ | ចំនួន | ភាគរយ | ខេត្តទី១ | ខេត្តទី២ | ខេត្តទី៣ |
| គ្រឹង | ភ្នំពេញ (៩៤) | តាកែវ (៥០) | រតនគិរី (៣៦) | ១៨០ | ៤៣,៦ | ២២,៨ | ១២,១ | ៨,៧ |
| កាជ្រូក | ភ្នំពេញ (៦០) | កំពង់ស្ពឺ (២៧) | កំពង់ស្ពឺ (២៧) | ១១៤ | ៤២,៩ | ២២,៦ | ១០,២ | ១០,២ |
| ស្អូច | សៀមរាប (៣៣) | ភ្នំពេញ (២៧) | បាត់ដំបង (១៦) | ៧៦ | ៣៦,៤ | ១៥,៨ | ១២,៩ | ៧,៧ |
| រដែ | ភ្នំពេញ (៣០) | កណ្ដាល (២៦) | តាកែវ (១៦) | ៧២ | ៤០,២ | ១៦,៨ | ១៤,៥ | ៨,៩ |
| ខោញ | ភ្នំពេញ (២១) | ក្រចេះ (២០) | កណ្ដាល (១៧) | ៥៨ | ៥៣,២ | ១៩,៣ | ១៨,៣ | ១៥,៦ |
| មន | តាកែវ (៥) | ពោធិ៍សាត់ (៤) | កណ្ដាល (៣) | ១២ | ៤៤,៤ | ១៨,៥ | ១៤,៨ | ១១,១ |
| កាចក់ | ភ្នំពេញ (៦) | កណ្ដាល (៣) | បន្ទាយមានជ័យ (២) | ១១ | ៦៨,៨ | ៣៧,៥ | ១៨,៨ | ១២,៥ |
| សរុប | ១៤២.១៦៧ | ១៦.០៣៣ | ៥.៤១៥ | ១៦៣.៦១៥ | ៩៤,៦ | ៨២,២ | ៩,៣ | ៣,១ |

### ២.១.៥. ចំនួនភូមិដែលមានជនជាតិដើមភាគតិចរស់នៅ

ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការទិន្នន័យ សម្រាប់ការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិចនៅតាមសហគមន៍ ព័ត៌មានអំពីភូមិដែលមានជនជាតិដើមភាគតិចយ៉ាងតិច៥០នាក់រស់នៅ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម (តារាងទី ៧) ដោយយោងតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ២០១៩។ ភូមិដែលមានជនជាតិដើមយ៉ាងតិច៥០នាក់រស់នៅ មានចំនួនសរុប ៣៥៤ភូមិ ដែលស្ថិតក្នុងឃុំសង្កាត់ចំនួន១១៧ ក្នុងស្រុកខ័ណ្ឌចំនួន៤៣ នៃរាជធានីខេត្តចំនួន១៤។ បញ្ជីឈ្មោះ ភូមិ ឃុំសង្កាត់ ស្រុកខ័ណ្ឌ នៃរាជធានីខេត្តដែលមានជនជាតិដើមភាគតិចយ៉ាងតិច១០នាក់រស់នៅ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៧ និងបញ្ជីឈ្មោះភូមិ ឃុំសង្កាត់ ស្រុកខ័ណ្ឌ នៃរាជធានីខេត្តដែលមានជនជាតិដើមភាគតិចយ៉ាងតិច១០គ្រួសាររស់នៅ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៨។

តារាងទី ៧. ចំនួនភូមិនៃរាជធានីខេត្ត ដែលមានជនជាតិដើមភាគតិចចាប់ពី៥០នាក់ឡើងទៅ

| រាជធានីខេត្ត រៀបតាមលំដាប់នៃចំនួនភូមិ | | ចំនួន | | |
|---|---|---|---|---|
| | | ស្រុកខ័ណ្ឌ | ឃុំសង្កាត់ | ភូមិ |
| ១ | រតនគិរី | ៩ | ៤៥ | ១៨៥ |
| ២ | មណ្ឌលគិរី | ៥ | ២០ | ៧២ |
| ៣ | ក្រចេះ | ៤ | ១៦ | ៣៨ |
| ៤ | ព្រះវិហារ | ៥ | ១១ | ១៩ |
| ៥ | ស្ទឹងត្រែង | ៥ | ៩ | ១៥ |
| ៦ | កំពង់ធំ | ៤ | ៥ | ១១ |
| ៧ | កំពង់ស្ពឺ | ១ | ១ | ៣ |
| ៨ | បន្ទាយមានជ័យ | ២ | ២ | ២ |
| ៩ | ឧត្តរមានជ័យ | ១ | ១ | ២ |
| ១០ | ភ្នំពេញ | ២ | ២ | ២ |
| ១១ | ពោធិ៍សាត់ | ២ | ២ | ២ |
| ១២ | បាត់ដំបង | ១ | ១ | ១ |
| ១៣ | កោះកុង | ១ | ១ | ១ |
| ១៤ | សៀមរាប | ១ | ១ | ១ |
| សរុប៖ | ១៤ រាជធានីខេត្ត | ៤៣ ស្រុកខ័ណ្ឌ | ១១៧ ឃុំសង្កាត់ | ៣៥៤ ភូមិ |

## ២.១.៦. ជនជាតិដើមភាគតិចក្នុងខេត្តទាំង១៥នៃគោលនយោបាយជាតិ

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ បានគូសបញ្ជាក់ថា ជនជាតិដើមភាគតិចមានប្រភពដើមកំណើតនៅក្នុងខេត្តចំនួន១៥ក្នុងប្រទេសកម្ពុជា គឺខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ពោធិសាត់ រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ឧត្តរមានជ័យ និងត្បូងឃ្មុំ។ ជារួម ជនជាតិដើមភាគតិចចំនួន១៦៧.៨០១នាក់ ស្មើនឹង ៩៧,០%នៃជនជាតិដើមភាគតិចទាំងអស់ កំពុងរស់នៅក្នុងខេត្តទាំង១៥ខាងលើ នាពេលប្រមូលទិន្នន័យជំរឿនឆ្នាំ២០១៩ និងចំនួន១៥៨.៨៥២នាក់ ស្មើនឹង ៩៤,៧% នៃជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងខេត្តទាំង១៥ បានឆ្លើយថា ខ្លួនកើតនៅក្នុងខេត្តទាំង១៥នេះ នាពេលប្រមូលទិន្នន័យជំរឿន។

ក្រាភិកទី១ខាងក្រោម បង្ហាញពីចំនួននិងភាគរយជនជាតិដើមភាគតិចដែលមានប្រភពកំណើតនៅក្នុងខេត្តដែលខ្លួនកំពុងរស់នៅ គិតតាមខេត្តនីមួយ។

ក្រាភិកទី ១. ចំនួននិងភាគរយជនជាតិដើមភាគដែលមានប្រភពកំណើតក្នុងខេត្តកំពុងរស់នៅ



ខេត្តដែលមានភាគរយជនជាតិដើមភាគតិចដែលមានប្រភពកំណើតនៅក្នុងខេត្តដែលខ្លួនកំពុងរស់នៅច្រើនជាង៩០% គឺខេត្តក្រចេះ (៩៦,៧%), កំពង់ស្ពឺ (៩៥,៥%), រតនគិរី (៩៥,៣%), មណ្ឌលគិរី (៩៥,២%), ព្រះវិហារ (៩៥,០%), ស្ទឹងត្រែង (៩៤,៦%), និងកំពង់ធំ (៩២,៣%)។ រីឯខេត្តដែលមានភាគរយជនជាតិដើមភាគតិចដែលមានប្រភពកំណើតនៅក្នុងខេត្តដែលខ្លួនកំពុងរស់នៅតិចជាងគេ គឺខេត្តឧត្តរមានជ័យ (៤១,៣%), ព្រះសីហនុ (៥៨,២%), បន្ទាយមានជ័យ (៦៣,១%) និងបាត់ដំបង (៦៦.០%)។

តារាងទី៨ បង្ហាញពីអំបូរនិងចំនួនប្រជាជនជនជាតិដើមភាគតិច (ចាប់ពី៥០នាក់ឡើង) ដែលកើតនិងកំពុងរស់នៅក្នុងខេត្តទាំង១៥។ អំបូរធំៗជាងគេដែលមានប្រភពក្នុងខេត្តនីមួយៗ មាន៖

១. កួយនិងចារ៉ាយ នៅបន្ទាយមានជ័យ
២. ចារ៉ាយនិងព័រ នៅបាត់ដំបង
៣. ស្ួយ នៅកំពង់ស្ពឺ
៤. កួយ នៅកំពង់ធំ
៥. ក្រោល នៅកោះកុង
៦. ពូនង ក្រោល ស្ទៀង កួយ ថ្មូន និងមិល នៅក្រចេះ
៧. ពូនង ក្រោល ស្ទៀង ទំពួន និងថ្មូន នៅមណ្ឌលគិរី
៨. កួយនិងព័រ នៅព្រះវិហារ
៩. ព័រ នៅពោធិសាត់
១០. ទំពួន ចារ៉ាយ គ្រឹង ព្រៅ កាវ៉ែត ពូនង លុន និងកួយ នៅរតនគិរី
១១. ចារ៉ាយ នៅសៀមរាប
១២. ស្អូច នៅព្រះសីហនុ[១៣]
១៣. កាវ៉ែត កួយ ពូនង និងលុន នៅស្ទឹងត្រែង
១៤. កួយ នៅឧត្តរមានជ័យ
១៥. ស្ទៀង នៅត្បូងឃ្មុំ[១២]។

---

[១៣] យោងតាមទិន្នន័យឃុំសង្កាត់។ សូមមើលសម្គាល់ខាងក្រោម។

**សម្គាល់៖** អំបូរជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងខេត្តព្រះសីហនុនិងខេត្តត្បូងឃ្មុំ ខុសគ្នារវាងទិន្នន័យជំរឿននិងទិន្នន័យឃុំសង្កាត់ ដូចខាងក្រោម៖

- នៅខេត្តព្រះសីហនុ ទិន្នន័យជំរឿនបង្ហាញថាមានជនជាតិចារ៉ាយ ឯទិន្នន័យឃុំសង្កាត់បង្ហាញថាមានតែជនជាតិស្អូចប៉ុណ្ណោះ។ យោងតាមទិន្នន័យអំពីការចុះបញ្ជីស្វ័យអត្តសញ្ញាណរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពិតជាជនជាតិស្អូច មិនមែនជនជាតិចារ៉ាយទេ ដែលកំពុងរស់ក្នុងខេត្តព្រះសីហនុ។
- នៅខេត្តត្បូងឃ្មុំ ទិន្នន័យជំរឿនបង្ហាញថាមានជនជាតិចារ៉ាយនិងការ៉ែត ឯទិន្នន័យឃុំសង្កាត់បង្ហាញថា មានតែជនជាតិស្ទៀងប៉ុណ្ណោះ។ ទិន្នន័យអំពីការចុះបញ្ជីស្វ័យអត្តសញ្ញាណរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បង្ហាញថាមានជនជាតិស្ទៀងកំពុងរស់នៅលើទឹកដីនៃខេត្តត្បូងឃ្មុំ។

តារាងទី ៨. ចំនួនជនជាតិដើមភាគតិចដែលកើតនៅក្នុងខេត្តទាំង១៥ តាមខេត្តនិងតាមអំបូរ

| | | ចំនួនជនជាតិដើមសរុប | ចំនួននិងអំបូរជនជាតិដើមកើតក្នុងខេត្ត | | | | |
|---|---|---|---|---|---|---|---|
| | | | ចំនួនសរុប | អំបូរដែលមានប្រជាជនកើតក្នុងខេត្ត៥០នាក់ឡើង តាមចំនួនច្រើនទៅតិច | | | |
| ១ | បន្ទាយមានជ័យ | ១១០៧ | ៦៩៨ | កួយ (២៧៥នាក់) | ចារ៉ាយ (១៩៦នាក់) | | |
| ២ | បាត់ដំបង | ៦០៩ | ៤០២ | ចារ៉ាយ (២១១នាក់) | ព័រ (៦៤នាក់) | | |
| ៥ | កំពង់ស្ពឺ | ១១៣២ | ១០៨១ | សួយ (៦៩៧នាក់) | ចារ៉ាយ (១៨៦នាក់) | | |
| ៦ | កំពង់ធំ | ៤០៤៣ | ៣៧៣២ | កួយ (៣៣០៧នាក់) | ចារ៉ាយ (១៩១នាក់) | ការ៉ែត (៥៨នាក់) | |
| ៩ | កោះកុង | ១៨០ | ១៦០ | ក្រោល (១០៨នាក់) | | | |
| ១០ | ក្រចេះ | ១៨០៦៧ | ១៧៤៧៨ | ពូនង (៥៤៧៦នាក់) | ក្រោល (៣៧៦៨នាក់) | ស្ទៀង (៣៤៩៤នាក់) | កួយ (២៨៨០នាក់) |
| | | | | ថ្មូន (៩៦៣នាក់) | មិល (៧១៤នាក់) | | |
| ១១ | មណ្ឌលគិរី | ៣១១២៨ | ២៩៦៤៨ | ពូនង (២៧៦១៧នាក់) | ក្រោល (១៣៥៤នាក់) | ស្ទៀង (៤៨៧នាក់) | ទំពួន (៧៣នាក់) |
| | | | | ថ្មូន (៥៤នាក់) | | | |
| ១៣ | ព្រះវិហារ | ៩២៨៦ | ៨៨២៥ | កួយ (៨១៥៦នាក់) | ព័រ (៥២០នាក់) | | |
| ១៥ | ពោធិសាត់ | ៣៧៥ | ៣៣៦ | ព័រ (២០១នាក់) | | | |
| ១៦ | រតនគិរី | ៩៤២០៤ | ៨៩៧៨១ | ទំពួន (៣៤៥៨៤នាក់) | ចារ៉ាយ (២២៣៩២នាក់) | គ្រឹង (១៩៣៩៥នាក់) | ព្រៅ (៨៩៣៥នាក់) |
| | | | | ការ៉ែត (២៧៩៣នាក់) | ពូនង (៨៩៥នាក់) | លុន (៦០១នាក់) | កួយ (១០៧នាក់) |
| ១៧ | សៀមរាប | ៦៤៦ | ៤៦៤ | ចារ៉ាយ (២៥៧នាក់) | | | |
| ១៨ | ព្រះសីហនុ[1] | ១២២ | ៧១ | ចារ៉ាយ (៤៧នាក់) | | | |
| ១៩ | ស្ទឹងត្រែង | ៦០១០ | ៥៦៨៥ | ការ៉ែត (៣៧១២នាក់) | កួយ (៦២៨នាក់) | ពូនង (៥៩២នាក់) | លុន (៣១៥នាក់) |
| | | | | ចារ៉ាយ ៥៤នាក់) | | | |
| ២២ | ឧត្តរមានជ័យ | ៤៨៧ | ២០១ | កួយ (១១០នាក់) | | | |
| ២៥ | ត្បូងឃ្មុំ[2] | ៤០៥ | ២៩០ | ចារ៉ាយ (៨៥នាក់) | ការ៉ែត (៥៣នាក់) | | |

១ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៩បង្ហាញថាមានតែជនជាតិស្អូចចំនួន៣២គ្រួសារ (ត្រូវនឹង១៤៦នាក់) កំពុងរស់នៅក្នុងខេត្តព្រះសីហនុ។

២ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៩បង្ហាញថាមានតែជនជាតិស្ទៀងចំនួន៨គ្រួសារ (ត្រូវនឹង២៩នាក់) កំពុងរស់នៅក្នុងខេត្តត្បូងឃ្មុំ។

## ២.២. រចនាសម្ព័ន្ធអាយុភេទនៃប្រជាជនជនជាតិដើមភាគតិច

### ២.២.១. ភាគរយស្ត្រីនិងផលធៀបភេទ

ជាទូទៅ ប្រជាជននីមួយៗតែងមានចំនួនមនុស្សស្រីច្រើនជាងចំនួនមនុស្សប្រុស ទោះតិចក្តី ច្រើនក្តី។ ប្រជាជនកម្ពុជានិងប្រជាជនជនជាតិដើមភាគតិច ក៏ដូច្នោះដែរ។ នៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចមានស្ត្រីចំនួន ៥០,៩% (៥១,៩% ក្នុងចំណោមប្រជាជននៅទីប្រជុំជន និង៥០,៨% ក្នុងចំណោមប្រជាជននៅជនបទ) (តារាងទី៩)។ បើធៀបនឹងឆ្នាំ២០០៨ ភាគរយស្ត្រីនៃប្រជាជនជនជាតិដើមភាគតិច គ្មានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ នៅក្នុងចំណោមប្រជាជនសរុបនិងប្រជាជននៅជនបទ។ ក៏ប៉ុន្តែ ភាគរយស្ត្រីនៅទីប្រជុំជន កើន៣ពិន្ទុភាគរយ ពី៤៨,៨%នៅឆ្នាំ២០០៨ ដល់៥០,៩%នៅឆ្នាំ២០១៩ ដែលអាចបណ្តាលមកពីទេសន្តរប្រវេសន៍របស់ស្ត្រីទៅកាន់ទីប្រជុំជនក្នុងហេតុផលណាមួយ នាចន្លោះពេលនោះ។

ផលធៀបភេទ គឺជាចំនួនបុរសក្នុងចំណោមស្ត្រី១០០នាក់ ដែលផលធៀបភេទធំជាង១០០ បញ្ជាក់ពីចំនួនបុរសច្រើនជាងចំនួនស្ត្រី (ឬភាគរយស្ត្រីតូចជាង៥០%) និងផលធៀបភេទតូចជាង១០០ បញ្ជាក់ពីចំនួនបុរសតិចជាងចំនួនស្ត្រី (ឬភាគរយស្ត្រីធំជាង៥០%)។ តាមទិន្នន័យឆ្នាំ២០១៩ ផលធៀបភេទរបស់ប្រជាជនជនជាតិដើមភាគតិច បង្ហាញថា ជាសរុបនិងនៅជនបទ មានបុរសប្រហែល៩៧នាក់ក្នុងចំណោមស្ត្រី១០០នាក់ (ផលធៀបភេទស្មើនឹង៩៦,៦ជាសរុប និង៩៦,៩នៅជនបទ) និងនៅទីប្រជុំជនមានបុរសប្រហែល៩៣នាក់ក្នុងចំណោមស្ត្រី១០០នាក់(ផលធៀបភេទស្មើនឹង៩២,៦)។ លទ្ធផលនេះបង្ហាញថា នៅឆ្នាំ២០១៩ ស្ត្រីមានចំនួនច្រើនជាងបុរសនៅទីប្រជុំជន ដែលខុសឆ្ងាយពីឆ្នាំ២០០៨ ដែលបុរសមានច្រើនជាងស្ត្រីនៅទីប្រជុំជន (ផលធៀបភេទនៅទីប្រជុំជនឆ្នាំ២០០៨ ស្មើនឹង១០៥)។

ក្រាភិកទី២ខាងក្រោមបង្ហាញថា ភាគរយស្ត្រី ក៏ដូចជាផលធៀបភេទ ខុសគ្នាបន្តិចបន្តួចចំពោះអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនច្រើន ដែលភាគរយស្ត្រីស្ថិតក្នុងរង្វង់ពី ៥០% ដល់ ៥២%។ ភាពខុសគ្នាគួរឱ្យកត់សម្គាល់នៃភាគរយស្ត្រី ក៏ដូចជាផលធៀបភេទ កើតមានចំពោះតែអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនតិចប៉ុណ្ណោះ ដែលជាទូទៅអំបូរតូចៗទាំងនេះមានស្ត្រីតិចជាងបុរស (ស្ត្រីមានចំនួនក្នុងរង្វង់៤០%ទៅ៤៥%)។

តារាងទី ៩. ចំនួនប្រជាជនតាមភេទនិងទីកន្លែងរស់នៅ ឆ្នាំ២០០៨ និងឆ្នាំ២០១៩

| | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| **កម្ពុជា** | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ | សរុប |
| ប្រុស (ពាន់នាក់) | ១.២៥៦ | ៥.២៦០ | ៦.៥១៦ | ២.៩៩៣ | ៤.៥៧៨ | ៧.៥៧២ |
| ស្រី (ពាន់នាក់) | ១.៣៥៨ | ៥.៥២១ | ៦.៨៨០ | ៣.១៤២ | ៤.៨៣៩ | ៧.៩៨០ |
| ភាគរយស្រី | ៥២,០ | ៥១,២ | ៥១,៤ | ៥១,២ | ៥១,៤ | ៥១,៣ |
| ផលធៀបភេទ | ៩២,៤ | ៩៥,៣ | ៩៤,៧ | ៩៥,៣ | ៩៤,៦ | ៩៤,៩ |
| **ជនជាតិដើមភាគតិច** | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ | សរុប |
| ប្រុស | ២.៤៦២ | ៨៥.៤៣៧ | ៨៧.៨៩៩ | ៦.១២៥ | ៧៨.៨៦៨ | ៨៤.៩៩៣ |
| ស្រី | ២.៣៤៤ | ៨៨.៩៥០ | ៩១.២៩៤ | ៦.៦១៤ | ៨១.៣៧៣ | ៨៧.៩៨៧ |
| ភាគរយស្រី | ៤៨,៨ | ៥១,០ | ៥០,៩ | ៥១,៩ | ៥០,៨ | ៥០,៩ |
| ផលធៀបភេទ | ១០៥,០ | ៩៦,១ | ៩៦,៣ | ៩២,៦ | ៩៦,៩ | ៩៦,៦ |

ក្រាភិកទី ២. ភាគរយស្ត្រីនិងផលធៀបភេទតាមអំបូរជនជាតិដើមភាគតិច ឆ្នាំ២០១៩



ក្រាភិកទី២ខាងលើបង្ហាញថា ជនជាតិរអងមានស្ត្រីច្រើនជាងបុរស ច្រើនជាងអំបូរដទៃ (ភាគរយស្ត្រីស្មើនឹង៥៨,៦% និងផលធៀបភេទស្មើនឹង៧០,៥%) បន្ទាប់មក គឺជនជាតិស្ទួយ និងកាវ្រ៉ុក ដែលមានភាគរយស្ត្រីប្រហែល៥៣% និងផលធៀបភេទប្រហែល៨៨%។ រីឯអំបូរតូចៗឯទៀត (មាន ស្ទួច រដែ ខោញ មន និងកាចក់) មានស្ត្រីតិចជាងបុរស ក្នុងរង្វង់ ៤០% ទៅ ៤៥%ប៉ុណ្ណោះ ដែលផលធៀបភេទមានចំនួនរហូតដល់ ១២៥% ទៅ ១៥០%។

ក្រាភិកទី ៣. ផលធៀបភេទតាមក្រុមអាយុ៥ៗឆ្នាំ




ជានិន្នាការទូទៅ ផលធៀបភេទច្រើនមានតម្លៃ ធំជាង១០០ ក្នុងចំណោមទារកទើបកើត កុមារ និងយុវវ័យ និងថយចុះជាបន្តបន្ទាប់កាលណាអាយុកាន់តែច្រើន។ និន្នាការនេះមានចំពោះប្រជាជនកម្ពុជា ក៏ដូចជាចំពោះប្រជាជនជនជាតិដើមភាគតិចដែរ។ ក៏ប៉ុន្តែ ផលធៀបភេទរបស់ប្រជាជននៃជនជាតិដើមភាគតិច ប្រែប្រួលចុះឡើងពីក្រុមអាយុមួយទៅក្រុមអាយុមួយទៀត ជាងការមាននិន្នាការថយចុះដោយរលូនតាមអាយុ និងមានតម្លៃខុសពីផលធៀបភេទរបស់ប្រជាជនកម្ពុជានៅក្នុងក្រុមអាយុជាច្រើន (ក្រាភិកទី៣ខាងលើ)។ ធៀបនឹងប្រជាជនកម្ពុជាជារួម ជនជាតិដើមភាគតិចមានផលធៀបភេទទាបជាង ចំពោះ

ក្រុមអាយុក្រោម២០ឆ្នាំ ធំជាងចំពោះក្រុមអាយុ៥៥ឆ្នាំឡើង និងប្រែប្រួលចុះឡើងខ្លាំងចំពោះក្រុមអាយុ ២០ឆ្នាំ ដល់អាយុ៥៤ឆ្នាំ។

### ២.២.២. របាយអាយុប្រជាជន

នៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចអាយុក្រោម១៥ឆ្នាំមានចំនួន៣៤,៨% អាយុ១៥-៥៩ឆ្នាំមានចំនួន៥៩,២% (អាយុ១៥-៦៤ឆ្នាំមានចំនួន៦១,៣%) និងអាយុ៦០ឆ្នាំឡើងមានចំនួន៦% (តារាងទី ១០)។ របាយអាយុនៃប្រជាជនជនជាតិដើមភាគតិច បង្ហាញថាប្រជាជនវ័យក្មេងអាយុក្រោម១៥ឆ្នាំបានថយចុះពី៤១,៧%នៅឆ្នាំ២០០៨ មក៣៤,៨% នៅឆ្នាំ២០១៩។ ក្នុងនោះ កុមារក្នុងក្រុមអាយុក្រោម៥ឆ្នាំ បានថយចុះពី១៣,៦%មក១០,២% ក្នុងក្រុម អាយុ៥-៩ឆ្នាំបានថយចុះពី១៤,៥%មក១១,៧% និងក្នុងក្រុមអាយុ១០-១៤ឆ្នាំបានថយចុះពី១៣,៦% មក១២,៩% ដែលការថយចុះនេះអាចជាវិបាកនៃការថយចុះនៃអត្រាលទ្ធភាពមានកូនក្នុងអំឡុងពេល ១១ឆ្នាំកន្លងមកនេះ។ រីឯភាគរយប្រជាជនក្នុងក្រុមអាយុ ១៥-៥៩ឆ្នាំ បានកើនឡើងខ្លះៗ ពី៥៣,១% នៅ ឆ្នាំ២០០៨ មក៥៩,២%នៅឆ្នាំ២០១៩ ដែលក្នុងនោះក្រុមអាយុដែលកើនច្រើនជាងគេ គឺក្រុមអាយុ ៣០-៣៤ឆ្នាំ (កើន១,៦%) ក្រុមអាយុ៣៥-៣៩ឆ្នាំ (កើន ១,២%) និងក្រុមអាយុ១៥-១៩ឆ្នាំ (កើន១,២%)។ ចំណែកឯភាគរយនៃប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងកើនឡើងតិចតួច ពី៥,៥%នៅឆ្នាំ២០០៨ មក ៦% នៅឆ្នាំ២០១៩។

ថ្វីបើចំនួនប្រជាជនវ័យក្មេងបានថយចុះ ប្រជាជននៃជនជាតិដើមភាគតិចទាំងអស់នៅបន្តជាប្រជាជនវ័យក្មេងជាងប្រជាជនកម្ពុជាសរុប (អាយុមេដ្យានស្មើនឹង២១ឆ្នាំ ធៀបនឹង២៦ឆ្នាំ រៀងគ្នា)។ តារាងខាងក្រោមបង្ហាញថា ភាគរយជនជាតិភាគតិចអាយុ ក្រោម១៥ឆ្នាំមានចំនួនច្រើនជាងប្រជាជនកម្ពុជាក្នុងក្រុមអាយុដូចគ្នា ដោយចំនួន៥,៤ពិន្ទុភាគរយ (គឺ ៣៤,៨%ទល់នឹង២៩,៤%) អាយុ១៥-៥៩ឆ្នាំមានចំនួនតិចជាង២,៥ពិន្ទុភាគរយ (គឺ៥៩,២%ទល់នឹង ៦១,៧%) និងអាយុ៦០ឆ្នាំឡើងមានចំនួនតិចជាងប្រហែល៣ពិន្ទុភាគរយ (គឺ៦%ទល់នឹង៨,៩%)។

បើគិតតាមក្រុមអាយុ៥ៗឆ្នាំ ប្រជាជនជនជាតិដើមភាគតិចក្នុងក្រុមអាយុក្រោម៥ឆ្នាំ មានចំនួនច្រើនជាងប្រជាជនកម្ពុជាក្នុងក្រុមអាយុដូចគ្នា ជិត១ពិន្ទុភាគរយ (គឺ១០,២% ទល់នឹង ៩,៣%), ក្នុងក្រុមអាយុ៥-៩ឆ្នាំ ច្រើនជាង២,២ពិន្ទុភាគរយ (គឺ១១,៧% ទល់នឹង ៩,៥%), ក្នុងក្រុមអាយុ១០-១៤ឆ្នាំ ច្រើនជាង២,៣ពិន្ទុភាគរយ (គឺ១២,៩% ទល់នឹង ១០,៦%), និងក្នុងក្រុមអាយុ១៥-១៩ឆ្នាំ ច្រើនជាង២,៨ពិន្ទុភាគរយ (១១,៩% ទល់នឹង ៩,១%)។ រីឯក្រុមអាយុចាប់ពីអាយុ២៥ឆ្នាំឡើង មានចំនួនតិចជាងប្រជាជនកម្ពុជា ស្ទើរតែគ្រប់ក្រុមអាយុទាំងអស់ តែភាពខុសគ្នាតិចតួចមានទំហំតិចតួចប៉ុណ្ណោះ។

តារាងទី ១០.  របាយភាគរយនៃក្រុមអាយុ៥ៗឆ្នាំ

| ក្រុមអាយុ | ២០០៨ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា (ពាន់នាក់) | | ជនជាតិដើមភាគតិច | | កម្ពុជា (ពាន់នាក់) | | ជនជាតិដើមភាគតិច | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ០-៤ | ១,៣៧៣ | ១០.២% | ២៤,៣១២ | ១៣.៦% | ១,៤៥០ | ៩.៣% | ១៧,៥៧៨ | ១០.២% |
| ៥-៩ | ១,៤៧១ | ១១.០% | ២៦,០០១ | ១៤.៥% | ១,៤៧៣ | ៩.៥% | ២០,១៨៨ | ១១.៧% |
| ១០-១៤ | ១,៦៧១ | ១២.៥% | ២៤,៣២៤ | ១៣.៦% | ១,៦៤៨ | ១០.៦% | ២២,៣៧៣ | ១២.៩% |
| សរុប ០-១៤ | ៤,៥១៤ | ៣៣.៧% | ៧៤,៦៣៧ | ៤១.៧% | ៤,៥៧១ | ២៩.៤% | ៦០,១៣៩ | ៣៤.៨% |
| ១៥-១៩ | ១,៦១៩ | ១២.១% | ១៩,១២៦ | ១០.៧% | ១,៤០៩ | ៩.១% | ២០,៦៤៦ | ១១.៩% |
| ២០-២៤ | ១,៣៦៩ | ១០.២% | ១៦,០៧០ | ៩.០% | ១,២៥៥ | ៨.១% | ១៦,៧០៦ | ៩.៧% |
| ២៥-២៩ | ១,២៣៣ | ៩.២% | ១៤,៨៦៤ | ៨.៣% | ១,៤២៨ | ៩.២% | ១៤,៩៤៦ | ៨.៦% |
| ៣០-៣៤ | ៦៩៣ | ៥.២% | ៩,៩៧៩ | ៥.៦% | ១,៣០៦ | ៨.៤% | ១២,៤៤៦ | ៧.២% |
| ៣៥-៣៩ | ៨៤៥ | ៦.៣% | ៩,៨៤១ | ៥.៥% | ១,៣០៦ | ៨.៤% | ១១,៥១៤ | ៦.៧% |
| ៤០-៤៤ | ៧៣៧ | ៥.៥% | ៨,២៤៣ | ៤.៦% | ៧៥៣ | ៤.៨% | ៧,៦៩៩ | ៤.៥% |
| ៤៥-៤៩ | ៦៥៤ | ៤.៩% | ៧,២២២ | ៤.០% | ៧៨៩ | ៥.១% | ៧,២៥៧ | ៤.២% |
| ៥០-៥៤ | ៤៩១ | ៣.៧% | ៥,៤៩៤ | ៣.១% | ៧១៥ | ៤.៦% | ៦,១៣៥ | ៣.៥% |
| ៥៥-៥៩ | ៣៩១ | ២.៩% | ៤,០៦៦ | ២.៣% | ៦៤០ | ៤.១% | ៥,១០៧ | ៣.០% |
| សរុប ១៥-៥៩ | ៨,០៣៣ | ៦០.០% | ៩៤,៩០៥ | ៥៣.១% | ៩,៦០២ | ៦១.៧% | ១០២,៤៥៦ | ៥៩.២% |
| ៦០-៦៤ | ២៧៨ | ២.១% | ៣,៣៤០ | ១.៩% | ៤៦៦ | ៣.០% | ៣,៥៧៨ | ២.១% |
| ៦៥-៦៩ | ២១៧ | ១.៦% | ២,៤៤២ | ១.៤% | ៣៥៩ | ២.៣% | ២,៨៦៥ | ១.៧% |
| ៧០-៧៤ | ១៥៩ | ១.២% | ១,៧៩២ | ១.០% | ២៤១ | ១.៦% | ១,៧០៣ | ១.០% |
| ៧៥-៧៩ | ១០៨ | ០.៨% | ១,០០១ | ០.៦% | ១៥៥ | ១.០% | ១,០៦៦ | ០.៦% |
| ៨០+ | ៨៨ | ០.៧% | ១,០៧៦ | ០.៦% | ១៥៧ | ១.០% | ១,១៧៣ | ០.៧% |
| សរុប៦០ឆ្នាំឡើង | ៨៤៩ | ៦.៤% | ៩,៦៥១ | ៥.៥% | ១,៣៧៩ | ៨.៩% | ១០,៣៨៥ | ៦.០% |
| សរុប | ១៣,៣៩៦ | ១០០% | ១៧៩,១៩៣ | ១០០% | ១៥,៥៥២ | ១០០% | ១៧២,៩៨០ | ១០០% |

យោងតាមតម្រូវការនិងភាពចាំបាច់របស់អ្នកប្រើប្រាស់ទិន្នន័យតាមវ័យ ទិន្នន័យអាយុខាងលើ ត្រូវបានផ្តុំជាក្រុមវ័យសំខាន់ៗចំនួន៥ គឺ ១) វ័យទារកនិងកុមារតូច អាយុក្រោម៥ឆ្នាំ, ២) វ័យកុមារនិង ជំទង់ដែលជាវ័យសិក្សាចំណេះទូទៅ ចាប់ពីអាយុ៥ឆ្នាំដល់១៧ឆ្នាំ, ៣) មជ្ឈិមវ័យបឋម ដែលជាវ័យចាប់ ផ្តើមការងារ ចាប់ពីអាយុ១៨ឆ្នាំដល់៣៥ឆ្នាំ, ៤) មជ្ឈិមវ័យកណ្តាល ដែលជាវ័យកណ្តាល ចាប់ពីអាយុ ៣៦ ឆ្នាំដល់៥៩ឆ្នាំ, និង ៥) បច្ឆិមវ័យ ដែលជាវ័យចាស់ ចាប់ពីអាយុ៦០ឆ្នាំឡើង (ក្រាភិកទី៤)។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចនៅឆ្នាំ២០១៩ វ័យទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំមានចំនួន១០,២% (ថយចុះពីចំនួន១៣,៦%នៅឆ្នាំ២០០៨), វ័យកុមារនិងជំទង់ក្នុងវ័យសិក្សាមានចំនួន៣១,៦% (ថយចុះពីចំនួន៣៤,៤%នៅឆ្នាំ២០០៨), មជ្ឈិមវ័យបឋមមានចំនួន៣២,១% (កើនឡើងពីចំនួន២៨,៨%នៅឆ្នាំ២០០៨), មជ្ឈិមវ័យមានចំនួន២០,២% (កើនឡើងពីចំនួន១៧,៨%នៅ ឆ្នាំ២០០៨), និងបច្ឆិមវ័យមានចំនួន៦% (កើនឡើងពីចំនួន៥,៤%នៅឆ្នាំ២០០៨)។

ក្រាភិកទី ៤. របាយភាគរយនៃវ័យ ឆ្នាំ២០០៨និងឆ្នាំ២០១៩




ប្រៀបធៀបជាមួយនឹងរបាយវ័យនៃប្រជាជនកម្ពុជាឆ្នាំ២០១៩ ប្រជាជនជនជាតិដើមភាគតិចវ័យទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំមានចំនួនច្រើនជាងតិចតួច (១០,២%ធៀបនឹង៩,៣%), វ័យកុមារ

និងជំទង់ក្នុងវ័យសិក្សាមានចំនួនច្រើនជាងគួរឱ្យកត់សម្គាល់ (៣១,៦%ធៀបនឹង២៥,៥%), មជ្ឈិមវ័យបឋមមានចំនួនច្រើនជាងតិចតួច (៣២,១%ធៀបនឹង៣១,២%), មជ្ឈិមវ័យនិងបច្ឆិមវ័យមានចំនួនតិចជាង (២០,២%ធៀបនឹង២៥,២% និង ៦%ធៀបនឹង៨,៩%) (ក្រាភិកខាងលើ)។

ក្រាភិកទី ៥. របាយភាគរយនៃវ័យរបស់អំបូរជនជាតិដើមភាគតិចធំៗ




ក្រាភិកទី៥ខាងលើ បង្ហាញពីរបាយវ័យនៃអំបូរជនជាតិដើមនីមួយៗ ដែលមានចំនួនប្រជាជនចាប់ពី៥០០នាក់ឡើងទៅ រៀបតាមលំដាប់នៃចំនួនប្រជាជនពីច្រើនទៅតិច។ ជារួម ជនជាតិដើមភាគតិចនៃអំបូរដែលមានប្រជាជនច្រើន ចាប់ពីលុនដល់ពូនង មានរបាយវ័យប្រហាក់ប្រហែលគ្នា គឺវ័យទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំមានចំនួនក្នុងរង្វង់ប្រហែល១០% វ័យកុមារនិងជំទង់ក្នុងវ័យសិក្សាមានចំនួន ពី២៧%ដល់៣៥% មជ្ឈិមវ័យបឋមមានចំនួនពី២៩%ដល់៣៥% មជ្ឈិមវ័យមានចំនួន១៦%ដល់២៤% និងបច្ឆិមវ័យមានចំនួនពី៥%ដល់៩%។ ក្នុងចំណោមក្រុមអំបូរទាំងនេះ អំបូរដែលមានប្រជាជនក្នុងវ័យ

ទារក កុមារ និងជំទង់ច្រើនជាងគេ គឺថ្បូន លុន ការ៉ែត ពូនង និងទំពួន និងអំបូរដែលមានវ័យចាស់ច្រើនជាងគេ គឺស្ទៀង កួយ និងគ្រឹង។ រីឯអំបូរដែលមានប្រជាជនតិច ជារួម មានប្រជាជនក្នុងវ័យទារក កុមារ និងជំទង់តិចជាង និងប្រជាជនក្នុងវ័យមជ្ឈិមនិងវ័យបច្ឆិមច្រើនជាង។

### ២.២.៣. ពីរ៉ាមីដប្រជាជន

ពីរ៉ាមីដប្រជាជនខាងក្រោម បង្ហាញពីរបាយនិងបម្រែបម្រួលរចនាសម្ព័ន្ធអាយុ-ភេទរបស់ប្រជាជនជនជាតិដើមភាគតិច ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៩។ បម្រែបម្រួលមួយដែលគួរឱ្យកត់សម្គាល់គឺការថយចុះនៃភាគរយប្រជាជនវ័យក្មេង អាយុក្រោម១០ឆ្នាំ ពី៣៨,១% នៅឆ្នាំ២០០៨ មកនៅត្រឹម២១,៩% នៅឆ្នាំ២០១៩ (ថយចុះជិត៤៣%) ដែលបម្រែបម្រួលនេះនាំឱ្យមានការកើនឡើងនៃភាគរយប្រជាជន ក្នុងវ័យធ្វើការ (សូមមើលតារាងទី៩ ខាងលើ) ក្នុងខណៈដែលភាគរយនៃប្រជាជនវ័យចាស់កើនឡើង តិចតួច។

បម្រែបម្រួលនេះរចនាសម្ព័ន្ធអាយុនេះ កើតឡើងដោយសារការថយចុះនៃអត្រាលទ្ធភាពមានកូនរបស់ជនជាតិដើមភាគតិច និងជះឥទ្ធិពលផ្ទាល់ទៅលើបម្រែបម្រួលផលធៀបវ័យនៅក្នុងបន្ទុក[១៤] និងផលធៀបសក្ដានុពលគាំទ្រ[១៥] (តារាងទី១១ ខាងក្រោម)។ ចំពោះជនជាតិដើមភាគតិចជាសរុប ផលធៀបវ័យនៅក្នុងបន្ទុកសរុបបានថយចុះពី៨២,៤ មកនៅត្រឹម៦៣,១ ក្នុងចំណោមប្រជាជនវ័យធ្វើការ១០០នាក់ ដែលក្នុងនោះ ផលធៀបប្រជាជនវ័យក្មេងក្នុងបន្ទុកបានថយចុះពី៧៦,០ មកនៅត្រឹម៥៦,៧។ ដោយឡែក ផលធៀបវ័យចាស់ក្នុងបន្ទុកនិងផលធៀបសក្ដានុពលគាំទ្រ គ្មានការប្រែប្រួលទេពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ (គឺ ៦,៤ និង ១៥,៦ រៀងគ្នា ទាំងនៅឆ្នាំ២០០៨ ទាំងនៅឆ្នាំ២០១៩)។

---

[១៤] ផលធៀបវ័យក្នុងបន្ទុកសរុប គឺជាចំនួនប្រជាជនវ័យក្រោម១៥ឆ្នាំនិងវ័យ៦៥ឆ្នាំឡើង ក្នុងចំណោមប្រជាជនវ័យ ១៥-៦៤ឆ្នាំចំនួន១០០នាក់។ ផលធៀបវ័យក្មេងក្នុងបន្ទុកសរុប គឺជាចំនួនប្រជាជនវ័យក្រោម១៥ឆ្នាំ ក្នុងចំណោមប្រជាជនវ័យ ១៥-៦៤ឆ្នាំចំនួន១០០នាក់។ ផលធៀបវ័យចាស់ក្នុងបន្ទុកសរុប គឺជាចំនួនប្រជាជនវ័យ៦៥ឆ្នាំឡើង ក្នុងចំណោមប្រជាជនវ័យ ១៥-៦៤ឆ្នាំចំនួន១០០នាក់។

[១៥] ផលធៀបសក្ដានុពលគាំទ្រ (Potential Support Ratio) គឺជាចំនួនប្រជាជនវ័យ១៥-៦៤ឆ្នាំ ក្នុងចំណោមប្រជាជនវ័យ៦៥ឆ្នាំឡើង ចំនួន១នាក់។

ក្រាភិកទី ៦. ពីរ៉ាមីដប្រជាជន



ដោយប្រៀបធៀបផលធៀបវ័យក្នុងបន្ទុក (Age dependency ratio) និងផលធៀបសក្ដានុពលគាំទ្រ (Potential support ratio) រវាងប្រជាជនជនជាតិដើមភាគតិចនិងប្រជាជនកម្ពុជា យើងសង្កេតឃើញមានទិដ្ឋភាពលេខធ្លោចំនួនពីរៈ

ទីមួយ ផលធៀបវ័យក្មេងក្នុងបន្ទុក របស់ប្រជាជនជនជាតិដើមភាគតិចកាន់តែខិតទៅរកផលធៀបវ័យក្នុងបន្ទុករបស់ប្រជាជនកម្ពុជា ដែលផលធៀបវ័យក្មេងក្នុងបន្ទុក របស់ប្រជាជនជនជាតិដើមភាគតិច ថយចុះយ៉ាងលឿនពី៧៦%នៅឆ្នាំ២០០៨មក៥៦,៧%នៅឆ្នាំ២០១៩ ដោយសារការថយចុះនៃកំណើតក្នុងចន្លោះឆ្នាំនេះ ដែលធ្វើឱ្យគម្លាតធៀបវ័យក្មេងក្នុងបន្ទុកក្នុងចំណោមប្រជាជនទាំងពីរកាន់តែរួមតូច ពី២១,៧ នៅឆ្នាំ២០០៨ មក១១,៣ពិន្ទុភាគរយនៅឆ្នាំ២០១៩។

ទីពីរ ផលធៀបវ័យចាស់ក្នុងបន្ទុកនិងផលធៀបសក្ដានុពលគាំទ្រ រវាងប្រជាជនជនជាតិដើមភាគតិចនិងប្រជាជនកម្ពុជា មានគម្លាតកាន់តែធំ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ គឺ៦,៤%ទល់នឹង៦,៩%នៅឆ្នាំ២០០៨ (ក្នុងគម្លាត -០,៥ពិន្ទុភាគរយ) និង៦,៤%ទល់នឹង៩,១%នៅឆ្នាំ២០១៩ (ក្នុងគម្លាត -២,៦ពិន្ទុភាគរយ) ដែលមានន័យថា ប្រជាជនវ័យចាស់នៃជនជាតិដើមភាគតិចមានកំណើនយឺតជាងប្រជាជនវ័យចាស់នៃប្រជាជនកម្ពុជាសរុប។ ផ្ទុយទៅវិញ សក្ដានុពលគាំទ្រ (ដែលជាចំនួនប្រជាជនវ័យធ្វើការសម្រាប់គាំទ្រមនុស្សវ័យចាស់១នាក់) បង្ហាញថាជនជាតិដើមភាគតិចវ័យចាស់ម្នាក់ មានប្រជាជនវ័យធ្វើការចំនួន ១៥,៦នាក់សម្រាប់គាំទ្រ ទាំងនៅឆ្នាំ២០០៨ ទាំងនៅឆ្នាំ២០១៩ ដែលសម្រាប់វ័យចាស់កម្ពុជាសរុបតួលេខ នេះថយចុះពី១៤,៥នាក់នៅឆ្នាំ២០០៨ មកនៅត្រឹម១១នាក់នៅឆ្នាំ២០១៩។

តារាងទី ១១. ផលធៀបវ័យក្នុងបន្ទុក

| | | ផលធៀបវ័យក្នុងបន្ទុក | | | ផលធៀប សក្ដានុពលគាំទ្រ |
|---|---|---|---|---|---|
| | | សរុប | វ័យក្មេង | វ័យចាស់ | |
| ២០០៨ | កម្ពុជា | ៦១,២ | ៥៤,៣ | ៦,៩ | ១៤,៥ |
| | ជនជាតិដើមភាគតិច | ៨២,៤ | ៧៦,០ | ៦,៤ | ១៥,៦ |
| | ភាពខុសគ្នា (ពិន្ទុភាគរយ) (ជនជាតិធៀបនឹងកម្ពុជា) | ២១,២% | ២១,៧% | -០,៥% | ១,១% |
| ២០១៩ | កម្ពុជា | ៥៤,៥ | ៤៥,៤ | ៩,១ | ១១,០ |
| | ជនជាតិដើមភាគតិច | ៦៣,១ | ៥៦,៧ | ៦,៤ | ១៥,៦ |
| | ភាពខុសគ្នា (ពិន្ទុភាគរយ) (ជនជាតិធៀបនឹងកម្ពុជា) | ៨,៧% | ១១,៣% | -២,៦% | ៤,៥% |

## ២.៣. គ្រួសារនិងអាពាហ៍ពិពាហ៍

### ២.៣.១. ចំនួនគ្រួសារនិងភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារ

ទោះជាចំនួនប្រជាជនសរុបនៃជនជាតិដើមភាគតិច បានថយចុះក្នុងរវាងឆ្នាំ២០០៨និង២០១៩ យោងតាមទិន្នន័យជំរឿន ចំនួនគ្រួសារត្រូវបានកើនឡើងក្នុងចន្លោះពេលនេះ ពី៣៣.៨២០គ្រួសារ ទៅដល់៣៧.៩១៩គ្រួសារ ដែលជាលទ្ធផល ទំហំគ្រួសារជនជាតិដើមភាគតិចត្រូវបានថយចុះ (គឺថយពី៥,៣នាក់ មកនៅត្រឹម ៤,៦នាក់ ជាមធ្យមក្នុងមួយគ្រួសារ) និងខិតទៅរកទំហំគ្រួសារមួយដែលប្រហាក់ប្រហែលនឹងទំហំគ្រួសាររបស់ប្រជាជនកម្ពុជាជាសរុបនៅឆ្នាំ២០១៩ (គឺ៤,៦ ទល់នឹង ៤,៤)។ ភាគរយនៃគ្រួសារដែលមានស្ត្រីជាមេគ្រួសារ[១៦] គ្មានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេក្នុងចន្លោះពេលនេះ ទាំងគ្រួសារនៃជនជាតិដើមភាគតិច ទាំងគ្រួសារនៃប្រជាជនកម្ពុជាសរុប។

តារាងទី ១២. ចំនួនគ្រួសារនិងភាគរយស្ត្រីជាមេគ្រួសារៈ សរុបកម្ពុជានិងជនជាតិដើមភាគតិច

| | ២០០៨ | | ២០១៩ | |
|---|---|---|---|---|
| | ជនជាតិដើមភាគតិច | កម្ពុជា (ចំនួនគិតជាពាន់) | ជនជាតិដើមភាគតិច | កម្ពុជា (ចំនួនគិតជាពាន់) |
| ចំនួនប្រជាជន | ១៧៩.១៩៣ | ១៣.៣៩៦ | ១៧២.៩៨០ | ១៥.៥៥២ |
| ចំនួនគ្រួសារ | ៣៣.៨២០ | ២.៨៤២ | ៣៧.៩១៩ | ៣.៥៥៣ |
| ទំហំគ្រួសារជាមធ្យម | ៥,៣ | ៤,៧ | ៤,៦ | ៤,៤ |
| គ្រួសារដែលស្ត្រីជាមេគ្រួសារ (%) | ១៤,០% | ២៦,០% | ១៣,៦% | ២៥,៦% |

តារាងខាងក្រោមបង្ហាញពីចំនួនគ្រួសារ និងភាគរយគ្រួសារដែលមានស្ត្រីជាមេគ្រួសារនៃអំបូរជនជាតិដើមភាគតិច ដែលមានយ៉ាងតិច១០០គ្រួសារឡើង។ ជាទិដ្ឋភាពរួម ជនជាតិដើមភាគតិចអំបូរធំៗមានភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារ តិចជាងជនជាតិដើមភាគតិចដែលជាអំបូរតូចៗ។ ក្នុងចំណោមជនជាតិដើមភាគតិចអំបូរធំៗដែលមានចាប់ពី១ពាន់គ្រួសារឡើងទៅ អំបូរជនជាតិដើមភាគតិចដែលមាន

[១៦] ស្ត្រីជាមេគ្រួសារ កំណត់ដោយអ្នកឆ្លើយសំណួរអំពីនរណាជាមេគ្រួសារ ដែលមិនសំដៅតែទៅលើគ្រួសារដែលមានតែស្ត្រីជាមេគ្រួសារដែលគ្មានស្វាមីនោះទេ។

ភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារតិចជាងគេ គឺគ្រឹង(៨,២%) បន្ទាប់មកគឺទំពួន(៨,៨%), ចារ៉ាយ (១១,២%) ព្រៅ(១២%), កាវ៉ែត(១៣,១%), និងពូនង(១៤,៩%)។ ជនជាតិដើមភាគតិចដែលមានភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារច្រើនជាងគេ គឺស្ទៀង(២៤%), កួយ(២២,៦%) និងក្រោល (២១,៤%)។ រីឯអំបូរជនជាតិដើមភាគតិចអំបូរតូចៗ ដែលមានភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារតិចជាងគេ គឺថ្មូន(១២%) និងសួយ(១៩,១%)។ អំបូរជនជាតិដើមភាគតិច ដែលមានភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារច្រើនជាងគេ គឺអេង(៤៤%) និងគ្លឹង(៣២,៧%)។

ក្រាភិកទី ៧. ភាគរយគ្រួសារជនជាតិដើមភាគតិចដែលស្ត្រីជាមេគ្រួសារ តាមអំបូរធំៗ



ក្រាភិកទី ៨. ភាគរយគ្រួសារជនជាតិដើមភាគតិចដែលស្ត្រីជាមេគ្រួសារ តាមរាជធានីខេត្ត




ក្រាភិកខាងលើ បង្ហាញពីភាគរយគ្រួសារជនជាតិដើមភាគតិចដែលមានស្ត្រីជាមេគ្រួសារ តាមរាជធានីខេត្ត ដោយរៀបតាមលំដាប់រៀងនៃចំនួនគ្រួសារ និងដោយមិនបញ្ចូលខេត្តកែបនិងខេត្តប៉ៃលិន ដោយសារមានចំនួនគ្រួសារតិចតួចពេក។ ក្នុងចំណោមខេត្តដែលមានគ្រួសារជនជាតិដើមភាគតិច ចាប់ពីមួយពាន់គ្រួសារឡើងទៅ ខេត្តដែលមានភាគរយស្ត្រីជាមេគ្រួសារច្រើន គឺខេត្តព្រះវិហារ(២៥,៦%) និង ខេត្តកំពង់ធំ(២៥,២%)។ រាជធានីខេត្តដទៃទៀត មានគ្រួសារជនជាតិដើមភាគតិចក្រោមមួយពាន់គ្រួសារ និង

មានភាគរយស្ត្រីជាមេគ្រួសារតិចបំផុត២៣% ដែលភាគរយច្រើនជាងគេគឺមាននៅក្នុងខេត្តព្រះសីហនុ (៥២,៦%) បាត់ដំបង(៤៤,៤%) ព្រៃវែង(៤២,៥%) កំពង់ឆ្នាំង(៣៨,៦%) កំពង់ចាម (៣៦,៧%) និងរាជធានីភ្នំពេញ ស្វាយរៀង និងកំពត (ប្រហែល៣៥%)។

### ២.៣.២. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច

ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ត្រូវបានផ្តុំជាបីក្រុម គឺ ១.នៅលីវ, ២.រៀបការហើយនិងរស់នៅជាមួយគ្នា និង៣.មេម៉ាយ ពោះម៉ាយ លែងគ្នា ឬរស់នៅបែកគ្នា សម្រាប់ប្រជាជនអាយុ១៥ឆ្នាំឡើង។ ជារួម ជនជាតិដើមភាគតិចចំនួន២៥,៩% នៅលីវ, ៦៩,៨% រៀបការហើយនិងរស់នៅជាមួយគ្នា និង៤,២% មេម៉ាយ ពោះម៉ាយ លែងគ្នា ឬរស់នៅបែកគ្នា នៅឆ្នាំ២០១៩។ ស្ថានភាពអាពាហ៍ពិពាហ៍ជនជាតិដើមភាគតិច ខុសគ្នាតិចតួចពីស្ថានភាពអាពាហ៍ពិពាហ៍ប្រជាជនកម្ពុជាសរុប (តារាងទី ១៣)។

នៅទីប្រជុំជន ជនជាតិដើមភាគតិចដែលមិនទាន់រៀបការមានចំនួនច្រើនជាងនៅជនបទ (៣២,៨% ធៀបនឹង ២៥,៣%), អ្នករៀបការហើយនិងរស់នៅជាមួយគ្នាមានចំនួនតិចជាងនៅជនបទ (៦២,០% ធៀបនឹង ៧០,៥%) និងអ្នកមេម៉ាយ/ពោះម៉ាយឬលែងលះ/រស់នៅបែកគ្នាមានចំនួនច្រើនជាងនៅជនបទតិចតួច (៥,២% ធៀបនឹង ៤,១%)។

តារាងទី ១៣. ស្ថានភាពអាពាហ៍ពិពាហ៍ជនជាតិដើមភាគតិច

| ស្ថានភាពអាពាហ៍ពិពាហ៍ប្រជាជនអាយុ១៥ឆ្នាំឡើង | កម្ពុជា | ជនជាតិដើមភាគតិច | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ទីប្រជុំជន | | | ជនបទ | | |
| | សរុប | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| មិនដែលរៀបការ | ២៧,៥ | ២៥,៩ | ៣៦,៣ | ២៩,៧ | ៣២,៨ | ២៩,៦ | ២១,២ | ២៥,៣ |
| រៀបការហើយ | ៦៦,២ | ៦៩,៨ | ៦១,៧ | ៦២,៣ | ៦២,០ | ៦៨,៨ | ៧២,២ | ៧០,៥ |
| មេម៉ាយ/ពោះម៉ាយ | ៤,០ | ៣,០ | ០,៩ | ៥,៤ | ៣,៣ | ១,០ | ៤,៩ | ៣,០ |
| លែងលះឬនៅបែកគ្នា | ២,៣ | ១,២ | ១,១ | ២,៥ | ១,៩ | ០,៥ | ១,៧ | ១,១ |
| គ្មានទិន្នន័យ | ០,០០ | ០,០០ | ០,០២ | ០,០៦ | ០,០៤ | ០,០៥ | ០,០១ | ០,០៣ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

បើគិតតាមភេទ ស្ត្រីមិនទាន់រៀបការមានភាគរយតិចជាងបុរស ទាំងនៅទីប្រជុំជនទាំងនៅជនបទ (២៩,៧% ធៀបនឹង ៣៦,៣% នៅទីប្រជុំជន និង ២១,២% ធៀបនឹង ២៩,៦% នៅជនបទ)។ ឯស្ត្រីរៀបការហើយនិងរស់នៅជាមួយគ្នាមានភាគរយប្រហាក់ប្រហែលនឹងបុរស (៦២,៣% ធៀបនឹង ៦១,៧%)

នៅទីប្រជុំជន ក៏ប៉ុន្តែស្ត្រីរៀបការហើយនិងរស់នៅជាមួយគ្នាមានចំនួនច្រើនជាងបុរសនៅជនបទ (៧២,២% ធៀបនឹង ៦៨,៨%)។ ស្ត្រីមេម៉ាយមានភាគរយច្រើនជាងបុរសពោះម៉ាយប្រហែល៥ដង ទាំងនៅទី ប្រជុំជន (៥,៤% ធៀបនឹង ០,៩%) ទាំងនៅជនបទ (៤,៩% ធៀបនឹង ១%)។ ស្ត្រីដែលលែងលះឬរស់ នៅបែកគ្នា ក៏មានចំនួនច្រើនជាងបុរសដែរ។

ក្រាភិកទី ៩. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង




របាយភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ខុសគ្នាខ្លះៗទៅតាមអំបូរ នីមួយៗ (ក្រាភិកទី ៩)។ អំបូរដែលមានប្រជាជននៅលីវតិចជាងគេ និងមានប្រជាជនរៀបការហើយនិង រស់នៅជាមួយគ្នាច្រើនជាងគេ មានគ្រឹង (២១,៦% និង ៧៤,៧% រៀងគ្នា) បន្ទាប់មកគឺ ក្ហួយ (២៣,២%

និង ៧១,៤% រៀងគ្នា), កាវ៉ែត (២៣,៧% និង ៧២% រៀងគ្នា), និងព្រៅ (២៤,២% និង ៧១,៩% រៀងគ្នា)។ ផ្ទុយទៅវិញ អំបូរដែលមានប្រជាជននៅលីវច្រើនជាងគេ និងមានប្រជាជនរៀបការហើយនិងរស់នៅជាមួយគ្នាតិចជាងគេ គឺស្ទួយ (៣៧,៣% និង ៦១,៨% រៀងគ្នា) បន្ទាប់មកគឺព័រ (៣២,៣% និង ៦០,៦% រៀងគ្នា), ស្អៀង (៣១,៣% និង ៦៤,១% រៀងគ្នា), ថ្មូន (៣១% និង ៦៧,៣% រៀងគ្នា), និងក្រោល (៣០,៧% និង ៦៤,៩% រៀងគ្នា)។ រីឯភាគរយនៃប្រជាជនមេម៉ាយ ពោះម៉ាយ លែងគ្នា ឬរស់នៅបែកគ្នា មានចំនួនតិចជាងគេក្នុងចំណោមស្ទួយ (០,៩%) និងថ្មូន (១,៧%) និងច្រើនជាងគេក្នុងចំណោមលុន (៨,៤%), ព័រ (៧,២%), និងមិល (៦,៨%)។

### ២.៣.៣. អាពាហ៍ពិពាហ៍កាត់ជនជាតិ

ក្រាភិកទី ១០. អាពាហ៍ពិពាហ៍កាត់ជនជាតិ




នៅក្នុងដំណើរនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ការរៀបអាពាហ៍ពិពាហ៍ជាមួយជាតិពន្ធ ជាតិសាសន៍ ឬក្រុមដែលមានវប្បធម៌ផ្សេង គឺជារឿងធម្មតារបស់ប្រជាជន។ ក្រាភិកទី១០ ខាងក្រោមបង្ហាញពីអាពាហ៍ពិពាហ៍កាត់ជនជាតិរបស់ជនជាតិដើមភាគតិច ដែលរៀបការហើយនិងរស់នៅជាមួយគ្នា។ ក្នុងចំណោមអាពាហ៍ពិពាហ៍ទាំងនេះ ៨៣,៥% ជាអាពាហ៍ពិពាហ៍ដែលស្វាមីនិងភរិយាជាជនជាតិដើមភាគតិចដូចគ្នា ដោយមិនគិតអំបូរ, ១០,២% ជាអាពាហ៍ពិពាហ៍រវាងស្វាមីជាជនជាតិដើមភាគ

តិចនិងភរិយាជាជនជាតិផ្សេង និង៦,៣% ជាអាពាហ៍ពិពាហ៍រវាងស្វាមីជាជនជាតិផ្សេងនិងភរិយាជាជនជាតិដើមភាគតិច។

### ២.៣.៤. អាយុរៀបការដំបូង

ជំរឿនឆ្នាំ២០១៩មានទិន្នន័យអំពីអាយុរៀបការដំបូង[១៧] ដែលអាចឱ្យយើងគណនារកអាយុមធ្យមពេលរៀបការដំបូង (តាមចម្លើយអំពីអាយុរៀបការដំបូង) ដោយវិធីផ្ទាល់ចេញពីទិន្នន័យនេះបាន។ អាយុរៀបការដំបូង ក៏អាចគណនាបានតាមវិធីប្រយោល (Singulate Mean Age at First Marriage, SMAM) ដែលជាចំនួនឆ្នាំនៃភាពនៅលីវ ដោយគណនាចេញពីទិន្នន័យអំពីស្ថានភាពអាពាហ៍ពិពាហ៍។ គួរកត់សម្គាល់ថា លទ្ធផលនៃរង្វាស់ទាំងពីរខុសគ្នាជានិច្ច [សូមប្រៀបធៀបកូឡោន(២) និង(៣) ក្នុងតារាងទី១៤ខាងក្រោម]។

លទ្ធផលក្នុងតារាងទី១៤ កូឡោន(១) និង(២) និងក្នុងក្រាភិកទី១១ខាងក្រោម បង្ហាញពីអាយុរៀបការដំបូង ដែលគណនាតាមវិធី SMAM។ ជារួម បុរសជនជាតិដើមភាគតិច រៀបការនៅអាយុ ២៤ឆ្នាំជាមធ្យម (២៦ឆ្នាំនៅទីប្រជុំជន និង ២៣,៧ឆ្នាំនៅជនបទ) រីឯស្ត្រីជនជាតិដើមភាគតិច រៀបការនៅអាយុ ២០,៦ឆ្នាំ ជាមធ្យម (២៣ឆ្នាំនៅទីប្រជុំជន និង២០,៤ឆ្នាំនៅជនបទ)។ ធៀបទៅនឹងឆ្នាំ២០០៨ អាយុរៀបការដំបូងនៅក្នុងឆ្នាំ២០១៩ កើនឡើងតិចតួច ដែលការកើនឡើងនេះកើតមាននៅជនបទច្រើនជាងនៅទីប្រជុំជនចំពោះបុរស (ពី២៣ឆ្នាំដល់ ២៣,៧ឆ្នាំសម្រាប់ជនបទ និងពី២៥,៥ឆ្នាំដល់ ២៦ឆ្នាំសម្រាប់ទីប្រជុំជន) និងនៅទីប្រជុំជនចំពោះស្ត្រី (ពី២២,១ឆ្នាំដល់ ២៣ឆ្នាំនៅទីប្រជុំជន និង២០,៤ឆ្នាំថេរនៅជនបទ)។

ទោះយ៉ាងណាក្តី អាយុរៀបការដំបូងរបស់ជនជាតិដើមភាគតិច នៅបន្ទាបជាងអាយុរៀបការដំបូងរបស់ប្រជាជនកម្ពុជាជារួម ប្រមាណពី២ឆ្នាំទៅ៣ឆ្នាំ។ មានន័យថា ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅ ២ទៅ៣ឆ្នាំ ទាំងបុរសទាំងស្ត្រី ទាំងនៅជនបទទាំងនៅទីប្រជុំជន។

---

[១៧] សំណួរអំពីអាយុនៅពេលរៀបការលើកទីមួយ ចំពោះអ្នកដែលរៀបការហើយ មេម៉ាយ/ពោះម៉ាយ លែងលះ និងបែកគ្នា។

តារាងទី ១៤.  អាយុពេលរៀបការដំបូង

| | | (១)<br>២០០៨<br>(តាមវិធី SMAM) | | (២)<br>២០១៩<br>( តាមវិធី SMAM) | | (៣)<br>២០១៩<br>( គណនាផ្ទាល់) | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ជនជាតិដើមភាគតិច | សរុប | ២៣,១ | ២០,៤ | ២៣,៩ | ២០,៦ | ២២,៨ | ២០,២ |
| | ទីប្រជុំជន | ២៥,៥ | ២២,១ | ២៦,០ | ២៣,០ | ២៣,៧ | ២១,០ |
| | ជនបទ | ២៣,០ | ២០,៤ | ២៣,៧ | ២០,៤ | ២២,៧ | ២០,១ |
| កម្ពុជា | សរុប | ២៥,៦ | ២៣,៣ | ២៧,០ | ២៤,០ | ២៤,២ | ២១,៧ |
| | ទីប្រជុំជន | ២៨,០ | ២៥,៥ | ២៨,១ | ២៥,០ | ២៤,៩ | ២២,២ |
| | ជនបទ | ២៤,៨ | ២២,៥ | ២៦,០ | ២២,៧ | ២៣,៧ | ២១,៤ |

ក្រាភិកទី ១១.  អាយុពេលរៀបការដំបូង



### ២.៣.៦. អាពាហ៍ពិពាហ៍វ័យក្មេង

ការឆាប់រៀបការមានឥទ្ធិពលផ្ទាល់និងវិជ្ជមានទៅលើចំនួនកូនដែលស្ត្រីមាន និងអវិជ្ជមានទៅលើទិដ្ឋភាពសង្គម-សេដ្ឋកិច្ចជាច្រើន ដូចជាការអប់រំ សុខភាព ការងារ និងសេដ្ឋកិច្ចគ្រួសារ។ តារាងទី១៥ បង្ហាញពីអាយុរៀបការដំបូង ដែលគណនាតាមវិធីផ្ទាល់ដោយប្រើប្រាស់ទិន្នន័យអំពីអាយុរៀបការដំបូង តាមក្រុមអាយុ ពិសេសគឺការរៀបការនៅអាយុក្រោម១៩ឆ្នាំ និងនៅអាយុ២០-២៤ឆ្នាំ ដើម្បីពិនិត្យមើលការឆាប់រៀបការរបស់ប្រជាជនជនជាតិដើមភាគតិច។ ជាទិដ្ឋភាពរួម យើងសង្កេតឃើញថា ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅក្នុងចំនួនដ៏ច្រើន ទាំងបុរសទាំងស្ត្រី និង ទាំងនៅទីប្រជុំជនទាំងនៅជនបទ។

ជាក់ស្តែង ស្ត្រីជនជាតិដើមភាគតិចដែលរៀបការនៅអាយុ១៦-១៩ឆ្នាំ មានចំនួន ៤៩,៥% នៅទីប្រជុំជន និង៥៥,៩%នៅជនបទ (ធៀបនឹងស្ត្រីកម្ពុជាដែលរៀបការនៅក្រុមអាយុដូចគ្នា ដែលមានចំនួនត្រឹម២៩,៦%នៅទីប្រជុំជន និង៣៨,១%នៅជនបទ)។ បុរសជនជាតិដើមភាគតិចដែលរៀបការនៅអាយុ១៦-១៩ឆ្នាំ មានចំនួន ២១,៥%នៅទីប្រជុំជន និង២៤,៧%នៅជនបទ (ធៀបនឹងបុរសកម្ពុជាដែល រៀបការនៅក្រុមអាយុដូចគ្នា ដែលមានចំនួនត្រឹម៩,៥%នៅទីប្រជុំជន និង១៤,៥%នៅជនបទ)។ នេះ បង្ហាញថា បុរសនិងស្ត្រីជនជាតិដើមភាគតិចឆាប់រៀបការជាងបុរសស្ត្រីកម្ពុជាទូទៅ ហើយស្ត្រីជនជាតិដើម ភាគតិចឆាប់រៀបការជាងស្ត្រីកម្ពុជាទូទៅ ចំនួន ១,៧ដងនៅទីប្រជុំជន និងចំនួន ១,៥ដងនៅជនបទ។

ផ្ទុយទៅវិញ ស្ត្រីជនជាតិដើមភាគតិចដែលរៀបការនៅអាយុ២០-២៥ឆ្នាំមានចំនួនតិចជាងស្ត្រី កម្ពុជាក្នុងក្រុមអាយុដូចគ្នា គឺ៣១,៣% ធៀបនឹង ៤៣,៨% ជាសរុប, ៣២.០% ធៀបនឹង ៤៥,១% នៅទីប្រជុំ ជន , និង៣១,២% ធៀបនឹង ៤៣,០% នៅជនបទ។ ដោយឡែក បុរសជនជាតិដើមភាគតិចដែលរៀបការ នៅអាយុ២០-២៥ឆ្នាំ មានចំនួនប្រហាក់ប្រហែលទៅនឹងបុរសកម្ពុជាក្នុងក្រុមអាយុដូចគ្នា គឺ៤៦,៣% ធៀបនិង ៤៧,០% ជាសរុប, ៤២,៦% ធៀបនឹង ៤២,៧% នៅទីប្រជុំជន, និង ៤៦,៦% ធៀបនឹង ៤៩,៧% នៅជនបទ។

បើគិតក្នុងក្រុមអាយុ១៦-២៤ឆ្នាំ ៨៦,៧%នៃស្ត្រីជនជាតិដើមភាគតិច (៨៦,១%នៅទីប្រជុំជន និង ៨៧,២%នៅជនបទ) និង៧០,៨%នៃបុរសជនជាតិដើមភាគតិច (៦៤,១%នៅទីប្រជុំជន និង ៧១,៣% នៅជនបទ) បានរៀបការហើយ។ ក្នុងចំណោមប្រជាជនកម្ពុជាសរុប ៧៨,៦%នៃស្ត្រីអាយុ១៦-២៥ឆ្នាំ (៧៤,៧%នៅទីប្រជុំជន និង៨១,០%នៅជនបទ) និង៥៩,៥%នៃបុរស (៥២,២%នៅទីប្រជុំជន និង ៦៤,២%នៅជនបទ) បានរៀបការហើយ។

តារាងទី ១៥.    របាយភាគរយនៃអាយុរៀបការដំបូង តាមភេទនិងទីកន្លែងរស់នៅ ឆ្នាំ២០១៩៖ ជនជាតិដើមភាគតិចនិងកម្ពុជា

| | ជនជាតិដើមភាគតិច | | | | | | កម្ពុជា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទីប្រជុំជន | | ជនបទ | | សរុប | | ទីប្រជុំជន | | ជនបទ | | សរុប | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| អាយុ ១៦-១៩ឆ្នាំ | ២១,៥ | ៤៩,៥ | ២៤,៧ | ៥៥,៩ | ២៤,៤ | ៥៥,៤ | ៩,៥ | ២៩,៦ | ១៤,៥ | ៣៨,១ | ១២,៥ | ៣៤,៨ |
| អាយុ ២០-២៤ឆ្នាំ | ៤២,៦ | ៣២,០ | ៤៦,៦ | ៣១,២ | ៤៦,៣ | ៣១,៣ | ៤២,៧ | ៤៥,១ | ៤៩,៧ | ៤៣,០ | ៤៧,០ | ៤៣,៨ |
| សរុប ១៦-២៤ឆ្នាំ | ៦៤,១ | ៨១,៦ | ៧១,៣ | ៨៧,២ | ៧០,៨ | ៨៦,៧ | ៥២,២ | ៧៤,៧ | ៦៤,២ | ៨១,០ | ៥៩,៥ | ៧៨,៦ |
| អាយុ ២៥-២៩ឆ្នាំ | ២២,៤ | ១១,៥ | ២០,០ | ៨,៦ | ២០,២ | ៨,៨ | ៣១,៧ | ១៨,៥ | ២៥,៧ | ១៣,៥ | ២៨,០ | ១៥,៤ |
| អាយុ ៣០-៣៤ឆ្នាំ | ៨,២ | ៣,៨ | ៥,៥ | ២,៥ | ៥,៧ | ២,៦ | ១០,៨ | ៤,៧ | ៦,៦ | ៣,៤ | ៨,២ | ៣,៩ |
| អាយុ ៣៥-៣៩ឆ្នាំ | ៣,១ | ១,៤ | ១,៩ | ០,៨ | ២,០ | ០,៩ | ៣,៥ | ១,៤ | ២,២ | ១,២ | ២,៧ | ១,៣ |
| អាយុ ៤០-៤៩ឆ្នាំ | ១,៤ | ០,៧ | ០,៩ | ០,៤ | ០,៩ | ០,៥ | ១,៤ | ០,៦ | ១,០ | ០,៦ | ១,២ | ០,៦ |
| អាយុ ៤០ឆ្នាំឡើង | ០,៧ | ០,៦ | ០,៤ | ០,២ | ០,៤ | ០,២ | ០,៤ | ០,១ | ០,៣ | ០,២ | ០,៣ | ០,២ |
| គ្មានទិន្នន័យ | ០,១ | ០,៣ | ០,១ | ០,២ | ០,១ | ០,៣ | ០,០ | ០,០ | ០,០ | ០,១ | ០,០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ២.៤. លទ្ធភាពមានកូន

មានរង្វាស់ជាច្រើនដែលគេប្រើសម្រាប់វាស់វែងលទ្ធភាពមានកូន (Fertility) និងគណនារកអត្រាកំណើតនៃប្រជាជន ដែលរង្វាស់ទាំងនោះខុសគ្នាទៅតាមទិន្នន័យដែលមាន និងទៅតាមវិធីគណនា ដូចជា អត្រាលទ្ធភាពមានកូនសរុប (Total fertility Rate), អត្រាកំណើតដុល (Crude birth rate), អត្រាលទ្ធភាពមានកូនទូទៅ (General fertility rate), ផលធៀបកុមារ-ស្ត្រី (Child-woman ratio) ជាដើម។ របាយការណ៍បច្ចុប្បន្នភាពនេះ ប្រើប្រាស់រង្វាស់មួយចំនួនជាគោល (ដោយគិតតាមទីប្រជុំជន ជនបទ និងសរុប) ដែលរួមមាន៖

១. អត្រាកំណើតដុល ដែលជាចំនួនកំណើតរស់ក្នុងចំណោមប្រជាជន ១.០០០នាក់

២. អត្រាលទ្ធភាពមានកូនទូទៅ ដែលជាចំនួនកំណើតរស់ក្នុង ចំណោមស្ត្រីក្នុងវ័យបន្តពូជអាយុ ១៥-៤៩ឆ្នាំ ១.០០០នាក់

៣. ផលធៀបកុមារ-ស្ត្រី ដែលជាចំនួនកូនអាយុក្រោម៥ឆ្នាំ ក្នុងចំណោម ស្ត្រីក្នុងវ័យបន្តពូជអាយុ ១៥-៤៩ឆ្នាំ ១.០០០នាក់។

៤. អត្រាលទ្ធភាពមានកូនសរុប ដែលជាសូចនាករប្រយោលទាញចេញពីរបាយការណ៍អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០២១-២០២២ (សូមមើលចំណុច ២.៤.៣ ខាងក្រោម)។

### ២.៤.១. អត្រាកំណើតដុល

អត្រាកំណើតដុលត្រូវបានគណនាផ្ទាល់ដោយប្រើទិន្នន័យមានស្រាប់ទាំងស្រុង ដោយមិនបានកែតម្រូវទិន្នន័យទៅតាមកំហុសដែលអាចកើតមានដោយសារការរាយការណ៍ អំពីចំនួនកូននិងអាយុរបស់កូននៅពេលប្រមូលទិន្នន័យទេ។

ជនជាតិដើមភាគតិចមានអត្រាកំណើតដុល ១៨នាក់ក្នុងចំណោមប្រជាជន១.០០០នាក់, អត្រាលទ្ធភាពមានកូនទូទៅ ៦៦នាក់ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ ១.០០០នាក់, និងផលធៀបកុមារ-ស្ត្រីស្មើនឹង៣៨០នាក់ ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ ១.០០០នាក់។ ជារួម ប្រជាជននៅជនបទមានអត្រាកំណើតខ្ពស់ជាងប្រជាជននៅទីប្រជុំជន (តារាងទី១៦)។(អាចថែមតារាងខាងលើយកពីជំរឿន២០០៨)

តារាងទី ១៦.  អត្រាកំណើតនៃជនជាតិដើមភាគតិច ឆ្នាំ២០១៩

| | ទីប្រជុំជន | ជនបទ | សរុប |
|---|---|---|---|
| ចំនួនកូនកើតរស់ក្នុង១២ខែចុងក្រោយ | ១៩៩ | ២,៨៦២ | ៣,០៦១ |
| ចំនួនកូនអាយុក្រោម៥ឆ្នាំ | ៩៣៦ | ១៦,៦៤២ | ១៧,៥៧៨ |
| ចំនួនស្ត្រីអាយុ ១៥-៤៩ឆ្នាំ | ៣,៩៧៦ | ៤២,៣២៦ | ៤៦,៣០២ |
| ចំនួនប្រជាជនសរុប | ១២,៧៣៩ | ១៦០,២៤១ | ១៧២,៩៨០ |
| អត្រាកំណើតដុល | ១៥.៦ | ១៧.៩ | ១៧.៧ |
| អត្រាលទ្ធភាពមានកូនទូទៅ | ៥០.១ | ៦៧.៦ | ៦៦.១ |
| ផលធៀបកុមារ-ស្ត្រី | ២៣៥.៤ | ៣៩៣.២ | ៣៧៩.៦ |

## ២.៤.២. ចំនួនកូនដែលបានបង្កើត

ក្រាភិកទី ១២.  ចំនួនកូនក្នុងចំណោមស្ត្រីរៀបការហើយ១០០នាក់ តាមក្រុមអាយុស្ត្រី




ក្រាភិកខាងក្រោមបង្ហាញពីចំនួនកូនដែលស្ត្រីជនជាតិដើមរៀបការហើយបានបង្កើត គិតតាមក្រុមអាយុ៥ៗឆ្នាំរបស់ស្ត្រីក្នុងវ័យបន្តពូជ និងប្រៀបធៀបនឹងទិន្នន័យឆ្នាំ២០១៣។ ជារួម ចំនួនកូនដែលស្ត្រីជនជាតិដើមបានបង្កើត បានថយចុះនៅគ្រប់ក្រុមអាយុស្ត្រី ក្នុងរវាងឆ្នាំ២០១៣និង២០១៩ លើកលែងតែស្ត្រីអាយុ១៥-១៩ឆ្នាំ ដែលចំនួនកូនបានបង្កើតបានកើនឡើងពី៥១កំណើត មក៦៣កំណើតក្នុងចំណោមស្ត្រីអាយុ១៥-១៩ឆ្នាំ១០០នាក់។ លើសពីនេះទៀត ស្ត្រីនៅជនបទមានចំនួនកូនដែលបានបង្កើតច្រើនជាងស្ត្រី

នៅទីប្រជុំជនគ្រប់ក្រុមអាយុទាំងអស់ ដែលភាពខុសគ្នាមានទំហំធំចំពោះក្រុមស្ត្រីក្នុងក្រុមអាយុ ៣០-៣៤ឆ្នាំ ដល់ក្រុមអាយុ៤០-៤៤ឆ្នាំ។ ជារួម ចំនួនកូនដែលបានបង្កើតជាមធ្យមកើនឡើងតាមអាយុរបស់ស្ត្រី។

### ២.៤.៣. អត្រាលទ្ធភាពមានកូនសរុប

ទិន្នន័យអំពីអត្រាលទ្ធភាពមានកូននិងសុខភាពបន្តពូជរបស់ស្ត្រីកម្ពុជា អាយុ១៥-៤៩ឆ្នាំតាមរាជធានីខេត្តនៃអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០២១-២០២២[១៨] ត្រូវបានយកមកប្រើប្រាស់នៅខាងក្រោមនេះ ដើម្បីជាព័ត៌មានបំពេញបន្ថែមសម្រាប់ស្ត្រីជនជាតិដើមភាគតិច ដែលរស់នៅក្នុងខេត្តដែលមានជនជាតិដើមភាគតិចច្រើន គឺខេត្តរតនគិរី (៤៣,៣២% នៃប្រជាជនខេត្តទាំងអស់) ខេត្តមណ្ឌលគិរី (៣៧,៧៦% នៃប្រជាជនខេត្តទាំងអស់) និងខេត្តក្រចេះ (៤៣,៣២% នៃប្រជាជនខេត្តទាំងអស់)។

ជារួម អត្រាលទ្ធភាពមានកូនសរុបរបស់ស្ត្រីកម្ពុជាវ័យ១៥-៤៩ឆ្នាំ ស្មើនឹង២,៧នាក់នៅឆ្នាំ២០២១-២០២២ (៣,០នៅជនបទ និង២,៤នៅទីប្រជុំជន)។ ស្ត្រីនៅខេត្តរតនគិរី មណ្ឌលគិរី និងស្ទឹងត្រែងធាប់រៀបការ និងធាប់មានកូនជាងស្ត្រីនៅខេត្តឯទៀតទាំងអស់។ ស្ត្រីដែលមានការអប់រំទាប មានសន្ទស្សន៍ទ្រព្យសម្បត្តិតិចតួច និងរស់នៅទីជនបទ មានចំនួនកូនច្រើនជាងស្ត្រីដែលមានការអប់រំខ្ពស់ មានសន្ទស្សន៍ទ្រព្យសម្បត្តិច្រើន និងរស់នៅទីប្រជុំជន។ លើសពីនេះទៀត ៩,២%នៃស្ត្រីអាយុ១៥-១៩ធ្លាប់មានផ្ទៃពោះ ដែលភាគរយនេះមានរហូតដល់៣៥,២%ក្នុងចំណោមស្ត្រីវ័យក្មេងខាងលើ ដែលមិនបានទទួលការអប់រំអ្វីទាំងអស់ ២០,៦%ក្នុងចំណោមស្ត្រីវ័យក្មេងខាងលើដែលបានទទួលការអប់រំត្រឹមកម្រិតបឋមសិក្សា និង១៦,១%ក្នុងចំណោមស្ត្រីវ័យក្មេងខាងលើដែលមានសន្ទស្សន៍ទ្រព្យសម្បត្តិតិចជាងគេ។

ក្រាភិកទី១៣ខាងក្រោមបង្ហាញថា ស្ត្រីកម្ពុជាអាយុ១៥-៤៩ឆ្នាំនៅក្នុងខេត្តមណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ និងរតនគិរី មានចំនួនកូនច្រើនជាងស្ត្រីក្នុងវ័យដូចគ្នាក្នុងខេត្តផ្សេងទៀត ដែលជាមធ្យមក្នុងស្ត្រីម្នាក់មានចំនួន៣,១នាក់នៅខេត្តមណ្ឌលគិរី ២,៩នាក់នៅខេត្តរតនគិរី ៣,៣នាក់នៅខេត្តក្រចេះ ៣,៤នាក់នៅខេត្តស្ទឹងត្រែង និង៣,២នាក់នៅខេត្តព្រះវិហារ។ ក្រាភិកទី១៤ បង្ហាញពីចំនួនកូនជាមធ្យមដែលស្ត្រីម្នាក់ៗបានបង្កើត ដែលមានចំនួន៤,៤នាក់នៅខេត្តមណ្ឌលគិរី ៤,២នាក់នៅខេត្តរតនគិរី ៣,៨នាក់នៅខេត្តស្ទឹងត្រែង ៣,៧នាក់នៅខេត្តព្រះវិហារ និង៣,០នាក់នៅខេត្តក្រចេះ។ ជារួម ស្ត្រីជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ និងរតនគិរី មានកូនច្រើនជាងស្ត្រីកម្ពុជាសរុប ដែលការធាប់រៀបការនិងធាប់មានផ្ទៃពោះនៃស្ត្រីជនជាតិដើមភាគតិចវ័យក្មេង គួរត្រូវគិតគូរ។

---

[១៨] Fertility and Reproductive Health in Cambodia: Further data analysis report from CSDH ២០២១-២០២២, NIS ២០២៤

ក្រាភិកទី ១៣. ផែនទីអត្រាលទ្ធភាពមានកូនឆ្នាំ២០២១-២០២




ក្រាភិកទី ១៤. ចំនួនកូនជាមធ្យមដែលស្ត្រីបានបង្កើត ឆ្នាំ២០២១-២០២២



### ២.៤.៤. ការសម្រាលដោយមានវត្តមានបុគ្គលិកសុខាភិបាល

ទិន្នន័យជំរឿនអំពីវត្តមានបុគ្គលិកសុខាភិបាលនាពេលសម្រាលកូនចុងក្រោយ មានភាគរយនៃអ្នកមិនបានផ្តល់ចម្លើយច្រើនរហូតដល់ជាង៦០% ដែលលទ្ធផលអាចមិនឆ្លុះបញ្ចាំងការពិតនៃបញ្ហាបាន។ ក្រាភិកខាងក្រោម បង្ហាញពីភាគរយនៃស្ត្រីជនជាតិដើមភាគតិចទៅតាមវត្តមាននៃបុគ្គលិកសុខាភិបាល នាពេលសម្រាល ដោយមិនរាប់បញ្ចូលអ្នកមិនបានផ្តល់ចម្លើយ។

ស្ត្រីជនជាតិដើមភាគតិច ដែលសម្រាលដោយមានវត្តមានវេជ្ជបណ្ឌិត/គិលានុបដ្ឋាយិកាឬឆ្មប មានចំនួនតិចជាងភាគរយនៃស្ត្រីកម្ពុជាសរុប (ប្រហែល៦៧% ទល់នឹង ៧៩%) រីឯភាគរយនៃស្ត្រីជនជាតិដើមភាគតិចដែលសម្រាលដោយឆ្មបបុរាណ មានច្រើនជាងភាគរយនៃស្ត្រីកម្ពុជាសរុប (៣២,៦% ទល់នឹង ២,៨%)។ អំបូរធំៗនៃជនជាតិដើមភាគតិច ដែលមានភាគរយច្រើននៃការសម្រាលដោយឆ្មបបុរាណ មានជនជាតិការ៉ែត(៧៧%) ពូនង(៤៤%) គ្រឹង(៣៦%) ព្រៅ(៣៥%) និងចារ៉ាយ(៣១%)។ អំបូរធំៗនៃជនជាតិដើមភាគតិច ដែលមានភាគរយច្រើននៃការសម្រាលដោយវេជ្ជបណ្ឌិត/គិលានុបដ្ឋាយិកា ឬឆ្មប មានជនជាតិស្នៀង(៩៣%) ទំពួន(៨១%) ក្រោល(៨០%) និងកួយ(៧៩%) (ក្រាភិកទី១៥)។

### ២.៤.៥. ការចុះបញ្ជីកំណើតរបស់ទារក

ដូចទិន្នន័យអំពីវត្តមានបុគ្គលិកសុខាភិបាលពេលសម្រាលដែរ ការគ្មានទិន្នន័យ (Not stated category) អំពីការចុះបញ្ជីកំណើតរបស់កុមារអាយុក្រោម១ឆ្នាំ មានចំនួនជិត៧០% ក្នុងចំណោមទារកអាយុក្រោម១២ខែជាសរុប និងប្រហែល៦៧%ក្នុងចំណោមទារកជនជាតិដើមភាគតិច ដែលបង្ហាញពីភាគរយទាបមិនទំនងនៃទិន្នន័យអំពីកុមារដែលបានចុះបញ្ជីកំណើត ទាំងជនជាតិដើមភាគតិចទាំងកម្ពុជាជាសរុប ទាំងនៅជនបទទាំងនៅទីប្រជុំជន។ ទោះយ៉ាងណាក្តី តារាងខាងក្រោម បង្ហាញពីភាគរយកុមារដែលបានចុះបញ្ជីកំណើត ក្នុងចំណោមកុមារដែលមានទិន្នន័យ។

ជារួម កុមារជនជាតិដើមភាគតិចដែលបានចុះបញ្ជីកំណើត មានចំនួនសរុប ១៨% (២០%នៅទីប្រជុំជន និង១៨%នៅជនបទ) ដែលតិចជាងកុមារកម្ពុជាសរុបប្រហែល៤ដង (៨៦%ជាសរុប ៩០%នៅទីប្រជុំជន និង៨៥%នៅជនបទ)។ ក្នុងចំណោមជនជាតិដើមភាគតិចអំបូរធំៗ អំបូរដែលមានភាគរយកុមារបានចុះបញ្ជីកំណើតច្រើនជាងគេ គឺកួយ ព្រៅ និងចារ៉ាយ។ រីឯអំបូរដែលមានភាគរយកុមារបានចុះបញ្ជីកំណើតតិចជាងគេ មានក្រោលនិងការ៉ែត (ក្រាភិកទី១៦)។

ក្រាភិកទី ១៥. វត្តមានបុគ្គលិកសុខាភិបាលពេលសម្រាល




ក្រាភិកទី ១៦. ភាគរយបានចុះបញ្ជីកំណើត



## ២.៥. មរណភាព

មរណភាពនៃប្រជាជនជនជាតិដើមភាគតិច ត្រូវបានគណនាដោយប្រើប្រាស់ទិន្នន័យ២ប្រភេទរបស់ជំរឿន២០១៩ គឺ ១) ចំនួនកូនដែលស្ត្រីបានបង្កើតនិងចំនួនកូនដែលនៅរស់ទៅតាមក្រុមអាយុរបស់ស្ត្រី និង ២) កំណត់ត្រាមរណភាពនៅក្នុងគ្រួសារក្នុងអំឡុង១២ខែមុនពេលធ្វើជំរឿន (Death Records: Deaths in the households in the 12 months) ដោយភ្ជាប់អត្តសញ្ញាណគ្រួសារជាជនជាតិដើមភាគតិច រវាងទិន្នន័យគ្រួសារជនជាតិដើមភាគតិចនិងកំណត់ត្រាមរណភាពនៅក្នុងគ្រួសារនីមួយៗ។ នៅក្នុងកំណត់ត្រាមរណភាព មានអ្នកស្លាប់សរុបចំនួន ៤២.៤៦៤នាក់ ដែលក្នុងនោះ ជនជាតិដើមភាគតិចមានចំនួន ៦១៥នាក់។

ដោយបំបែកទៅតាមទីកន្លែងរស់នៅ ការវិភាគអំពីមរណភាពដែលកើតមានក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច ផ្តោតទៅលើ៖

១. មរណភាពកុមារ (គឺរួមមានមរណភាពទារកអាយុក្រោម១ឆ្នាំ មរណភាពកុមារអាយុ១ឆ្នាំដល់អាយុក្រោម៥ឆ្នាំ និងមរណភាពកុមារអាយុក្រោម៥ឆ្នាំ)

២. មរណភាពតាមក្រុមអាយុជាក់លាក់ និង

៣. មូលហេតុនៃមរណភាព

### ២.៥.១. មរណភាពកុមារ

មរណភាពកុមារ គឺជាមរណភាពដែលកើតមានក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច អាយុក្រោម៥ឆ្នាំ ដែលចែកជាមរណភាពទារកអាយុក្រោម១ឆ្នាំ មរណភាពកុមារអាយុ១ឆ្នាំដល់អាយុក្រោម៥ឆ្នាំ និងមរណភាពកុមារអាយុក្រោម៥ឆ្នាំ។ អត្រាមរណភាពកុមារ ត្រូវបានគណនាទៅតាមទីប្រជុំជននិងជនបទតាមរយៈកម្មវិធី QFive[១៩] នៃ MortPak Software របស់អង្គការសហប្រជាជាតិ ដោយប្រើប្រាស់ទិន្នន័យអំពីចំនួនកូនដែលស្ត្រីបានបង្កើត[២០] (Children ever born) និងចំនួនកូនដែលនៅរស់ (Children

[១៩] Coale-Demny North Model.

[២០] អាចរាយការណ៍ពីចំនួនមិនអស់ ដូចបានទទួលស្គាល់នៅក្នុងរបាយការណ៍ជំរឿន។

surviving) ទៅក្រុមអាយុរបស់ស្ត្រី។ ក្រាភិកទី១៧ខាងក្រោមបង្ហាញពីលទ្ធផលនៃមរណភាពកុមាររបស់ជនជាតិដើមភាគតិច និងរបស់ប្រជាជនសរុប[២១] សម្រាប់ជាការប្រៀបធៀប។

ក្រាភិកទី ១៧. អត្រាមរណភាពកុមារៈ ជនជាតិដើមភាគតិច




អត្រាមរណភាពទារកនៃជនជាតិដើមភាគតិច ជាសរុបមានចំនួន៣១,៨នាក់ក្នុងចំណោមកំណើត ១.០០០នាក់ (២៣,៣នាក់នៅទីប្រជុំជន និង៣២,៣នាក់នៅជនបទ) ធៀបនឹងអត្រាមរណភាពទារកកម្ពុជាសរុបចំនួន១៧,៦នាក់។ អត្រាមរណភាពកុមារអាយុ១ឆ្នាំដល់អាយុក្រោម៥ឆ្នាំ នៃប្រជាជនជនជាតិដើមភាគតិច ជាសរុបមានចំនួន១១,៨នាក់ (៧,៧នាក់នៅទីប្រជុំជន និង១២,២នាក់នៅជនបទ) ធៀបនឹងកម្ពុជាសរុបចំនួន១០,៥នាក់។ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ជាសរុបមានចំនួន៤៣,៦នាក់ (៣១,០នាក់នៅទីប្រជុំជន និង៤៤,៥នាក់នៅជនបទ) ធៀបនឹងកម្ពុជាសរុបចំនួន២៨,១នាក់។ ជារួមជនជាតិដើមភាគតិចមានអត្រាមរណភាពវ័យក្មេងខ្ពស់នៅជនបទជាងនៅទីប្រជុំជន និងខ្ពស់ជាងប្រជាជនកម្ពុជាទូទៅ។

[២១] របាយការណ៍ជំរឿន២០១៩។

### ៥.២.២. មរណភាពនៃប្រជាជនជនជាតិដើមភាគតិចតាមក្រុមអាយុជាក់លាក់

គិតតាមក្រុមអាយុជាក់លាក់ អត្រាមរណភាពដុលមានចំនួនខ្ពស់ជាងគេក្នុងចំណោមទារកអាយុក្រោម១ឆ្នាំ និងទាបជាងគេក្នុងចំណោមក្រុមអាយុ១៥-២៩ឆ្នាំ ទាំងនៅជនបទទាំងនៅទីប្រជុំជន។ អត្រាមរណភាពដុលចាប់ផ្តើមកើនតិចតួចពីក្រុមអាយុ៣០-៤៤ឆ្នាំទៅ រហូតដល់វ័យចាស់អាយុ៦០ឆ្នាំឡើង។

ក្រាភិកទី ១៨. អត្រាមរណភាពដុលតាមក្រុមអាយុជាក់លាក់




### ៥.២.៣. មូលហេតុនៃការស្លាប់

មូលហេតុនៃការស្លាប់ ត្រូវបានទាញចេញទាំងស្រុងពីកំណត់ត្រាមរណភាពនៃជំរឿន២០១៩។ នៅក្នុងរបាយការណ៍នេះ មូលហេតុនៃការស្លាប់ត្រូវបានបំបែកសម្រាប់កុមារអាយុក្រោម៥ឆ្នាំ ក្នុងគោលបំណងពិនិត្យរកមូលហេតុចម្បងនៃការស្លាប់របស់កុមារ និងសម្រាប់ប្រជាជនសរុបទូទៅ[២២] ទៅតាមទីប្រជុំជននិងជនបទ។

[២២] ចំពោះមរណភាពមាតា កំណត់ត្រាមរណភាពពុំមានស្ត្រីជនជាតិដើមភាគតិចណាម្នាក់ដែលត្រូវបានរាយការណ៍ថា ស្លាប់ដោយសារការផ្តល់កំណើតឡើយ។

ក្រាភិកទី ១៩. មូលហេតុនៃការស្លាប់របស់កុមារជនជាតិដើមភាគតិចអាយុក្រោម៥ឆ្នាំ




ក្នុងចំណោមមរណភាពកុមារអាយុក្រោម៥ឆ្នាំនៅទីប្រជុំជន (ក្រាភិកទី១៦) មូលហេតុនៃការស្លាប់ជាចម្បងគឺ គ្រោះថ្នាក់ផ្សេងៗ រួមមានការលង់ទឹកនិងគ្រោះថ្នាក់ចរាចរណ៍ (១/៣នៃកុមារ), ជំងឺគ្រុនក្ដៅ (២២,២%), ជំងឺរបេង (២២,២%) និងជំងឺតេតាណូស (១១,១%)។ ក្នុងចំណោមមរណភាពកុមារអាយុក្រោម៥ឆ្នាំនៅជនបទ មូលហេតុនៃការស្លាប់ជាចម្បងគឺ ជំងឺគ្រុនក្ដៅ (៣៥%), ជំងឺរាគរូស (១២,២%), ជំងឺគ្រុនឈាម (៨,៩%), និងជំងឺគ្រុនចាញ់ (៣,៨%)។

មូលហេតុចម្បងៗនៃមរណភាពជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង (ក្រាភិកទី២០) គឺជំងឺគ្រុនក្ដៅ (២៥%នៅទីប្រជុំជន និង២៣,៧%នៅជនបទ), ជំងឺរាគរូស (១៥,៦% នៅទីប្រជុំជន និង១៩,៩% នៅជនបទ), គ្រោះថ្នាក់ផ្សេងៗ (១៨,៨%នៅទីប្រជុំជន និង៥,៣%នៅជនបទ), ជំងឺគ្រុនឈាមនិងជំងឺបេះដូង (ប្រហែល៦-៧%នៃជំងឺនីមួយៗ ទាំងនៅទីប្រជុំជនទាំងនៅជនបទ), ជំងឺរបេង (៦,៣%នៅទីប្រជុំជន និង៤,៥%នៅជនបទ) និងជំងឺផ្សេងទៀត (១៥,៦%នៅទីប្រជុំជន និង ២១,១%នៅជន បទ)។

ជាសរុប មរណភាពនៃប្រជាជនជនជាតិដើមភាគតិច ទាំងកុមារទាំងមនុស្សពេញវ័យ ច្រើនបណ្ដាលមកពីជំងឺគ្រុនក្ដៅនិងជំងឺរាគរូស ទាំងនៅទីប្រជុំជនទាំងនៅជនបទ ដោយមិនរាប់បញ្ចូលគ្រោះថ្នាក់ផ្សេងៗ និងជំងឺផ្សេងទៀតដែលមិនបានបញ្ជាក់។

ក្រាភិកទី ២០. មូលហេតុនៃការស្លាប់របស់ជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង




## ២.៦. ទេសន្តរប្រវេសន៍

ទេសន្តរប្រវេសន៍ គឺជាដំណើរផ្លាស់ប្ដូរទីកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយ ទៅភូមិសាស្ត្រមួយទៀត។ ក្នុងរបាយការណ៍នេះ ជនទេសន្តរប្រវេសន៍គឺជាមនុស្សទាំងឡាយ ដែលមានទីកន្លែងរស់នៅនាមុនពេលធ្វើអង្កេត ខុសពីទីកន្លែងរស់នៅនាពេលធ្វើអង្កេត។

### ២.៦.១. ចំនួននិងភាគរយជនទេសន្តរប្រវេសន៍

ជនជាតិដើមភាគតិចមិនសូវមានចលនាទេសន្តរប្រវេសន៍ដូចប្រជាជនកម្ពុជាជារួមទេ ពិសេសក្នុងចំណោមប្រជាជននៅជនបទ (យោងតាមទិន្នន័យឆ្នាំ២០១៩)។ ដោយមិនគិតពីរយៈពេលដែលបានធ្វើ

ទេសន្តរប្រវេសន៍ ជនជាតិដើមភាគតិចចំនួន ១០.៤៤៥នាក់ (ប្រុសចំនួន៥.៩៨១នាក់ និងស្រីចំនួន ៤.៤៦៤នាក់) ជាជនទេសន្តរប្រវេសន៍ ដែលស្មើនឹង៦%នៃជនជាតិដើមភាគតិចទាំងអស់ (៧%ក្នុងចំណោមបុរស និង៥%ក្នុងចំណោមស្ត្រី)។ គិតតាមទីកន្លែងរស់នៅនាពេលធ្វើជំរឿន ជនទេសន្តរប្រវេសន៍រស់នៅទីប្រជុំជនមានចំនួន ៣.១៧៨នាក់ (ស្មើនឹង២៥% នៃជនជាតិដើមភាគតិចនៅទីប្រជុំជនទាំងអស់) និងនៅជនបទចំនួន១.៦១៣នាក់ (ស្មើនឹង៤,៥% នៃជនជាតិដើមភាគតិចនៅជនបទទាំងអស់) (តារាងទី១៧ខាងក្រោម)។

តារាងទី ១៧. ចំនួននិងភាគរយជនទេសន្តរប្រវេសន៍ តាមភេទនិងទីកន្លែងរស់នៅ៖ ឆ្នាំ២០១៩

| | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| **កម្ពុជា (ចំនួនគិតជាពាន់)** | | | | | | |
| ទីប្រជុំជន | ១.១០១ | ១.០៦៨ | ២.១៦៨ | ៣៦,៨ | ៣៤,០ | ៣៥,៣ |
| ជនបទ | ៦៥២ | ៥១៨ | ១.១៧០ | ១៤,២ | ១០,៧ | ១២,៤ |
| សរុប | ១.៧៥២ | ១.៥៨៦ | ៣.៣៣៨ | ២៣,១ | ១៩,៩ | ២១,៥ |
| **ជនជាតិដើមភាគតិច** | | | | | | |
| ទីប្រជុំជន | ១.៦១៣ | ១.៥៦៥ | ៣.១៧៨ | ២៦,៣ | ២៣,៧ | ២៤,៩ |
| ជនបទ | ៤.៣៦៨ | ២.៨៩៩ | ៧.២៦៧ | ៥,៥ | ៣,៦ | ៤,៥ |
| សរុប | ៥.៩៨១ | ៤.៤៦៤ | ១០.៤៤៥ | ៧,០ | ៥,១ | ៦,០ |

ក្នុងចំណោមជនទេសន្តរប្រវេសន៍ជាជនជាតិដើមភាគតិច ភាគរយនៃជនទេសន្តរប្រវេសន៍ក្នុងអំឡុង ៥ឆ្នាំចុងក្រោយមុនពេលធ្វើអង្កេត មានចំនួន៤៨% នៃជនជាតិដើមភាគតិចជាជនទេសន្តរប្រវេសន៍នៅទីប្រជុំជន (៥០%ក្នុងចំណោមបុរស និង៤៧%ក្នុងចំណោមស្ត្រី) និង៤១%នៃជនជាតិដើមភាគតិច ជាជនទេសន្តរប្រវេសន៍នៅជនបទ (៤៣%ក្នុងចំណោមបុរស និង៣៨%ក្នុងចំណោមស្ត្រី)។ តួលេខនេះ បង្ហាញថា ចលនាផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិចកើតមានច្រើនក្នុងអំឡុង៥ឆ្នាំចុងក្រោយ ជាពិសេសក្នុងចំណោមបុរស (ក្រាភិកទី២១)។

ក្រាភិកទី ២១. ភាគរយទេសន្តរប្រវេសន៍ក្នុងអំឡុង៥ឆ្នាំចុងក្រោយ




## ២.៦.២. លំហូរទេសន្តរប្រវេសន៍

លំហូរទេសន្តរប្រវេសន៍ គឺជាដំណើរផ្លាស់ទីលំនៅរវាងទីប្រជុំជននិងជនបទ ដែលចែកចេញជាដំណើរផ្លាស់ទីលំនៅ៖ ១. ពីទីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត, ២. ពីជនបទទៅទីប្រជុំជន, ៣. ពីជនបទមួយទៅជនបទមួយទៀត, និង ៤. ពីទីប្រជុំជនទៅជនបទ។ ជារួម លំហូរផ្លាស់ទីពីជនបទមួយទៅជនបទមួយទៀតមានច្រើនជាងគេ ទាំងក្នុងចំណោមបុរសនិងស្ត្រី និងគ្រប់រយៈពេលនៃការតាំងលំនៅចុងក្រោយ។ ក៏ប៉ុន្តែ ស្ត្រីមានទំនោរផ្លាស់ទីឆ្ពោះទៅកាន់ទីប្រជុំជនច្រើនជាងបុរស ទាំងពីជនបទទៅទីប្រជុំជន ទាំងពីទីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត និងគ្រប់រយៈពេលនៃការតាំងលំនៅចុងក្រោយ។ ក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនៃការផ្លាស់ទី ភាគរយនៃស្ត្រីដែលផ្លាស់ទីពីជនបទទៅទីប្រជុំជនមានចំនួន៣០,៣% (ធៀបនឹងបុរសដែលមានចំនួន២៣,២%) និងភាគរយស្ត្រីដែលផ្លាស់ទីពីទីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត មានចំនួន១៣,២% (ធៀបនឹងបុរសដែលមានចំនួន៨,០%) (ក្រាភិកទី២២)។

ក្រាភិកទី ២២. លំហូរទេសន្តរប្រវេសន៍ តាមភេទនិងរយៈពេលតាំងលំនៅ




### ២.៦.៣. មូលហេតុទេសន្តរប្រវេសន៍

តារាងទី១៨ខាងក្រោម បង្ហាញពីរបាយភាគរយនៃមូលហេតុទេសន្តរប្រវេសន៍របស់ជនជាតិដើមភាគតិច បែងចែកតាមភេទ ក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៩។ មូលហេតុពាក់ព័ន្ធនឹងគ្រួសារ នៅតែជាមូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍នៅឆ្នាំ២០១៩ ដែល៣៤%នៃទេសន្តរប្រវេសន៍ផ្លាស់ទីតាមគ្រួសារ (ពិសេសក្នុងចំណោមស្ត្រី ដែលមានចំនួន ៤៣,៨%) និង៣០,៧% នៃទេសន្តរប្រវេសន៍ផ្លាស់ទីព្រោះការរៀបអាពាហ៍ពិពាហ៍ (ពិសេសក្នុងចំណោមបុរស ដែលមានចំនួន៣៨%)។ មូលហេតុចម្បងទីពីរ នៃការធ្វើទេសន្តរប្រវេសន៍នៅឆ្នាំ២០១៩ គឺទាក់ទងជាមួយនឹងការងារ រួមមានការស្វែងរកការងារធ្វើ និងការផ្ទេរកន្លែងធ្វើការ ដែលមានចំនួនកើនឡើងបើធៀបនឹងឆ្នាំ២០១៣។ ភាគរយអ្នកផ្លាស់ព្រោះស្វែងរកការងារ ធ្វើបានកើនពី១០%នៅឆ្នាំ២០១៣ ដល់១៥,២%នៅឆ្នាំ២០១៩ (ក្នុងចំណោមស្ត្រីទេសន្តរប្រវេសន៍កើន ពី ១១,៨%ដល់១៥% និងក្នុងចំណោមបុរសទេសន្តរប្រវេសន៍ កើនពី៨%ដល់១៥,៤%)។ ភាគរយអ្នកផ្លាស់ទីព្រោះផ្លាស់ប្តូរទីកន្លែងធ្វើការ បានកើនពី១,៧%នៅឆ្នាំ២០១៣ ដល់៧,៥%នៅឆ្នាំ២០១៩ (កើនពី

០,៦% ដល់៥,៨%ក្នុងចំណោមស្ត្រីទេសន្តរប្រវេសន៍ និងកើនពី២,៧% ដល់៨,៩%ក្នុងចំណោមបុរសទេសន្តរប្រវេសន៍)។ រីឯមូលហេតុទី៣ គឺជាការសិក្សា ដែលកើនពី០,៤%នៅឆ្នាំ២០១៣ ដល់៤,៣%នៅឆ្នាំ២០១៩ (កើនពី០,១% ដល់៥% ក្នុងចំណោមស្ត្រីទេសន្តរប្រវេសន៍ និងកើនពី០,៦% ដល់៣,៧% ក្នុងចំណោមបុរសទេសន្តរប្រវេសន៍)។

តារាងទី ១៨. មូលហេតុនៃទេសន្តរប្រវេសន៍

| មូលហេតុទេសន្តរប្រវេសន៍របស់ជនជាតិដើមភាគតិច | ២០១៩ | | | ២០១៣ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ផ្លាស់ទីទាំងគ្រួសារ | ២៦,៧ | ៤៣,៨ | ៣៤,០ | ៤១,៨ | ៦១,០ | ៥១,២ |
| រៀបការ | ៣៨,០ | ២១,០ | ៣០,៧ | ៣២,១ | ៩,១ | ២០,៩ |
| ស្វែងរកការងារ | ១៥,៤ | ១៥,០ | ១៥,២ | ៨,០ | ១១,៨ | ៩,៩ |
| ផ្ទេរកន្លែងធ្វើការ | ៨,៩ | ៥,៨ | ៧,៥ | ២,៧ | ០,៦ | ១,៧ |
| សិក្សា | ៣,៧ | ៥,០ | ៤,៣ | ០,៦ | ០,១ | ០,៤ |
| ការវិលមកស្រុកវិញ | ២,០ | ៣,១ | ២,៥ | ១០,៤ | ៩,៧ | ១០,១ |
| ផ្សេងទៀត | ២,៨ | ១,៥ | ២,២ | ០,០ | ០,០ | ០,០ |
| មកលេង | ១,១ | ១,៧ | ១,៣ | ១,៣ | ១,២ | ១,២ |
| បាត់បង់ផ្ទះឬដីធ្លី | ០,៥ | ១,១ | ០,៨ | ២,៨ | ០,៥ | ១,៧ |
| អសន្តិសុខ | ០,៤ | ១,០ | ០,៧ | ០,២ | ៣,០ | ១,៦ |
| ប្តូរកន្លែងរស់នៅដោយសារគម្រោងអភិវឌ្ឍន៍ | ០,៣ | ០,៦ | ០,៤ | ០,០ | ០,០ | ០,០ |
| បាត់បង់ឪពុកម្តាយ | ០,៣ | ០,៤ | ០,៣ | ០,០ | ៣,០ | ១,៥ |
| គ្រោះធម្មជាតិ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| **ចំនួនអ្នកផ្លាស់ទី** | **៥.៩៨១** | **៤.៤៦៤** | **១០.៤៤៥** | **៩.២៨០** | **៨.៨៩៤** | **១៨.១៧៤** |

## ២.៦.៤. របាយអាយុនិងកម្រិតវប្បធម៌ជនទេសន្តរប្រវេសន៍១០ឆ្នាំចុងក្រោយ

នៅក្នុងបរិបទនៃការអភិវឌ្ឍន៍ ទេសន្តរប្រវេសន៍ជាដំណើរការសម្រាំងមួយ (Selective process) ដែលជនទេសន្តរប្រវេសន៍ភាគច្រើនជាមនុស្សវ័យក្មេង មានបណ្តាញទេសន្តរប្រវេសន៍ និងមានសក្តានុពលក្នុងការធ្វើទេសន្តរប្រវេសន៍។ ក្រាភិកខាងក្រោមបង្ហាញថា ភាគច្រើនលើសលប់នៃជនទេសន្តរប្រវេសន៍ជនជាតិដើមភាគតិច គឺជាមនុស្សវ័យក្មេងដែលជាវ័យពាក់ព័ន្ធនឹងការរៀនសូត្រ ការរៀបការ និងការងារ គឺ

ក្នុងក្រុមអាយុ ២០-២៩ឆ្នាំ (៤១,២%ក្នុងចំណោមបុរស និង៣៣,៦%ក្នុងចំណោមស្ត្រី) បន្ទាប់មកគឺក្រុមអាយុ៣០-៣៤ឆ្នាំ (១៥,២%ក្នុងចំណោមបុរស និង១២,០%ក្នុងចំណោមស្ត្រី)។ រីឯភាគរយក្នុងក្រុមអាយុ១៥-១៩ឆ្នាំ មានចំនួន៨,៨%ក្នុងចំណោមបុរស និង១២,០%ក្នុងចំណោមស្ត្រី។

ក្រាភិកទី ២៣. របាយអាយុនៃជនទេសន្តរប្រវេសន៍ក្នុងអំឡុង១០ឆ្នាំចុងក្រោយ




ក្រាភិកទី២៤ ខាងក្រោម បង្ហាញពីរបាយភាគរយនៃកម្រិតសិក្សាអប់រំរបស់ជនជាតិដើមភាគតិច ដែលបានធ្វើទេសន្តរប្រវេសន៍ក្នុងស្រុក ក្នុងកំឡុង១០ឆ្នាំចុងក្រោយ ដោយបែងចែកតាមភេទ។ ជារួម របាយភាគរយនៃកម្រិតសិក្សាអប់រំ មានភាពខុសគ្នាតិចតួចរវាងបុរសនិងស្ត្រីជនជាតិដើមភាគតិច ដែលបានធ្វើទេសន្តរប្រវេសន៍ក្នុងកំឡុង១០ឆ្នាំចុងក្រោយ។ ជាសរុប អ្នកមិនបានរៀនសោះឬរៀនមិនចប់កម្រិតបឋមសិក្សាមានប្រហែល៤២% (៤០,៦%ក្នុងចំណោមបុរស និង៤៥,១%ក្នុងចំណោមស្ត្រី) អ្នកបានរៀនត្រឹមថ្នាក់ទី៦ដល់ទី៨មាន២៧,៣% អ្នកបានរៀនត្រឹមថ្នាក់ទី ៩ដល់ទី១២មានជិត២១% អ្នកមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានជិត៥% (%ប្រហែលគ្នារវាង បុរសនិងស្ត្រី) និងអ្នកបានរៀនដល់

កម្រិតឧត្តមសិក្សាមានជិត៤% (៤,១% ក្នុងចំណោមបុរស និង២,៧% ក្នុងចំណោមស្ត្រី)។ ដោយឡែកអ្នកដែលទទួលបានការបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈ មានចំនួនតិចជាង ១%។

ក្រាភិកទី ២៤. កម្រិតសិក្សាអប់រំនៃជនទេសន្តរប្រវេសន៍ក្នុងកំឡុង១០ឆ្នាំចុងក្រោយ



## ២.៧. ប្រជាជនវ័យចាស់

### ២.៧.១. ចំនួននិងភាគរយប្រជាជនវ័យចាស់

ប្រជាជនវ័យចាស់ គឺជាប្រជាជនអាយុ៦០ឆ្នាំឡើង។ ជនជាតិដើមភាគតិច មានប្រជាជនវ័យចាស់សរុបចំនួន ១០.៣៨៥នាក់នៅឆ្នាំ២០១៩ ស្មើនឹង៦%នៃប្រជាជនជនជាតិដើមភាគតិចសរុប (ដែលស្ត្រីមានចំនួន ៥.៨២២នាក់ ស្មើនឹង៥៦,១%) (តារាងទី១៩)។ ធៀបនឹងឆ្នាំ២០០៨ ប្រជាជនវ័យចាស់ ក្នុងចំណោមជនជាតិដើមភាគតិចកើនឡើងតិចតួច ពី៥,៤%នៅឆ្នាំ២០០៨ (៥%ក្នុងចំណោមបុរស និង៥,៧%ក្នុងចំណោមស្ត្រី) មកត្រឹម៦,០%នៅឆ្នាំ២០១៩ (៥,៤%ក្នុងចំណោមបុរស និង៦,៦%ក្នុងចំណោមស្ត្រី)។ ក៏ប៉ុន្តែ ភាគរយស្ត្រីវ័យចាស់នៅបន្តមានច្រើនជាងភាគរយបុរសវ័យចាស់។

នៅឆ្នាំ២០១៩ ភាគរយប្រជាជនវ័យចាស់នៃជនជាតិដើមភាគតិចជាសរុប មានចំនួនប្រហែល ៣ពិន្ទុភាគរយ តិចជាងភាគរយប្រជាជនវ័យចាស់កម្ពុជាសរុប (៦%ទល់នឹង៨,៩%) និងមានកំណើនឆ្នាំ២០០៨-២០១៩ ប្រហែល៤ដងតិចជាងកំណើនប្រជាជនវ័យចាស់កម្ពុជាសរុប (បម្រែបម្រួល០,៦%ទល់នឹង២,៥%)។ នេះបង្ហាញថា ជនជាតិដើមភាគតិចអាយុ៦០ឆ្នាំឡើង មានអត្រាកំណើតយឺតជាងប្រជាជនកម្ពុជាវ័យចាស់។

តារាងទី ១៩. ចំនួននិងភាគរយប្រជាជនវ័យចាស់ ឆ្នាំ២០០៨និង២០១៩

| | | ជនជាតិដើមភាគតិច | | | កម្ពុជា | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | បម្រែបម្រួល ២០០៨-២០១៩ | ចំនួន | ភាគរយ | បម្រែបម្រួល ២០០៨-២០១៩ |
| ២០០៨ | ប្រុស | ៤.៤៣០ | ៥,០ | | ៣៤៦.៩២៣ | ៥,៣ | |
| | ស្រី | ៥.២២១ | ៥,៧ | | ៥០១.៩៨៨ | ៧,៣ | |
| | សរុប | ៩.៦៥១ | ៥,៤ | | ៨៤៨.៩១១ | ៦,៣ | |
| ២០១៩ | ប្រុស | ៤.៥៦៣ | ៥,៤ | ០,៣ | ៥៤៩.៤៨១ | ៧,៣ | ១,៩ |
| | ស្រី | ៥.៨២២ | ៦,៦ | ០,៩ | ៨២៩.២០៧ | ១០,៤ | ៣,១ |
| | សរុប | ១០.៣៨៥ | ៦,០ | ០,៦ | ១.៣៧៨.៦៨៨ | ៨,៩ | ២,៥ |

### ២.៧.២. ប្រជាជនវ័យចាស់តាមអំបូរជនជាតិដើមភាគតិច

ទោះជាជនជាតិដើមភាគតិចមានភាគរយប្រជាជនវ័យចាស់តិចគិតជារួម ក៏មានអំបូរជនជាតិដើមភាគតិចខ្លះ (ពិសេសអំបូរតូចឬមធ្យម) មានភាគរយប្រជាជនវ័យចាស់ច្រើនគួរឱ្យកត់សម្គាល់។ ជាក់ស្តែងអំបូរដែលមានប្រជាជនវ័យចាស់ច្រើន គឺមិល ដែលមានមនុស្សចាស់១៣,៣% (១២,២% ក្នុងចំណោមបុរស និង១៤,៤%ក្នុងចំណោមស្ត្រី), រអង ១២,៩% (៨,៤%ក្នុងចំណោមបុរស និង១៦,១%ក្នុងចំណោមស្ត្រី), ព័រ ១១,៩% (១១,៣%ក្នុងចំណោមបុរស និង១២,៤%ក្នុងចំណោមស្ត្រី), សួយ ១០,១% (៦,៩%ក្នុងចំណោមបុរស និង១២,៩%ក្នុងចំណោមស្ត្រី), ស្ទៀង ៨,៨% (៧,១%ក្នុង ចំណោមបុរស និង១០,៤%ក្នុងចំណោមស្ត្រី), និងកួយ ៧,៩% (៦,១%ក្នុងចំណោមបុរស និង៩,៧% ក្នុងចំណោមស្ត្រី)។

តារាងទី ២០. ប្រជាជនវ័យចាស់តាមអំបូរជនជាតិដើមភាគតិច

| | ចំនួន មនុស្សវ័យចាស់ | ភាគរយ សរុប | ភាគរយ ក្នុងចំណោមប្រុស | ភាគរយ ក្នុងចំណោមស្រី |
|---|---|---|---|---|
| ទំពួន | ១.៧៦៥ | ៤,៩ | ៤,៨ | ៤,៩ |
| ពូនង | ១.៦១១ | ៤,៤ | ៤,១ | ៤,៧ |
| ចារ៉ាយ | ១.៥៧០ | ៥,៨ | ៥,២ | ៦,៥ |
| គ្រឹង | ១.៥២០ | ៧,១ | ៦,៨ | ៧,៤ |
| កួយ | ១.៣២៨ | ៧,៩ | ៦,១ | ៩,៧ |
| ព្រៅ | ៦៦៣ | ៦,៦ | ៦,១ | ៧,០ |
| កាវ៉ែត | ៤៧៨ | ៦,៣ | ៥,១ | ៧,៤ |
| ស្ទៀង | ៤៣២ | ៨,៨ | ៧,១ | ១០,៤ |
| ក្រោល | ២៨០ | ៥,០ | ៤,៣ | ៥,៦ |
| មិល | ១៣១ | ១៣,៣ | ១២,២ | ១៤,៤ |
| ព័រ | ១១២ | ១១,៩ | ១១,៣ | ១២,៤ |
| សួយ | ៧៨ | ១០,១ | ៦,៩ | ១២,៩ |
| លុន | ៧៦ | ៧,៤ | ៤,៨ | ៩,៩ |
| រអង | ៧៤ | ១២,៩ | ៨,៤ | ១៦,១ |
| ថ្មូន | ៧០ | ៦,០ | ៥,០ | ៧,០ |
| ជនជាតិដើមផ្សេងទៀត | ១៩៧ | ១៦,២ | ១១,៩ | ២០,៨ |
| សរុប | ១០.៣៨៥ | ៦,០ | ៥,៤ | ៦,៦ |

រីឯអំបូរជនជាតិដើមភាគតិចដែលមានភាគរយប្រជាជនវ័យចាស់តិចជាងគេ គឺពូនង (សរុប ៤,៤% និង ៤,១%ក្នុងចំណោមបុរស និង៤,៧%ក្នុងចំណោមស្ត្រី) បន្ទាប់មកគឺទំពួន (សរុប៤,៩% និង ៤,៤%ក្នុងចំណោមបុរស និង៤,៩%ក្នុងចំណោមស្ត្រី)។

### ២.៧.៣. ស្ថានភាពអាពាហ៍ពិពាហ៍នៃប្រជាជនវ័យចាស់

គិតតាមស្ថានភាពអាពាហ៍ពិពាហ៍ ភាគច្រើននៃជនជាតិដើមភាគតិចវ័យចាស់ ជាអ្នករៀបការនិងរស់នៅជាមួយគ្នា (៧៣,៧%)។ ប្រជាជនវ័យចាស់ដែលជាអ្នកមេម៉ាយឬពោះម៉ាយ មានចំនួន១៨,៤% អ្នកមិនដែលរៀបការមានចំនួនជិត៥% និងអ្នករស់នៅបែកគ្នាមានចំនួនជិត៣%។ ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិចវ័យចាស់ ខុសគ្នាទៅតាមភេទ ដែលបុរសវ័យចាស់រៀបការនិងរស់នៅជាមួយគ្នាមានចំនួនជិត៩០% ធៀបនឹង៦១,១%នៃស្ត្រីក្នុងស្ថានភាពដូចគ្នា។ ស្ត្រីវ័យចាស់ដែលមេម៉ាយមានចំនួនដល់ទៅជិត៣០% ធៀបនឹងបុរសពោះម៉ាយដែលមានត្រឹម៦%។ លើសពីនេះ ស្ត្រីវ័យចាស់ដែលមិនដែលរៀបការឬរស់នៅបែកគ្នា ក៏មានចំនួនច្រើនជាងបុរសប្រហែល៣ដង។

ក្រាភិកទី ២៥. ស្ថានភាពអាពាហ៍ពិពាហ៍នៃប្រជាជនវ័យចាស់ជនជាតិដើមភាគតិច



### ២.៧.៤. ជនជាតិដើមភាគតិចវ័យចាស់តាមរាជធានីខេត្ត

ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ និងស្ទឹងត្រែង គឺជាខេត្តទាំង៥ដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ។ ថ្វីបើខេត្តទាំង៥នេះក៏មានជនជាតិដើមភាគតិចវ័យចាស់ច្រើនផងដែរ បើគិតជាចំនួន (តារាងទី២១ កូឡោនទី៥) តែជាខេត្តដែលមានភាគរយជនជាតិដើមភាគតិចវ័យចាស់តិចជាងរាជធានីខេត្តឯទៀតដែលមានជនជាតិដើមភាគតិចរស់នៅ គឺប្រហែលពី៤%ទៅ៧%ក្នុងខេត្តនីមួយៗនៃខេត្តទាំង៥ ទល់នឹង៩%ទៅ១៩,៤%រៀងគ្នានៅខេត្តឯទៀត, តារាងទី ២០ កូឡោមទី៤។ មានន័យថាជនជាតិដើមភាគតិចនៅក្នុងខេត្តទាំង៥ នៅបន្តជាប្រជាជនវ័យក្មេងជាងនៅក្នុងខេត្តដទៃ។

តារាងទី ២១. ប្រជាជនវ័យចាស់តាមរាជធានីខេត្ត

| ១. រាជធានីខេត្ត | ២. ចំនួនសរុប | ៣. ចំនួនមនុស្សចាស់ | ៤. ភាគរយមនុស្សចាស់ក្នុងរាជធានីខេត្ត | ៥. របាយភាគរយមនុស្សចាស់តាមរាជធានីខេត្ត |
|---|---:|---:|---:|---:|
| រតនគិរី | ៩៤.២០៤ | ៥.១៦៥ | ៥,៥ | ៤៩,៧ |
| មណ្ឌលគិរី | ៣១.១២៨ | ១.២៨៦ | ៤,១ | ១២,៤ |
| ក្រចេះ | ១៨.០៦៧ | ១.១៩៣ | ៦,៦ | ១១,៥ |
| ព្រះវិហារ | ៩.២៨៦ | ៦៧៦ | ៧,៣ | ៦,៥ |
| ស្ទឹងត្រែង | ៦.០១០ | ៣៦៩ | ៦,១ | ៣,៦ |
| កំពង់ធំ | ៤.០៤៣ | ៣៧១ | ៩,២ | ៣,៦ |
| ភ្នំពេញ | ១.៧១៩ | ២១០ | ១២,២ | ២,០ |
| កំពង់ស្ពឺ | ១.១៣២ | ១១៤ | ១០,១ | ១,១ |
| បន្ទាយមានជ័យ | ១.១០៧ | ១២០ | ១០,៨ | ១,២ |
| កណ្តាល | ៧៦១ | ១០៥ | ១៣,៨ | ១,០ |
| កំពង់ចាម | ៧៤៥ | ៩៦ | ១២,៩ | ០,៩ |
| តាកែវ | ៧៣៦ | ៩៨ | ១៣,៣ | ០,៩ |
| សៀមរាប | ៦៤៦ | ១១៦ | ១៨,០ | ១,១ |
| បាត់ដំបង | ៦០៩ | ១១១ | ១៨,២ | ១,១ |
| ឧត្តរមានជ័យ | ៤៨៧ | ៤៦ | ៩,៤ | ០,៤ |
| ត្បូងឃ្មុំ | ៤០៥ | ៦១ | ១៥,១ | ០,៦ |
| ពោធិ៍សាត់ | ៣៧៥ | ៥៤ | ១៤,៤ | ០,៥ |
| ព្រៃវែង | ៣៥៦ | ៦៩ | ១៩,៤ | ០,៧ |

| ១. រាជធានីខេត្ត | ២. ចំនួនសរុប | ៣. ចំនួនមនុស្សចាស់ | ៤. ភាគរយមនុស្សចាស់ក្នុងរាជធានីខេត្ត | ៥. របាយភាគរយមនុស្សចាស់តាមរាជធានីខេត្ត |
|---|---|---|---|---|
| កំពត | ៣២៤ | ៤២ | ១៣,០ | ០,៤ |
| ស្វាយរៀង | ២៨២ | ៣២ | ១១,៣ | ០,៣ |
| កំពង់ឆ្នាំង | ២២០ | ២៨ | ១២,៧ | ០,៣ |
| កោះកុង | ១៨០ | ១៩ | ១០,៦ | ០,២ |
| ព្រះសីហនុ | ១២២ | ៣ | ២,៥ | ០,០ |
| កែប | ១៩ | ១ | ៥,៣ | ០,០ |
| ប៉ៃលិន | ១៤ | ០ | ០,០ | ០,០ |
| សរុប | ១៧២.៩៧៧ | ១០.៣៨៥ | ៦,០ | ១០០,០ |

## ៣. ស្ថានភាពសង្គម-សេដ្ឋកិច្ចនៃជនជាតិដើមភាគតិច

ស្ថានភាពសង្គម-សេដ្ឋកិច្ចនៅក្នុងរបាយការណ៍នេះ ផ្តោតលើស្ថានភាពនៃការអប់រំ កម្លាំងពលកម្ម និងការងារ សុខភាពនិងអនាម័យ ពិការភាព និង សាសនានិងជំនឿ។ រីឯសូចនាករអំពីលំនៅឋាន ប្រភពភ្លើងបំភ្លឺ ប្រភពឋាមពលចម្អិនអាហារ សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងដីសមូហភាពនិងកម្មសិទ្ធិ ដែលជាផ្នែកមួយនៃស្ថានភាពសង្គម-សេដ្ឋកិច្ច នឹងបង្ហាញនៅក្នុងជំពូកទី៤។ ទិន្នន័យសម្រាប់សូចនាករទាំងនេះ បានមកពីជំរឿន អង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ច និងទិន្នន័យរដ្ឋបាលពីក្រសួងស្ថាប័នពាក់ព័ន្ធ។

### ៣.១. ការអប់រំ

សូចនាករអំពីការអប់រំរបស់ជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍នេះ រួមមានអត្រាអក្ខរភាពភាសាខ្មែរ អត្រាចូលរៀនសាលា អត្រាឈប់រៀន (ដែលជាប្រុកស៊ីនៃអត្រាបោះបង់ការសិក្សា) ការចូលរៀនយឺតជាងអាយុ និងកម្រិតនៃការទទួលបានការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

#### ៣.១.១. អត្រាអក្ខរភាព

ជានិយមន័យទូទៅ អត្រាអក្ខរភាពគឺជាភាគរយនៃប្រជាជនដែលចេះអាននិងសរសេរសារធម្មតានៃភាសាខ្មែរឬភាសាណាមួយផ្សេងទៀត ក្នុងចំណោមប្រជាជនអាយុ៧ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សទូទៅ) និងក្នុងចំណោមប្រជាជនអាយុ១៥ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សពេញវ័យ)។ នៅក្នុងរបាយការណ៍នេះ អត្រាអក្ខរភាពគឺផ្តោតលើភាគរយនៃប្រជាជនជនជាតិដើមភាគតិចដែលចេះអាននិងសរសេរភាសាខ្មែរប៉ុណ្ណោះ ក្នុងចំណោមប្រជាជនអាយុ៧ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សទូទៅ) និងក្នុងចំណោមប្រជាជនអាយុ១៥ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សពេញវ័យ)។

ទិន្នន័យឆ្នាំ២០១៩បង្ហាញថា ៥៦,៥%នៃជនជាតិដើមភាគតិចអាយុ៧ឆ្នាំឡើងចេះអាននិងសរសេរភាសាខ្មែរ (៦២,៥%ក្នុងចំណោមបុរស និង៥០,៨%ក្នុងចំណោមស្ត្រី) ដែលកើនឡើងគួរឱ្យកត់សម្គាល់ពីឆ្នាំ២០១៣ ដែលប្រជាជនជនជាតិដើមភាគតិចអាយុ៧ឆ្នាំឡើងចេះអាននិងសរសេរភាសាខ្មែរ ជាសរុបមានត្រឹមតែ៣៤,៣% (៤១,៩%ក្នុងចំណោមបុរស និង២៧,៣%ក្នុងចំណោមស្ត្រី)។ ក្នុងអំឡុងពេលខាងលើ ទិន្នន័យក៏បានបង្ហាញពីការថយចុះយ៉ាងខ្លាំងនៃគម្លាតយេនឌ័រអំពីអក្ខរភាពភាសាខ្មែរ។ ចំពោះអក្ខរភាពមនុស្សពេញវ័យ ៥១,០%នៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងចេះអាននិងសរសេរភាសាខ្មែរ (៥៨,៩%ក្នុងចំណោមបុរស និង៤៣,៥%ក្នុងចំណោមស្ត្រី)។ អត្រាអក្ខរភាពមនុស្សពេញវ័យទាប

ជាងអត្រាអក្ខរភាពមនុស្សទូទៅ បញ្ជាក់ថាមនុស្សពេញវ័យនិងមនុស្សវ័យចាស់ចេះអាននិងសរសេរភាសាខ្មែរតិចជាងមនុស្សវ័យក្មេង (អាយុ៧ឆ្នាំដល់១៤ឆ្នាំ)។

ក្រាភិកទី ២៦. អក្ខរភាពភាសាខ្មែររបស់ជនជាតិដើមភាគតិច ឆ្នាំ២០១៣និងឆ្នាំ២០១៩




## ៣.១.២. អត្រាចូលរៀនសាលា

អត្រាចូលរៀនសាលា សំដៅលើកុមារក្នុងវ័យសិក្សាដែលកំពុងរៀននៅសាលាក្នុងពេលធ្វើអង្កេតក្នុងចំណោមកុមារក្នុងវ័យដូចគ្នា។ កុមារក្នុងវ័យសិក្សាដែលមិនបានរៀននៅសាលាក្នុងពេលធ្វើអង្កេត មានកុមារដែលមិនទាន់បានចូលរៀន កុមារដែលមិនដែលបានរៀន និងកុមារដែលឈប់រៀន (ធ្លាប់ចូលសាលាពីមុន) ក្នុងពេលអង្កេត។ អត្រាចូលរៀនសាលាត្រូវបានបំបែកតាមក្រុមអាយុ៦-១៣ឆ្នាំ និង អាយុ៦-១៨ឆ្នាំ ដោយយោងតាមតម្រូវការរបស់អ្នកប្រើប្រាស់និងដើម្បីអាចប្រៀបធៀបបានជាមួយនឹងរបាយការណ៍ដំបូង និងតាមក្រុមអាយុ ៦-១១ឆ្នាំ ១២-១៤ឆ្នាំ ១៥-១៧ឆ្នាំ និង១៨-២៥ឆ្នាំ ទៅតាមកម្រិតសិក្សា ដើម្បីអាចប្រៀបធៀបបានជាមួយនឹងរបាយការណ៍ជំរឿនអំពីប្រជាជនកម្ពុជាសរុប។

តារាងទី២២ខាងក្រោមបង្ហាញថា មានកុមារជនជាតិដើមភាគតិចអាយុ៦-១៣ឆ្នាំ ឬអាយុ៦-១៨ឆ្នាំ ប្រហែល២៣% មិនបានឬមិនទាន់បានទៅរៀនសាលា។ ថ្វីបើតួលេខនេះធំជាងច្រើន បើធៀបនឹងភាគរយនៃប្រជាជនកម្ពុជាសរុប (ដែលមានត្រឹមប្រហាក់ប្រហែល៦%) តួលេខនេះក៏បង្ហាញពីភាពល្អប្រសើរនៃការចូលរៀនរបស់កុមារជនជាតិដើមភាគតិចបើធៀបនឹងឆ្នាំ២០១៣ ដែលភាគរយមិនបានចូលរៀនមានរហូតដល់ទៅជិត៥០% ទាំងក្រុមអាយុអាយុ៦-១៣ឆ្នាំ ទាំងក្រុមអាយុ៦-១៨ឆ្នាំ។ រីឯភាគរយកុមារ និង យុវវ័យកំពុងរៀនសាលា មានចំនួន៧៥,៤%ក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង៦៧,៣%ក្នុងក្រុមអាយុ៦-១៨ឆ្នាំ។ រីឯភាគរយអ្នកឈប់រៀនសាលា មានចំនួន១,៧%ក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង១០,១%ក្នុងក្រុមអាយុ៦-១៨ឆ្នាំ។

តារាងទី ២២. ភាគរយមិនបានទៅរៀន កំពុងរៀន និងឈប់រៀន

| | ជនជាតិដើមភាគតិច | | កម្ពុជាសរុប | |
|---|---|---|---|---|
| | អាយុ៦-១៣ឆ្នាំ | អាយុ៦-១៨ឆ្នាំ | អាយុ៦-១៣ឆ្នាំ | អាយុ៦-១៨ឆ្នាំ |
| ភាគរយមិនបានរៀន | ២២,៨ | ២២,៦ | ៦,៦ | ៥,៨ |
| ភាគរយកំពុងរៀន | ៧៥,៤ | ៦៧,៣ | ៩១,៣ | ៨២,៣ |
| ភាគរយធ្លាប់រៀនពីមុន | ១,៧ | ១០,១ | ២,១ | ១១,៨ |
| ចំនួនសរុប | ៣៤.២៨៤ | ៥៥.០៩៣ | ២.៥០៩.៦០៣ | ៣.៩៥២.៣១៧ |

តារាងទី២៣ខាងក្រោម បង្ហាញពីភាគរយមិនបានទៅរៀន កំពុងរៀន និងធ្លាប់រៀនពីមុន តាមក្រុមអាយុនៃកម្រិតសិក្សា គឺកម្រិតបឋមសិក្សាអាយុ៦-១១ឆ្នាំ មធ្យមសិក្សាបឋមភូមិអាយុ១២-១៤ឆ្នាំ មធ្យមសិក្សាទុតិយភូមិអាយុ១៥-១៧ឆ្នាំ និងការអប់រំកម្រិតឧត្តមសិក្សាអាយុ១៨-២៤ឆ្នាំ។ ភាគរយកំពុងរៀនរបស់កុមារនិងយុវវ័យជនជាតិដើមភាគតិចមានកម្រិតល្អបង្គួរ គឺភាគរយកំពុងរៀននៅកម្រិតបឋមសិក្សាស្មើនឹង៧២,៩% មធ្យមសិក្សាបឋមភូមិស្មើនឹង៨០,២% មធ្យមសិក្សាទុតិយភូមិស្មើនឹង៥៤,៣% និងនៅឧត្តមសិក្សាស្មើនឹង ១៣,៥%។ បើធៀបនឹងកុមារនិងយុវវ័យកម្ពុជាសរុប[២៣] ភាគរយនេះនៅទាបជាងច្រើន។

---

[២៣] ក្នុងចំណោមកុមារនិងយុវវ័យកម្ពុជាសរុប ភាគរយកំពុងរៀនស្មើនឹង៩០,៦%ក្នុងចំណោមអាយុ៦-១១ឆ្នាំ ៩១,៦%ក្នុងចំណោមអាយុ១២-១៤ឆ្នាំ ៦៧,៦%ក្នុងចំណោមអាយុ១៥-១៧ឆ្នាំ និង២០,៧%ក្នុងចំណោមអាយុ១៨-២៤ឆ្នាំ (តារាង ៤.៥.១ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩៖ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ)។

កុមារជនជាតិដើមភាគតិចដែលមិនបានចូលរៀន មានចំនួន២៦,២%ក្នុងចំណោមកុមារអាយុ៦-១១ឆ្នាំ ១៤%ក្នុងចំណោមកុមារអាយុ១២-១៤ឆ្នាំ ២២,១%ក្នុងចំណោមកុមារអាយុ១៥-១៧ឆ្នាំ និង ៣៨,៤%ក្នុងចំណោមយុវវ័យអាយុ១៨-២៤ឆ្នាំ។ ភាគរយមិនបានចូលរៀនដែលមានតម្លៃខ្ពស់នៅក្នុងចំណោមកុមារអាយុ៦-១១ឆ្នាំ អាចមកពីការចូលរៀនយឺតរបស់កុមារអាយុ៦ឬ៧ឆ្នាំ រីឯភាគរយខ្ពស់នៃអ្នកមិនបានចូលរៀនក្នុងចំណោមអាយុ១៨-២៤ឆ្នាំ បញ្ជាក់ពីការមិនបានចូលរៀនរបស់ក្រុមអាយុនេះកាលពីវ័យកុមារ ក្នុងអំឡុង១០-១៥ឆ្នាំកន្លងទៅ។ ដោយឡែក ភាគរយអ្នកធ្លាប់បានរៀនពីមុនមានចំនួនតូចប្រហាក់ប្រហែលនឹងកម្ពុជាសរុបក្នុងចំណោមកុមារអាយុក្រោម១៥ឆ្នាំ និងមានចំនួនតិចជាងកម្ពុជាសរុបក្នុងចំណោមអាយុ១៥-២៤ឆ្នាំ[២៤] ដែលបង្ហាញពីចំនួនបោះបង់ការសិក្សាទាប និងដែលបណ្តាលមកពីភាគរយអ្នកមិនបានរៀនខ្ពស់។

ជាទូទៅ អត្រាចូលរៀនរបស់កុមារនិងយុវវ័យជនជាតិដើមភាគតិច មិនសូវខុសគ្នារវាងប្រុសនិងស្រីទេ ដែលភាគរយស្រីដែលកំពុងរៀនធំជាងភាគរយប្រុសកំពុងរៀនតិចតួចចំពោះក្រុមអាយុក្រោម១៥ឆ្នាំ និងតូចជាងភាគរយប្រុសកំពុងរៀនតិចតួចចំពោះក្រុមអាយុ១៨-២៤ឆ្នាំ។

តារាងទី ២៣. អត្រាចូលរៀនរបស់កុមារនិងយុវវ័យជនជាតិដើមភាគតិចតាមអាយុកម្រិតសិក្សា

| ភាគរយ | | ៦-១១ឆ្នាំ | ១២-១៤ឆ្នាំ | ១៥-១៧ឆ្នាំ | ១៨-២៤ឆ្នាំ |
|---|---|---|---|---|---|
| សរុប | មិនបានចូលរៀន | ២៦,២ | ១៤,0 | ២២,១ | ៣៨,៤ |
| | កំពុងរៀន | ៧២,៩ | ៨0,២ | ៥៤,៣ | ១៣,៥ |
| | ធ្លាប់រៀនពីមុន | 0,៩ | ៥,៨ | ២៣,៦ | ៤៨,0 |
| ប្រុស | មិនបានចូលរៀន | ២៧,៦ | ១៤,៧ | ២១,៨ | ៣៤,៣ |
| | កំពុងរៀន | ៧១,៣ | ៧៩,៣ | ៥៤,៦ | ១៥,៨ |
| | ធ្លាប់រៀនពីមុន | ១,១ | ៦,0 | ២៣,៦ | ៤៩,៩ |
| ស្រី | មិនបានចូលរៀន | ២៤,៨ | ១៣,៣ | ២២,៤ | ៤២,៣ |
| | កំពុងរៀន | ៧៤,៦ | ៨១,១ | ៥៤,0 | ១១,៤ |
| | ធ្លាប់រៀនពីមុន | 0,៧ | ៥,៦ | ២៣,៦ | ៤៦,៣ |

[២៤] ប្រភពដដែល ដូចខាងលើ។

ខាងក្រោម ជាការបង្ហាញនិងបកស្រាយបន្ថែមទៅតាមអំបូរជនជាតិនីមួយៗ អំពីភាគរយកំពុងរៀន (ចំណុច ៣.១.៣) ភាគរយបោះបង់ការសិក្សា (ចំណុច ៣.១.៤) និងការចូលរៀនយឺត (ចំណុច ៣.១.៥) របស់កុមារជនជាតិដើមភាគតិច យោងតាមទិន្នន័យឆ្នាំ២០១៩។

### ៣.១.៣. ភាគរយកំពុងរៀនតាមក្រុមអាយុនិងអំបូរ

ក្រាភិកខាងក្រោមបង្ហាញពីភាគរយកុមារជនជាតិដើមភាគតិចដែលកំពុងរៀន នៃអំបូរធំៗទាំង១៥ ដែលមានចំនួនប្រជាជនចាប់ពី៥០០នាក់ឡើងទៅ។ សរុបគ្រប់វ័យ ជនជាតិដើមភាគតិចដែលមានភាគរយកុមារនិងយុវវ័យកំពុងរៀនច្រើនជាងគេ មានស្ទួយ ព្រៅ គ្រឹង លុន និងទំពួន និងជនជាតិដើមភាគតិចដែលមានភាគរយកុមារនិងយុវវ័យកំពុងរៀនតិចជាងគេ មានកាវ៉ែត មិល និងក្រោល។

ជនជាតិដើមភាគតិចដែលមានកុមារអាយុ៦-១១ឆ្នាំកំពុងរៀនច្រើនជាងគេ គឺស្ទួយ (៩៤,៧%) បន្ទាប់មកគឺព័រ (៨៦,៤%) ស្ទៀង (៨០,៦%) កួយ (៧៩,៧%) ថ្មូន (៧៨,៩%) និងលុន (៧៤,៩%)។ រីឯជនជាតិដើមភាគតិចដែលមានកុមារអាយុ៦-១១ឆ្នាំកំពុងរៀនតិចជាងគេ មានមិល (៦៩,១%) កាវ៉ែត (៦២,៦%) និងក្រោល (៦១,៦%, តិចជាងគេបង្អស់)។

ជនជាតិដើមភាគតិចដែលមានកុមារអាយុ១២-១៤ឆ្នាំកំពុងរៀនចាប់ពី៨០%ឡើងទៅ មានជនជាតិស្ទួយ (៩៨,៥%) រអង (៩៣,៣%) លុន (៨៦,៦%) ព័រ (៨៦,៤%) ថ្មូន (៨៥,៦%) គ្រឹង (៨៥,៥%) និងព្រៅ (ចំនួនជិត ៨៥%)។ រីឯជនជាតិដើមភាគតិចដែលមានកុមារអាយុ១២-១៤ឆ្នាំកំពុងរៀនតិចជាង៨០% មានស្ទៀង (៧៩,៩%) ពូនង (៧៥,៨%) កួយ (៧៤,៨%) កាវ៉ែត (៧១,៤%) និងក្រោល (៧០,៣%, តិចជាងគេបង្អស់)។

ជនជាតិដើមភាគតិចដែលមានកុមារអាយុ១៥-១៧ឆ្នាំកំពុងរៀនច្រើនជាងគេ គឺជនជាតិស្ទួយ (៧១,០%) បន្ទាប់មកគឺ ព្រៅ (៦៥,១%) ទំពួន (៦៣,០%) គ្រឹង (៦១,៨%) រអង (៦១,៥%) និងលុន (៦១,៣%)។ ជនជាតិដើមភាគតិចដែលមានកុមារអាយុ១៥-១៧ឆ្នាំកំពុងរៀនតិចជាងគេ មានជនជាតិព័រ (៤៤,៧%) ក្រោល (៤១,៩%) កួយ (៤០,២%) និងមិល (៣៦,៧% តិចជាងគេបង្អស់)។

ជនជាតិដើមភាគតិចដែលមានយុវវ័យអាយុ១៨-២៤ឆ្នាំកំពុងរៀនចាប់ពី១០%ឡើងទៅ មានជនជាតិព្រៅ (១៧,៣%) គ្រឹង (១៧,១%) ចារ៉ាយ (១៦,០%) ទំពួន (១៥,៧%) លុន (១៤,១%) កាវ៉ែត (១៣,១%) និងពូនង (១១,៧%)។ ជនជាតិដើមភាគតិចចំនួនបីអំបូរ ដែលមានយុវវ័យអាយុ ១៨-២៤ឆ្នាំកំពុងរៀនតិចជាងគេ គឺរអង (៥,៤%) ថ្មូន (៣,៥%) និងមិល (១,៧%)។

ក្រាភិកទី ២៧. ភាគរយកំពុងរៀនតាមក្រុមអាយុនិងអំបូរ៖ ឆ្នាំ២០១៩



### ៣.១.៤. ភាគរយមិនបានចូលរៀន

តារាងទី២៣ ខាងលើបង្ហាញថា ភាគរយនៃកុមារជនជាតិដើមភាគតិចដែលមិនបានចូលរៀន មានច្រើនក្នុងចំណោមកុមារអាយុ៦-១១ឆ្នាំ ជាងកុមារអាយុ១២-១៧ឆ្នាំ។ ក្រាភិកខាងក្រោមបង្ហាញពីភាគរយកុមារជនជាតិដើមភាគតិចដែលមិនបានចូលរៀន នៃអំបូរទាំង១៥ដែលមានចំនួនប្រជាជនចាប់ពី៥០០នាក់ឡើងទៅ។ ជារួម កុមារនិងយុវវ័យជនជាតិដើមភាគតិចដែលមិនបានចូលរៀនសាលា មានចំនួនច្រើនគួរឱ្យកត់សម្គាល់ ដែលចំនួននេះទាបជាងគេចំពោះក្រុមអាយុ១២-១៤ឆ្នាំ និងកើនទៅតាមក្រុមអាយុ។ នេះបង្ហាញថា ស្ថានភាពនៃការចូលរៀនរបស់កុមារបច្ចុប្បន្នល្អប្រសើរជាងពីពេលមុន។ ដោយឡែក ភាគរយមិនបានចូលរៀនក្នុងចំណោមកុមារអាយុ៦-១១ឆ្នាំ មានចំនួនច្រើនជាងភាគរយមិនបានចូលរៀនក្នុងចំណោមកុមារអាយុ១២-១៤ឆ្នាំ ដែលអាចបណ្តាលមកពីការចូលរៀនយឺតរបស់កុមារអាយុ៦-៧ឆ្នាំ។

កុមារជនជាតិដើមភាគតិចអាយុ៦-១១ឆ្នាំដែលមិនបានចូលរៀនច្រើនជាងគេ គឺកុមារជនជាតិក្រោលនិងការ៉ែតដែលមានចំនួនប្រហែល៣៧% បន្ទាប់មកគឺកុមារជនជាតិមិលប្រហែល២៩% កុមារជនជាតិពូនងប្រហែល២៨% កុមារជនជាតិទំពួន ចារ៉ាយ និងព្រៅប្រហែល២៦% និងកុមារជនជាតិគ្រឹងកួយ និងលុនប្រហែល២៥%។ រីឯជនជាតិដើមភាគតិច ដែលមានភាគរយកុមារអាយុ៦-១១ឆ្នាំមិនបានចូលរៀនតិចជាងគេ គឺជនជាតិស្ទួយ(៥,៣%) និងព័រ(១០,២%)។

ជនជាតិដើមភាគតិច ដែលមានភាគរយកុមារអាយុ១២-១៤ឆ្នាំមិនបានចូលរៀនច្រើនជាងគេ គឺជនជាតិការ៉ែត (២៥,៣%) និង ក្រោល (២២,៦%)។ ជនជាតិដើមភាគតិច ដែលមានភាគរយកុមារអាយុ១២-១៤ឆ្នាំមិនបានចូលរៀនតិចជាងគេ គឺជនជាតិស្ទួយ (០%) និងព័រ (៤,៥%)។

ជនជាតិដើមភាគតិច ដែលមានភាគរយកុមារអាយុ១៥-១៧ឆ្នាំមិនបានចូលរៀនច្រើនជាងគេ គឺជនជាតិការ៉ែត (៣៨%) ក្រោល (៣០,១%) និងលុន (២៩,៣%)។ ជនជាតិដើមភាគតិច ដែលមានភាគរយកុមារអាយុ១៥-១៧ឆ្នាំមិនបានចូលរៀនតិចជាងគេ គឺស្ទួយ (១,៦%) និងព័រ (៤,៣%)។

ជនជាតិដើមភាគតិច ដែលមានភាគរយយុវវ័យអាយុ១៨-២៤ឆ្នាំមិនបានចូលរៀនច្រើនជាងគេ គឺការ៉ែត (៥៥,២%) លុន (៥៥,០%) ចារ៉ាយ (៤៥,៦%) ទំពួន (៤២,៨%) និងក្រោល (៤០,២%)។ ជនជាតិដើមភាគតិច ដែលមានភាគរយយុវវ័យអាយុ១៨-២៤ឆ្នាំមិនបានចូលរៀនតិចជាងគេ គឺស្ទួយ (៣,៤%) និងព័រ (៥,៤%)។ គួរកត់សម្គាល់ថា កុមារនិងយុវវ័យជនជាតិស្ទួយនិងព័រ មានអត្រាមិនបានចូលរៀនទាបជាងគេ គ្រប់វ័យ។

ក្រាភិកទី ២៨. ភាគរយមិនបានចូលរៀនតាមក្រុមអាយុនិងអំបូរ



### ៣.១.៥. អត្រាបោះបង់ការសិក្សា

ភាគរយនៃអ្នកឈប់រៀន (ធ្លាប់រៀនពីមុន) ត្រូវបានប្រើជាប្រូកស៊ី (Proxy) នៃអត្រាបោះបង់ការសិក្សា ដោយគិតទៅតាមអាយុនីមួយៗពី៦ឆ្នាំដល់១៨ឆ្នាំ (ក្រាភិកខាងក្រោម)។ អត្រាបោះបង់ការសិក្សាមានទំហំតូចក្នុងចំណោមអាយុពី៦ឆ្នាំដល់១១ឆ្នាំ (ប្រហែល១%ឬតិចជាង) និងចាប់ផ្តើមកើនបន្តិចម្តងៗដល់១១%នៅអាយុ១៤ឆ្នាំ និងបន្តកើនលឿនរហូតដល់ជាង៥០%នៅអាយុ១៨ឆ្នាំ។ អត្រាបោះបង់ការសិក្សាចាប់កើនខ្លាំងគួរឱ្យកត់សម្គាល់ ចាប់ពីអាយុ១៣ឆ្នាំទៅ ជាក់ស្តែង៖

- នៅអាយុ១២ឆ្នាំ ៤%នៃកុមារា និង៣%នៃកុមារីឈប់រៀន
- នៅអាយុ១៣ឆ្នាំ ៧%នៃកុមារា និង៦%នៃកុមារីឈប់រៀន
- នៅអាយុ១៤ឆ្នាំ កុមារា និងកុមារី១១%ឈប់រៀន
- នៅអាយុ១៥ឆ្នាំ ២២%នៃកុមារា និង២០%នៃកុមារីឈប់រៀន
- នៅអាយុ១៦ឆ្នាំ ប្រហែល៣០%នៃកុមារា និងកុមារីឈប់រៀន
- នៅអាយុ១៧ឆ្នាំ ៤០%នៃកុមារា និង៤៧%នៃកុមារីឈប់រៀន
- នៅអាយុ១៨ឆ្នាំ ជាង៥០%នៃកុមារានិងកុមារីឈប់រៀន

ក្រាភិកទី ២៩. អត្រាបោះបង់ការសិក្សាតាមអាយុនិងភេទ៖ ឆ្នាំ២០១៩



### ៣.១.៦. ការរៀននៅកម្រិតថ្នាក់ទាបជាងអាយុ

តារាងទី ២៣ ខាងលើ បង្ហាញពីភាគរយមិនបានចូលរៀននិងភាគរយឈប់រៀនតាមក្រុមអាយុនៃកម្រិតសិក្សា ដែលភាគរយមិនបានចូលរៀនមានចំនួនច្រើន។ ក្រាភិកទី២៩ខាងលើ ក៏បានបង្ហាញពីភាគរយឈប់រៀនតាមអាយុ ពីអាយុ៦ឆ្នាំដល់១៨ឆ្នាំ ដែលការឈប់រៀនមានទំហំគួរឱ្យកត់សម្គាល់ចាប់ពីអាយុ១៣ឆ្នាំទៅ។ ទិដ្ឋភាពមួយទៀតនៃការសិក្សារបស់កុមារជនជាតិដើមភាគតិច គឺការរៀននៅកម្រិតថ្នាក់ទាបជាងអាយុ (ក្រាភិកទី៣០ខាងក្រោម) ដែលចាប់ផ្តើមលេចឡើងចាប់ពីអាយុ៧ឆ្នាំឡើងទៅ។ ថ្វីបើតួលេខក្នុងក្រាភិកខាងក្រោមបង្ហាញពីភាពល្អប្រសើរជាងកាលនៅឆ្នាំ២០១៣[២៥] ការរៀននៅកម្រិតថ្នាក់ទាបជាងអាយុនៅបន្តមានទំហំធំ ដែលអាចបណ្តាលមកពីការចូលរៀនយឺតនិងការរៀនត្រួតថ្នាក់។ ឧទាហរណ៍៖

- កុមារអាយុ៧ឆ្នាំចំនួន៤២%កំពុងរៀននៅថ្នាក់ទី២ដែលត្រូវនឹងវ័យរបស់ខ្លួន និង៥២%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ
- កុមារអាយុ៨ឆ្នាំចំនួន២១%កំពុងរៀននៅថ្នាក់ទី៣ដែលត្រូវនឹងវ័យរបស់ខ្លួន ៥៣%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និង២២%ទៀតកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំ
- កុមារអាយុ៩ឆ្នាំចំនួន១០%កំពុងរៀននៅថ្នាក់ទី៤ដែលត្រូវនឹងវ័យរបស់ខ្លួន ៤៤%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និង៤៤%ទៀតកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំឡើងទៅ
- កុមារអាយុ១០ឆ្នាំចំនួន១០%កំពុងរៀននៅថ្នាក់ទី៥ដែលត្រូវនឹងវ័យរបស់ខ្លួន ៣៤%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និង៥៤%ទៀតកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំឡើងទៅ
- កុមារអាយុ១១ឆ្នាំចំនួន១០%កំពុងរៀននៅថ្នាក់ទី៦ដែលត្រូវនឹងវ័យរបស់ខ្លួន ២៣%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និង៦៥%ទៀតកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំឡើងទៅ
- កុមារអាយុ១២ឆ្នាំចំនួន៦%កំពុងរៀននៅថ្នាក់ទី៧ដែលត្រូវនឹងវ័យរបស់ខ្លួន ២៥%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និង៦៨%ទៀតកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំឡើងទៅ
- កុមារអាយុ១៣ឆ្នាំចំនួន៤%កំពុងរៀននៅថ្នាក់ទី៣ដែលត្រូវនឹងវ័យរបស់ខ្លួន ២០%កំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន១ឆ្នាំ និងក្រៅពីនេះកំពុងរៀននៅថ្នាក់ទាបជាងអាយុខ្លួន២ឆ្នាំឡើងទៅ។

---

[២៥] ក្រាភិកទី១៧នៃរបាយការណ៍បោះពុម្ពឆ្នាំ២០២១ ដែលយោងលើទិន្នន័យឆ្នាំ២០១៣។

ទោះជាយ៉ាងនេះក្តី ក្រាភិកក៏បានបង្ហាញពីកុមារដែលកំពុងនៅកម្រិតថ្នាក់ខ្ពស់ជាងអាយុខ្លួនដែរ ថ្វីបើមានចំនួនតិចៗ។ ជាក់ស្តែង មានកុមារអាយុ៧ឆ្នាំចំនួន៦%ដែលកំពុងរៀនថ្នាក់ទី៣និងទី៤ កុមារអាយុ ៨ឆ្នាំចំនួន៤%ដែលកំពុងរៀនថ្នាក់ទី៤និងទី៥ កុមារអាយុ៩ឆ្នាំចំនួន៣%ដែលកំពុងរៀនថ្នាក់ទី៥និងទី៦ និងកុមារអាយុ៩ឆ្នាំនិង១០ឆ្នាំចំនួន២%ដែលកំពុងរៀនថ្នាក់ខ្ពស់ជាងអាយុរបស់ខ្លួន។

ក្រាភិកទី ៣០. របាយភាគរយនៃកម្រិតថ្នាក់កំពុងរៀន តាមអាយុនាពេលអង្កេត




### ៣.១.៧. ការទទួលបានការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

តារាងទី២៤ ខាងក្រោមបង្ហាញពីរបាយភាគរយនៃកម្រិតសិក្សាខ្ពស់បំផុតទទួលបាន គិតតាមភេទ និងទីកន្លែងរស់នៅរបស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង និងអាយុ២៥ឆ្នាំឡើង។ ការបកស្រាយខាងក្រោម ផ្តោតលើការទទួលបានការអប់រំក្នុងចំណោមប្រជាជនអាយុ២៥ឆ្នាំតែប៉ុណ្ណោះ ដែលជាវ័យបញ្ចប់ការសិក្សាជាទូទៅ។

ជារួម ភាគច្រើននៃជនជាតិដើមភាគតិចអាយុ២៥ឆ្នាំឡើង ទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា (៧៤,៦%នៅជន បទ និង៤៦,៨%នៅទីប្រជុំជន) និងមធ្យមសិក្សាបឋមភូមិ (១៤,៥%នៅជនបទ និង២៣,៨%នៅទីប្រជុំជន) ប៉ុណ្ណោះ។ ចំណែកឯអ្នកដែលបានរៀនដល់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានចំនួនត្រឹម៥,៤%ក្នុងចំណោមអ្នកនៅជនបទ និង១៦,០%ក្នុងចំណោមអ្នកនៅទីប្រជុំជន។ អ្នកដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ (ទាំងមុននិងក្រោយមធ្យមសិក្សាបឋមភូមិ) មានចំនួនត្រឹមតែ ០,២%ក្នុងចំណោមអ្នកនៅជនបទ និង០,៦%ក្នុងចំណោមអ្នកនៅទីប្រជុំជន។ គម្លាតយេនឌ័រអំពីការទទួលបានការអប់រំ មានតិចតួច ទាំងនៅជនបទទាំងនៅទីប្រជុំជន។

តារាងទី ២៤.   កម្រិតសិក្សាខ្ពស់បំផុតដែលបានរៀនចប់ តាមភេទនិងទីកន្លែងរស់នៅ៖ ឆ្នាំ២០១៩

| កម្រិតសិក្សាខ្ពស់បំផុត ដែលបានរៀនចប់ | អាយុ១៥ឆ្នាំឡើង | | | | | | អាយុ២៥ឆ្នាំឡើង | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទីក្រុង | | | ជនបទ | | | ទីក្រុង | | | ជនបទ | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| មិនបានរៀនសោះ | ០,១ | ០,២ | ០,២ | ០,១ | ០,១ | ០,១ | ០,០ | ០,០ | ០,០ | ០,០ | ០,១ | ០,០ |
| បឋមសិក្សា (ថ្នាក់ទី១-៦) | ៤០,៧ | ៤៣,៧ | ៤២,១ | ៦៦,៦ | ៦៦,៨ | ៦៦,៧ | ៤៣,៥ | ៥០,៥ | ៤៦,៨ | ៧៣,៣ | ៧៦,៨ | ៧៤,៦ |
| មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) | ២៧,៥ | ២៧,២ | ២៧,៤ | ២១,៥ | ២១,៤ | ២១,៤ | ២៤,៥ | ២៣,១ | ២៣,៨ | ១៦,០ | ១២,០ | ១៤,៥ |
| មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) | ១៨,៦ | ១៧,៧ | ១៨,១ | ៧,៨ | ៧,១ | ៧,៥ | ១៧,០ | ១៤,៩ | ១៦,០ | ៥,៩ | ៤,៦ | ៥,៤ |
| សញ្ញាបត្រឌីប្លូម | ១,៦ | ១,៥ | ១,៦ | ០,៥ | ០,៣ | ០,៤ | ២,២ | ១,៦ | ១,៩ | ០,៦ | ០,៣ | ០,៥ |
| សញ្ញាបត្របាក់ឌុប | ៤,៥ | ៤,៤ | ៤,៥ | ០,៩ | ០,៩ | ០,៩ | ៣,៤ | ២,២ | ២,៨ | ០,៩ | ០,៩ | ០,៩ |
| បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស | ០,៦ | ០,៥ | ០,៥ | ០,២ | ០,២ | ០,២ | ០,៥ | ០,៧ | ០,៦ | ០,២ | ០,២ | ០,២ |
| ឧត្តមសិក្សា | ៥,៤ | ៣,៣ | ៤,៤ | ០,៣ | ០,២ | ០,៣ | ៧,៧ | ៤,៦ | ៦,២ | ០,៥ | ០,២ | ០,៤ |
| ផ្សេងៗទៀត | ១,០ | ១,៦ | ១,៣ | ២,១ | ៣,០ | ២,៥ | ១,៣ | ២,២ | ១,៧ | ២,៦ | ៤,៨ | ៣,៥ |
| **ចំនួនសរុប** | **៣.៣៧២** | **៣.២៨៩** | **៦.៦៦១** | **២៨.១១៤** | **២១.១០១** | **៤៩.២១៥** | **២.២០៧** | **២.០២២** | **៤.២២៩** | **១៦.៤៨៥** | **១០.១៨៦** | **២៦.៦៧១** |

## ៣.២. ស្ថានភាពកម្លាំងពលកម្ម ការងារ និងសេដ្ឋកិច្ច

នៅក្នុងបរិការណ៍នៃភាគលាភប្រជាសាស្ត្រដែលកំពុងបន្តមាននៅកម្ពុជាបច្ចុប្បន្ន ព័ត៌មានអំពីស្ថានភាពកម្លាំងពលកម្ម ការងារ និងសេដ្ឋកិច្ចរបស់ប្រជាជន នឹងផ្តល់ការយល់ដឹងបន្ថែមអំពីលទ្ធភាពនៃការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនៃភាគលាភប្រជាសាស្ត្រ។ ជនជាតិដើមភាគតិចនៅកម្ពុជា ដែលជាក្រុមប្រជាជនងាយរងគ្រោះ ក៏ជាផ្នែកមួយនៃភាគលាភប្រជាសាស្ត្រផងដែរ ដោយសារចំនួនប្រជាជនក្នុងវ័យធ្វើការកំពុងកើនឡើង។ នៅក្នុងផ្នែកនេះ ស្ថានភាពនៃកម្លាំងពលកម្ម ការងារ និងកម្រិតវប្បធម៌របស់ជនជាតិដើមភាគតិច នឹងត្រូវបានលើកយកមកបកស្រាយ ទៅតាមស្ថានភាពនៃទិន្នន័យដែលមាន ដោយមានការប្រៀបធៀបជាមួយនឹងប្រជាជនកម្ពុជាជារួម និងទៅតាមនិន្នាការប្រែប្រួលទៅតាមពេល។

### ៣.២.១. ប្រជាជនសកម្មសេដ្ឋកិច្ចនិងអសកម្មសេដ្ឋកិច្ច

ប្រជាជនចែកជាពីរប្រភេទ យោងតាមនិយមន័យជំរឿន គឺប្រជាជនសកម្មសេដ្ឋកិច្ច និងប្រជាជនអសកម្មសេដ្ឋកិច្ច។ ប្រជាជនសកម្មសេដ្ឋកិច្ច (ឬហៅថា សកម្មជនសេដ្ឋកិច្ច) គឺជាកម្លាំងពលកម្ម ដែលរាប់បញ្ចូលទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ នៅក្នុងកំឡុងពេលយោងមួយមុនពេលប្រមូលទិន្នន័យ។ ដូចនេះ អត្រាចូលរួមក្នុងកម្លាំងពលកម្ម គឺជាភាគរយនៃប្រជាជនសកម្មសេដ្ឋកិច្ច ក្នុងចំណោមប្រជាជនមួយ។

- អ្នកមានការងារធ្វើ គឺជាអ្នកដែលបានធ្វើការយ៉ាងតិច៦ខែ (១៨៣ថ្ងៃ) ក្នុងកំឡុងពេល១២ខែមុនថ្ងៃធ្វើជំរឿន (ដែលជាកាលបរិច្ឆេទជំរឿន) ដែលរួមមាន៖

  ១. អ្នកមានការងារធ្វើមានប្រាក់ឈ្នួលឬប្រាក់ខែ

  ២. អ្នកបានធ្វើការដើម្បីប្រាក់ឈ្នួល ប្រាក់កម្រៃ ឬបានប្រយោជន៍ជាសាច់ប្រាក់ឬរបស់របរផ្សេងៗ

  ៣. អ្នកដែលមិនបានធ្វើការក្នុងពេលកំណត់ខាងលើ តែមានជាប់ការងារកន្លងមកដែលខ្លួនអាចត្រឡប់ទៅធ្វើនៅពេលណាមួយវិញ (ដូចជាកសិករដែលសម្រាកពីការងារក្នុងពេលផុតរដូវបង្កបង្កើនផល)

  ៤. អ្នកធ្វើអាជីវកម្មផ្ទាល់ខ្លួន

- អ្នកគ្មានការងារធ្វើ គឺអ្នកដែលធ្លាប់ធ្វើការងារពេលណាមួយពីមុនមក និងអ្នកមិនដែលធ្វើការងារពេលណាមួយសោះពីមុនមក។ អ្នកដែលមានលទ្ធភាពធ្វើការឬបានស្វែងរកការងារក្នុងរយៈពេលមួយមុនកាលបរិច្ឆេទនៃជំរឿន ក៏ចាត់ទុកថាជាអ្នកគ្មានការងារធ្វើដែរ។
- ប្រជាជនអសកម្មសេដ្ឋកិច្ច គឺជា៖

១. អ្នកធ្វើការងារផ្ទះសម្បែង

២. សិស្សនិស្សិត

៣. អ្នកនៅក្នុងបន្ទុក (ទារក កុមារតូចមិនទាន់ចូលសាលា អ្នកមានពិការភាពមិនអាចធ្វើការបាន អ្នកមានជំងឺមិនអាចធ្វើការងារបាន និងមនុស្សចាស់ជរា)

៤. អ្នករស់នៅដោយការជួលអចលនវត្ថុ និវត្តន៍ជន ឬអ្នកទទួលកម្រៃជើងសារផ្សេងៗ ដែលមិនបានប្រើប្រាស់ពេលវេលាច្រើនបំផុតទៅលើការធ្វើការងារ

៥. អ្នកធ្វើការងារផ្សេងទៀត ដែលមិនតម្រូវពេលវេលាសកម្មសេដ្ឋកិច្ចគ្រប់ពេល (ការងារម្តងម្កាលប៉ុណ្ណោះ)។

តារាងខាងក្រោម បង្ហាញពីចំនួននិងភាគរយប្រជាជនសកម្មនិងអសកម្មសេដ្ឋកិច្ច ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចនិងប្រជាជនកម្ពុជាសរុប អាយុ៥ឆ្នាំឡើងនិងអាយុ១៥ឆ្នាំឡើង តាមភេទ។ ដោយប្រជាជនអាយុ៥ឆ្នាំឡើង មិនទាន់ចូលដល់វ័យធ្វើការងារ ការបកស្រាយលទ្ធផលក្នុងតារាងខាងក្រោម ផ្តោតជាចម្បងទៅលើក្រុមប្រជាជនអាយុ១៥ឆ្នាំឡើង។

ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង មានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងប្រជាជនកម្ពុជាសរុប ពិសេសស្ត្រី។ ជាសរុប ៨៥,២%នៃប្រជាជនជនជាតិដើមភាគតិច ជាប្រជាជនសកម្មសេដ្ឋកិច្ច (៨៧,០%ក្នុងចំណោមបុរស និង ៨៣,៥%ក្នុងចំណោមស្ត្រី) ខ្ពស់ជាងប្រជាជនកម្ពុជា ដែលមានជាសរុប ៧៩,១% (៨៤,៤%ក្នុងចំណោមបុរស និង ៧៤,៣%ក្នុងចំណោមស្ត្រី)។ ក្នុងចំណោមជនជាតិដើមភាគតិចដែលសកម្មសេដ្ឋកិច្ច អត្រាគ្មានការងារធ្វើមានតិចជាង ១% គឺ ០,៦%ជាសរុប ០,៧%ក្នុងចំណោមបុរស និង០,៦%ក្នុងចំណោមស្ត្រី។

តារាងទី ២៥.  ប្រជាជនសកម្មនិងអសកម្មសេដ្ឋកិច្ច អាយុ៥ឆ្នាំឡើងនិង១៥ឆ្នាំឡើង៖ ឆ្នាំ២០១៩

| | ជនជាតិដើមភាគតិច | | | កម្ពុជា | | |
|---|---|---|---|---|---|---|
| **ប្រជាជនអាយុ៥ឆ្នាំឡើង** | **ប្រុស** | **ស្រី** | **សរុប** | **ប្រុស** | **ស្រី** | **សរុប** |
| **សកម្មសេដ្ឋកិច្ច(%)** | **៦៤,១** | **៦២,៦** | **៦៣,៣** | **៦៥,២** | **៥៩,០** | **៦២,០** |
| អ្នកមានការងារធ្វើ | ៩៩,៣ | ៩៩,៤ | ៩៩,៣ | ៩៨,៧ | ៩៨,៥ | ៩៨,៦ |
| អ្នកគ្មានការងារធ្វើ | ០,៧ | ០,៦ | ០,៧ | ១,៣ | ១,៥ | ១,៤ |
| **អសកម្មសេដ្ឋកិច្ច(%)** | **៣៥,៩** | **៣៧,៤** | **៣៦,៧** | **៣៤,៨** | **៤១,០** | **៣៨,០** |
| អ្នកធ្វើការផ្ទះ | ១,៨ | ៩,២ | ៥,៦ | ៥,០ | ២២,៩ | ១៥,០ |
| សិស្ស និស្សិត | ៧៥,២ | ៦៨,២ | ៧១,៥ | ៧៩,០ | ៦១,១ | ៦៩,០ |
| អ្នកក្នុងបន្ទុក | ២២,១ | ២១,៦ | ២១,៩ | ១៣,០ | ១៣,៧ | ១៣,៤ |
| អ្នកពឹងលើចំណូលស្រាប់ | ០,៥ | ០,៧ | ០,៦ | ២,០ | ១,៧ | ១,៨ |
| ផ្សេងទៀត | ០,៤ | ០,៣ | ០,៤ | ១,០ | ០,៦ | ០,៨ |
| **ចំនួនសរុប (ពាន់នាក់)** | **៧៦,២** | **៧៩,២** | **១៥៥,៤** | **៦.៨២៥,៩** | **៧.២៧៦,២** | **១៤.១០២,១** |
| | **ជនជាតិដើមភាគតិច** | | | **កម្ពុជា** | | |
| **ប្រជាជនអាយុ១៥ឆ្នាំឡើង** | **ប្រុស** | **ស្រី** | **សរុប** | **ប្រុស** | **ស្រី** | **សរុប** |
| **សកម្មសេដ្ឋកិច្ច (%)** | **៨៧,០** | **៨៣,៥** | **៨៥,២** | **៨៤,៤** | **៧៤,៣** | **៧៩,១** |
| អ្នកមានការងារធ្វើ | ៩៩,៣ | ៩៩,៤ | ៩៩,៤ | ៩៨,៨ | ៩៨,៥ | ៩៨,៧ |
| អ្នកគ្មានការងារធ្វើ | ០,៧ | ០,៦ | ០,៦ | ១,២ | ១,៥ | ១,៣ |
| **អសកម្មសេដ្ឋកិច្ច(%)** | **១៣,០** | **១៦,៥** | **១៤,៨** | **១៥,៦** | **២៥,៧** | **២០,៩** |
| អ្នកធ្វើការផ្ទះ | ៥,៤ | ២៧,១ | ១៧,៩ | ១៣,៧ | ៤៥,៧ | ៣៤,៣ |
| សិស្ស និស្សិត | ៧៧,១ | ៥០,៣ | ៦១,៧ | ៦២,៣ | ៣៣,៣ | ៤៣,៦ |
| អ្នកក្នុងបន្ទុក | ១៤,១ | ១៩,៦ | ១៧,៣ | ១៥,៤ | ១៦,៤ | ១៦,០ |
| អ្នកពឹងលើចំណូលស្រាប់ | ២,១ | ២,១ | ២,១ | ៥,៨ | ៣,៤ | ៤,២ |
| ផ្សេងទៀត | ១,៣ | ០,៩ | ១,១ | ២,៨ | ១,២ | ១,៨ |
| **ចំនួនសរុប (ពាន់នាក់)** | **៥៤,៧** | **៥៨,២** | **១១២,៨** | **៥.២២៩,៤** | **៥.៧៥១,៦** | **១០.៩៨១,១** |

ផ្ទុយទៅវិញ ភាគរយប្រជាជនអសកម្មសេដ្ឋកិច្ច ក្នុងចំណោមជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង មានចំនួនតិចជាងភាគរយក្នុងចំណោមប្រជាជនកម្ពុជាសរុប ពិសេសក្នុងចំណោមស្ត្រី។ ជាសរុប ១៤,៨%នៃប្រជាជនជនជាតិដើមភាគតិច ជាប្រជាជនអសកម្មសេដ្ឋកិច្ច (១៣,០%ក្នុងចំណោមបុរស និង ១៦,៥%ក្នុងចំណោមស្ត្រី) ទាបជាងប្រជាជនកម្ពុជា ដែលមានជាសរុប ២០,៩% (១៥,៦%ក្នុងចំណោមបុរស និង ២៥,៧%ក្នុងចំណោមស្ត្រី)។ ភាគច្រើននៃបុរសជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលអសកម្មសេដ្ឋកិច្ច ច្រើនជាសិស្សនិស្សិត (៧៧,១%) រីឯភាគច្រើននៃស្ត្រីជនជាតិដើមភាគតិចដែលអសកម្មសេដ្ឋកិច្ច ច្រើនជាសិស្សនិស្សិត (៥០,៣%) និងអ្នកធ្វើការផ្ទះ (២៧,១%)។

### ៣.២.២. អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមភេទនិងក្រុមអាយុ និងតាមអំបូរ

បើគិតតាមក្រុមអាយុ (ក្រាភិកទី៣១ ខាងក្រោម) ការចូលរួមក្នុងកម្លាំងពលកម្មរបស់បុរស មានអត្រាខ្ពស់គួរកត់សម្គាល់ក្នុងចំណោមបុរសជនជាតិដើមភាគតិចអាយុ២៥-៥៤ឆ្នាំ គឺចាប់ពី៩៨,០%ដល់៩៩,០%។ អត្រានេះស្មើនឹង៧០,៥%ចំពោះក្រុមអាយុ១៥-២៤ឆ្នាំ ៩៥,៩%ចំពោះក្រុមអាយុ៥៥-៦៤ឆ្នាំ និងជិត៨០%ចំពោះក្រុមអាយុ៦៥ឆ្នាំឡើង។ ចំពោះស្ត្រីវិញ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងក្រុមអាយុ២៥-៥៤ឆ្នាំ ទាបជាងបុរសតិចតួច គឺមានតម្លៃពីពី៩៤,១%ដល់៩៥,២%។ អត្រានេះស្មើនឹង៦៧,៩%ក្នុងក្រុមអាយុ១៥-២៤ ៨៤,៨%ក្នុងក្រុមអាយុ៥៥-៦៤ឆ្នាំ និង៥៨,១%ក្នុងក្រុមអាយុ៦៥ឆ្នាំឡើង។ លទ្ធផលនេះបញ្ជាក់អំពីការចូលរួមក្នុងកម្លាំងពលកម្មខ្ពស់នៃក្រុមអាយុ២៥-៥៤ឆ្នាំទាំងបុរសទាំងស្ត្រី។ ភាគច្រើននៃប្រជាជនក្រៅកម្លាំងពលកម្ម (អសកម្មសេដ្ឋកិច្ច) គឺជាប្រជាជនក្នុងវ័យ១៥-២៤ឆ្នាំ ដែលច្រើនជាសិស្សនិស្សិត និងក្នុងវ័យ៦៥ឆ្នាំឡើង ដែលច្រើនជាអ្នកធ្វើកិច្ចការផ្ទះនិងអ្នកក្នុងបន្ទុក ពិសេសស្ត្រី (តារាងទី ២៥ ខាងលើ)។

ក្រាភិកទី ៣១. ភាគរយកម្លាំងពលកម្ម តាមភេទនិងក្រុមអាយុ៖ ឆ្នាំ២០១៩




ក្រាភិកទី៣២ខាងក្រោមបង្ហាញថា អត្រាចូលរួមក្នុងកម្លាំងពលកម្មក្នុងចំណោមប្រជាជនអាយុ ១៥ឆ្នាំឡើង ខុសៗគ្នាពីអំបូរមួយទៅអំបូរមួយ ដែលជនជាតិគ្រោល ថ្នូន មិល និងកួយ មានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងគេ គឺ៩១,៦% ៩១% ៨៨,១% និង ៨៧% រៀងគ្នា។ រីឯជនជាតិព័រ មានអត្រាចូលរួមក្នុងកម្លាំងពលកម្មទាបជាងគេ គឺ៧៧%។ ក្រៅពីនោះ អំបូរផ្សេងៗទៀតមានអត្រាចូលរួមកម្លាំងពលកម្មក្នុងរង្វង់ ពី៨១%ទៅ៨៦%។

ក្រាភិកទី ៣២. អត្រាចូលរួមក្នុងកម្លាំងពលកម្មនៃប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង



### ៣.២.៣. អត្រាគ្មានការងារធ្វើ តាមភេទនិងក្រុមអាយុ និងតាមអំបូរ

តារាងទី២៥ខាងលើបង្ហាញថា ជនជាតិភាគតិចមានអត្រានិកម្មភាព (គ្មានការងារ) ធ្វើទាប។ ដោយគិតតាមភេទនិងក្រុមអាយុ ភាគរយអ្នកគ្មានការងារធ្វើខ្ពស់ក្នុងចំណោមប្រជាជនអាយុ១៥-២៤ឆ្នាំ (ដែលភាគច្រើនស្ថិតក្នុងវ័យសិក្សា) និងក្នុងចំណោមអាយុ៦៥ឆ្នាំឡើង (ដែលភាគច្រើនជាអ្នកក្នុងបន្ទុក និងចាស់ជរា)។ លើសពីនេះទៀត បុរសអាយុ១៥-៣៤ឆ្នាំ មានភាគរយអ្នកគ្មានការងារធ្វើខ្ពស់ជាងស្ត្រី តែចាប់ពីអាយុ៣៥ឆ្នាំឡើង ស្ត្រីមានភាគរយអ្នកគ្មានការងារធ្វើខ្ពស់ជាងបុរស តែភាពខុសគ្នាមានតិចតួច។

ក្រាភិកទី ៣៣. ភាគរយអ្នកគ្មានការងារធ្វើ តាមភេទនិងក្រុមអាយុ




ជារួម ជនជាតិដើមភាគតិចមានអ្នកគ្មានការងារធ្វើតិចតួចណាស់ និងខុសគ្នាតិចតួចពីអំបូរមួយទៅអំបូរមួយ។ ជាក់ស្តែង អំបូរជនជាតិដើមភាគតិចចំនួន៣ ដែលមានភាគរយអ្នកគ្មានការងារធ្វើច្រើនជាងគេ គឺពូនង (ដែលមានត្រឹម១,៦៧%) គ្រឹង (១,២៨%) និងទំពួន (១,០៧%) (ក្រាភិកទី៣៤)។ ដូចនេះ ជនជាតិដើមភាគតិចមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ និងអត្រាគ្មានការងារធ្វើទាប ទាំងបុរសទាំងស្ត្រី ក្នុងវ័យ១៥ឆ្នាំឡើង។

ក្រាភិកទី ៣៤. ភាគរយអ្នកគ្មានការងារធ្វើតាមអំបូរជនជាតិដើមភាគតិច




## ៣.២.៤. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច

ព័ត៌មានអំពីស្ថានភាពការងាររបស់ជនជាតិដើមភាគតិច (ក្រាភិកខាងក្រោម) អាចឱ្យយល់ដឹងបន្ថែមពីស្ថានភាពសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច។ ទោះបីជាជនជាតិដើមភាគតិចមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់និងអត្រាគ្មានការងារធ្វើទាបក៏ដោយ ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចប្រកបរបររកស៊ីដោយខ្លួនឯងឬធ្វើការងារគ្មានប្រាក់កម្រៃ ជាពិសេសគឺក្នុងចំណោមស្ត្រីអាយុ១៥ឆ្នាំឡើងដែលភាគច្រើនធ្វើការងារគ្មានប្រាក់កម្រៃ។

យោងតាមទិន្នន័យអំពីស្ថានភាពការងារនៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ចំនួនត្រឹមតែ៦,៥%ប៉ុណ្ណោះ ដែលធ្វើការងារមានប្រាក់កម្រៃ (តួលេខនេះស្មើនឹង៣១,៥%សម្រាប់កម្ពុជាសរុប) ជិត៤៤%ប្រកបរបររកស៊ីដោយខ្លួនឯង (ជិត៤៣%សម្រាប់កម្ពុជាសរុប) និង៤៩,៣%ធ្វើការងារគ្មានប្រាក់កម្រៃ (២៤,៨%សម្រាប់កម្ពុជាសរុប) (ក្រាភិកទី៣៥)។ បើគិតតាមភេទ ភាគច្រើននៃបុរសជនជាតិដើមភាគតិចប្រកបរបរដោយខ្លួនឯង (៦៦,១%) និងធ្វើការងារគ្មានប្រាក់កម្រៃ (២៥%)។ ផ្ទុយទៅវិញ ភាគច្រើនលើសលប់នៃស្ត្រីជនជាតិដើមភាគតិច ធ្វើការងារគ្មានប្រាក់កម្រៃ (៧៣%) និងប្រកបរបររកស៊ីដោយខ្លួនឯង (២១,៩%)។

បើគិតតាមក្រុមអាយុ (ក្រាភិក៣៦) បុរសជនជាតិដើមភាគតិចច្រើនប្រកបរបររកស៊ីដោយខ្លួនឯងនៅអាយុ២៥-៣៤ឆ្នាំ (ជិត៦៨%) និងចាប់ពីអាយុ៣៥ឆ្នាំទៅ ភាគរយនេះកើនដល់ជាង៨០% ដែលភាគរយបុរសអាយុ៣៥ឆ្នាំធ្វើការងារគ្មានប្រាក់កម្រៃ ថយនៅក្រោម១០%។ ផ្ទុយទៅវិញ ភាគច្រើននៃស្ត្រីជនជាតិដើមភាគតិច ធ្វើការងារដោយគ្មានប្រាក់កម្រៃនៅគ្រប់ក្រុមអាយុទាំងអស់ ហើយភាគរយនេះខ្ពស់ខ្លាំងក្នុងចំណោមស្ត្រីវ័យក្មេង (ជាង៨០%ក្នុងក្រុមអាយុ១៥-២៤ឆ្នាំ ជាង៧០%ក្នុងក្រុមអាយុ២៥-៤៤ឆ្នាំ និងជាង៦០%ក្នុងក្រុមអាយុ៤៥-៦៤ឆ្នាំ)។

ក្រាភិកទី ៣៥. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិចនិងកម្ពុជាអាយុ១៥ឆ្នាំឡើង តាមភេទ



ក្រាភិកទី ៣៦.  ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច អាយុ១៥ឆ្នាំឡើង តាមភេទនិងក្រុមអាយុ




## ៣.២.៥. ការងារតាមវិស័យសេដ្ឋកិច្ច

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចដែលមានការងារធ្វើ ភាគច្រើនលើសលប់ទាំងប្រុសទាំងស្រី ធ្វើការងារក្នុងវិស័យកសិកម្ម (ជាង៩០%) ដែលចំនួននេះមានត្រឹមតែជាង៥០%ប៉ុណ្ណោះក្នុងចំណោមប្រជាជនកម្ពុជាសរុប (ក្រាភិកទី៣៧)។ ផ្ទុយទៅវិញ ជនជាតិដើមភាគតិចដែលធ្វើការងារក្នុងវិស័យឧស្សាហកម្ម មានចំនួនតិចជាង២% (១,៩%ក្នុងចំណោមបុរស និង១,៤%ក្នុងចំណោមស្ត្រី) ដែលចំនួននេះមានជិត១៨% ក្នុងចំណោមប្រជាជនកម្ពុជាសរុប (១៨%ក្នុងចំណោមបុរស និង២០%ក្នុងចំណោមស្ត្រី)។ រីឯជនជាតិដើមភាគតិចដែលធ្វើការងារក្នុងវិស័យសេវាកម្ម មានចំនួនប្រហែល៦% (៧,៤%ក្នុងចំណោមបុរស និង៤,៥%ក្នុងចំណោមស្ត្រី) ដែលតិចជាងឆ្ងាយនៃភាគរយក្នុងចំណោមប្រជាជនកម្ពុជាសរុប (គឺ ២៦,៥%សរុបទាំងពីរភេទ ២៩%ក្នុងចំណោមបុរស និង២៣,៨%ក្នុងចំណោមស្ត្រី)។

ក្រាភិកទី ៣៧. ការងារតាមវិស័យសេដ្ឋកិច្ច គិតតាមភេទ




ភាគច្រើននៃបុរសជនជាតិដើមភាគតិចធ្វើការក្នុងវិស័យឧស្សាហកម្ម គឺបុរសអាយុ២៥-៣៤ឆ្នាំ (មានចំនួន២,៦%) និងអាយុ១៥-២៤ឆ្នាំ និង ៣៥-៤៤ឆ្នាំ (ប្រហែល២%ក្នុងក្រុមអាយុនីមួយៗ)។ បុរសដែលធ្វើការងារក្នុងវិស័យសេវាកម្ម ច្រើនមាននៅក្រុមអាយុ១៥-២៤ឆ្នាំ ដល់៣៥-៤៤ឆ្នាំ (ប្រហែល៩% ក្នុងក្រុមអាយុនីមួយៗ)។ ស្ត្រីភាគច្រើនដែលធ្វើការងារក្នុងវិស័យឧស្សាហកម្ម គឺស្ថិតក្នុងក្រុមអាយុ១៥-៤៤ឆ្នាំ (ប្រហែល២%ក្នុងក្រុមអាយុនីមួយៗ)។ ស្ត្រីដែលធ្វើការងារក្នុងវិស័យសេវាកម្ម ច្រើនស្ថិតក្នុងក្រុមអាយុ២៥-៣៤ឆ្នាំ (ប្រហែល៧%)។

គិតតាមអំបូរ ជនជាតិដើមភាគតិចដែលមានប្រជាជនច្រើន ធ្វើការងារក្នុងវិស័យកសិកម្មច្រើនជាងអំបូរតូចៗ និងផ្ទុយទៅវិញអំបូរតូចៗមានអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មនិងសេវាកម្មច្រើនជាងអំបូរដែលមានប្រជាជនច្រើន (តារាងទី ២៥)។ អំបូរជនជាតិដើមភាគតិច ដែលមានបុរសធ្វើការងារក្នុងវិស័យកសិកម្មច្រើនជាង៩០% មានព្នង (៩២,១%) ទំពួន (៩៣,៩%) គ្រឹង (៩២,២%) កួយ (៩២,៣%) ក្រោល (៩៣,៦%) និងលុន (៩១,៩%)។ អំបូរជនជាតិដើមភាគតិច ដែលមានអ្នកធ្វើការងារក្នុងវិស័យ

ឧស្សាហកម្មច្រើន មានរអេង ស្ទួយ ព័រ មិល និងស្ទៀង។ រីឯអំបូរជនជាតិដើមភាគតិច ដែលមានអ្នកធ្វើការងារក្នុងវិស័យសេវាកម្មច្រើន មានរអេង មិល ព័រ ស្ទៀង ព្រៅ កាវ៉ែត និងស្ទួយ។

ក្រាភិកទី ៣៨. ការងារតាមវិស័យសេដ្ឋកិច្ច គិតតាមភេទនិងក្រុមអាយុ




តារាងទី ២៦. ការងារតាមវិស័យសេដ្ឋកិច្ចនៃអំបូរនីមួយ

| | កសិកម្ម | | ឧស្សាហកម្ម | | សេវាកម្ម | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ពូនង | ៩២,១ | ៩៥,៤ | ១,០ | ០,៣ | ៧,០ | ៤,៣ |
| ទំពួន | ៩៣,៩ | ៩៦,៥ | ០,៨ | ០,៤ | ៥,៣ | ៣,០ |
| ចារ៉ាយ | ៨៨,៦ | ៩១,៣ | ៣,៤ | ៣,០ | ៨,០ | ៥,៧ |
| គ្រឹង | ៩២,២ | ៩៦,០ | ០,៥ | ០,២ | ៧,៣ | ៣,៨ |
| កួយ | ៩២,៣ | ៩៤,២ | ១,៧ | ១,៣ | ៦,០ | ៤,៥ |
| ព្រៅ | ៨៩,៥ | ៩៤,៦ | ០,៩ | ១,០ | ៩,៦ | ៤,៤ |
| កាវ៉ែត | ៨៧,៤ | ៩១,៥ | ៣,៦ | ៣,០ | ៩,០ | ៥,៥ |
| ក្រោល | ៩៣,៦ | ៩៣,២ | ១,៥ | ១,៦ | ៤,៩ | ៥,៣ |

| | កសិកម្ម | | ឧស្សាហកម្ម | | សេវាកម្ម | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ស្ទៀង | ៨៦,១ | ៨៦,៦ | ៥,៤ | ៤,៥ | ៨,៤ | ៨,៩ |
| ថ្នូន | ៨៩,៥ | ៩១,៦ | ៣,៤ | ២,៥ | ៧,១ | ៥,៩ |
| លុន | ៩១,៩ | ៩៤,១ | ០,០ | ២,៨ | ៨,១ | ៣,១ |
| មិល | ៨១,៣ | ៨៨,១ | ៥,២ | ៤,៦ | ១៣,៥ | ៧,៣ |
| ព័រ | ៨៣,៣ | ៩៣,៧ | ៦,៥ | ៣,៤ | ១០,១ | ៣,០ |
| សួយ | ៨១,០ | ៧៦,៣ | ១០,៦ | ១៨,៩ | ៨,៣ | ៤,៨ |
| រអង | ៥៤,៥ | ៥៦,៤ | ១៦,២ | ១៤,៧ | ២៩,៣ | ២៨,៩ |
| ជនជាតិដើមផ្សេងទៀត | ៤៤,២ | ៤៨,៨ | ១៩,៧ | ១៩,១ | ៣៦,១ | ៣២,១ |

### ៣.២.៦. សហគ្រាសការងាររបស់ជនជាតិដើមភាគតិច

ការងារត្រូវបានបែងចែកជា ៧ ប្រភេទ គឺៈ ១) ការងារសហគ្រាសឯកជនក្នុងស្រុក, ២) ការងាររដ្ឋាភិបាល, ៣) ការងារសហគ្រាសបរទេស, ៤) ការងារគ្រួសារ, ៥) ការងារអង្គភាពស្វយ័ត, ៦) ការងារស្ថាប័នមិនយកប្រាក់ចំណេញ, និង៧) ការងារស្ថានទូត/ស្ថាប័នអន្តរជាតិ, (យោងតាមទិន្នន័យជំរឿន)។

តារាងទី ២៧. សហគ្រាសនៃការងារជនជាតិដើមភាគតិចដែលមានការងារធ្វើ ឆ្នាំ២០១៣និង ២០១៩

| | ឆ្នាំ២០១៣ | | | ឆ្នាំ២០១៩ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| សហគ្រាសឯកជនក្នុងស្រុក | ៩៥,១ | ៩៨,០ | ៩៦,៦ | ៩៤,០ | ៩៦,៦ | ៩៥,៣ |
| រដ្ឋាភិបាល | ៣,៧ | ០,៦ | ២,១ | ៤,០ | ១,៣ | ២,៦ |
| សហគ្រាសបរទេស | ០,៩ | ០,៩ | ០,៩ | ០,៩ | ១,១ | ១,០ |
| ផ្នែកគ្រួសារ | ០,៣ | ០,៤ | ០,៤ | ០,៥ | ០,៦ | ០,៦ |
| អង្គភាពស្វយ័ត | ០,០ | ០,១ | ០,០ | ០,៣ | ០,២ | ០,៣ |
| ស្ថាប័នមិនយកប្រាក់ចំណេញ | ០,០ | ០,០ | ០,០ | ០,១ | ០,១ | ០,១ |
| ស្ថានទូត/ស្ថាប័នអន្តរជាតិ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

របាយភាគរយនៃប្រភេទការងាររបស់ជនជាតិដើមភាគតិច អាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ (តារាងទី២៧ខាងលើ) ខុសគ្នាតិចតួចរវាងឆ្នាំ២០១៣និងឆ្នាំ២០១៩។ ភាគច្រើនលើសលប់នៃជនជាតិដើម ភាគតិច ធ្វើការងារនៅសហគ្រាសឯកជនក្នុងស្រុក ដែលជាសរុបមានចំនួន៩៦,៦%នៅឆ្នាំ២០១៣ និងចំនួន៩៥,៣%នៅឆ្នាំ២០១៩ (៩៤%ក្នុងចំណោមបុរស និង៩៦,៦%ក្នុងចំណោមស្ត្រី នៅឆ្នាំ ២០១៩)។ គួរកត់សម្គាល់ថា ប្រភេទការងារសហគ្រាសឯកជនក្នុងស្រុកនេះ រាប់បញ្ចូលទាំងការងារមានប្រាក់កម្រៃ ការងារគ្មានប្រាក់កម្រៃ និងការងារដោយខ្លួនឯង។ ជនជាតិដើមភាគតិចដែលធ្វើការងាររដ្ឋាភិបាល មានចំនួនតិចជាង៣% (៤%ក្នុងចំណោមបុរស និង១,៣%ក្នុងចំណោមស្ត្រី)។ ជនជាតិដើមភាគតិចដែលធ្វើការងារក្នុងសហគ្រាសបរទេស មានចំនួនប្រហែល១% ទាំងក្នុងចំណោមបុរសនិងក្នុងចំណោមស្ត្រី។ រីឯប្រភេទការងារផ្សេងទៀត មានចំនួនសរុបប្រហែល១%។

### ៣.២.៧. កម្រិតសិក្សាអប់រំរបស់ជនជាតិដើមភាគតិចដែលមានការងារធ្វើ

តារាងទី ២៨. កម្រិតអប់រំខ្ពស់បំផុតរបស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ដែលមានការងារធ្វើ

| កម្រិតអប់រំខ្ពស់បំផុត | ប្រុស | ស្រី | សរុប |
|---|---|---|---|
| មិនបានរៀនសោះ | ០,០៤ | ០,០៥ | ០,០៤ |
| បឋមសិក្សា (ថ្នាក់ទី១-៦) | ៦៩,០៨ | ៧០,៤៦ | ៦៩,៦៥ |
| អនុវិទ្យាល័យ(ថ្នាក់ទី៧-៩) | ១៨,៥៦ | ១៧,៤១ | ១៨,០៩ |
| សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | ០,៦៩ | ០,៥៤ | ០,៦៣ |
| វិទ្យាល័យ(ថ្នាក់ទី១០-១២) | ៦,៩៤ | ៦,០៥ | ៦,៥៧ |
| សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ១,១២ | ១,១១ | ១,១២ |
| បណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស | ០,២១ | ០,២៦ | ០,២៣ |
| ឧត្តមសិក្សា | ១,០៤ | ០,៦៩ | ០,៨៩ |
| ផ្សេងៗ ឬមិនបានបញ្ជាក់ | ២,៣២ | ៣,៤២ | ២,៧៨ |
| សរុប | ១០០ | ១០០ | ១០០ |

តារាងទី២៨ខាងលើ បង្ហាញពីរបាយភាគរយនៃកម្រិតសិក្សាអប់រំខ្ពស់បំផុតរបស់ជនជាតិដើមភាគតិច អាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ គិតតាមភេទ។ ជារួម ភាគច្រើននៃជនជាតិដើមភាគតិចអាយុ

១៥ឆ្នាំឡើងដែលមានការងារធ្វើ រៀនបានត្រឹមកម្រិតបឋមសិក្សា (ជិត៧០%ជាសរុប ៦៩%ក្នុងចំណោមបុរស និងប្រហែល៧០%ក្នុងចំណោមស្ត្រី)។ រីឯជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ និងរៀនដល់កម្រិតមធ្យមសិក្សាបឋមភូមិ (មានឬគ្មានសញ្ញាបត្រ) មានចំនួនជិត១៩%ជាសរុប ចំនួន១៩%ក្នុងចំណោមបុរស និងចំនួន១៨%ក្នុងចំណោមស្ត្រី។

រីឯអ្នករៀនដល់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) មានចំនួនប្រហែល៧% (៧%ក្នុងចំណោមបុរស និង៦%ក្នុងចំណោមស្ត្រី) និងអ្នកមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មានចំនួនប្រហែល១% ទាំងក្នុងចំណោមបុរសទាំងក្នុងចំណោមស្ត្រី។ អ្នករៀនដល់កម្រិតឧត្តមសិក្សាមានចំនួនតិចជាង១% (១%ក្នុងចំណោមបុរស និង០,៧%ក្នុងចំណោមស្ត្រី) និងអ្នកបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស មានប្រហែល០,២%ប៉ុណ្ណោះ។

## ៣.៣. សុខភាពនិងអនាម័យ

ជំរឿនមានទិន្នន័យអំពីពិការភាពនិងអនាម័យ តែពុំមានទិន្នន័យពាក់ព័ន្ធនឹងការមានជំងឺនិងការស្វែងរកសេវាសុខភាពឡើយ។ អង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ច មានទិន្នន័យអំពីការមានជំងឺនិងការស្វែងរកសេវាពិគ្រោះនិងព្យាបាលជំងឺ។ ដូចនេះ ទិន្នន័យទាំងពីរប្រភព គឺជំរឿនឆ្នាំ២០១៩និងអង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ចឆ្នាំ២០១៩-២០២០ ត្រូវបានយកមកប្រើប្រាស់នៅក្នុងផ្នែកនៃសុខភាពនិងអនាម័យក្នុងរបាយការណ៍នេះ។ គួរកត់សម្គាល់ថា ប្រភពទិន្នន័យទាំងពីរ បង្ហាញពីអត្តសញ្ញាណជនជាតិដើមភាគតិចខុសៗគ្នា។ ជំរឿនកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច ដោយប្រើភាសានិយាយពីកំណើត ឯអង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ចចែកប្រជាជនកម្ពុជា ជាជនជាតិខ្មែរ (Khmer), ជនជាតិភាគតិច (Ethnic groups), និងជនជាតិភាគតិចក្នុងស្រុកផ្សេងទៀត (Other local ethnic groups)។ ក្នុងរបាយការណ៍នេះ ជនជាតិភាគតិចក្នុងស្រុកផ្សេងទៀតត្រូវបានសន្មតថាជាជនជាតិដើមភាគតិច និងហៅថាជនជាតិភាគតិចក្នុងស្រុក ដែលជាសរុបមានចំនួន ២៤០.៦២៨នាក់ (ស្មើនឹង ១,៦%នៃប្រជាជនកម្ពុជាសរុប) ដែលក្នុងនោះស្ត្រីមានចំនួន ១២៣.២៤០នាក់ (ស្មើនឹង៥១,២%នៃជនជាតិភាគតិចក្នុងស្រុកទាំងអស់)។

### ៣.៣.១. ការមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ

ក្នុងចំណោមជនជាតិភាគតិចក្នុងស្រុកទាំងអស់ ៣១.១៥១នាក់ (ស្មើនឹង១៣,៩៥%) ធ្លាប់មានជំងឺ និង១៨០នាក់ (ស្មើនឹង០,០៧%) ធ្លាប់មានរបួស ក្នុងរយៈពេល៣០ថ្ងៃមុនពេលធ្វើអង្កេត។ ជាសរុបភាគរយអ្នកធ្លាប់មានជំងឺ គឺប្រហាក់ប្រហែលគ្នារវាងក្រុមប្រុសនិងក្រុមស្រី (១៣,២% ទល់នឹង ១២,៩% រៀងគ្នា) តែភាពខុសគ្នានៃភេទនេះមានទំហំគួរកត់សម្គាល់បើគិតតាមក្រុមអាយុនីមួយៗ គឺកុមារាឈឺច្រើនជាងកុមារី និងបុរសវ័យចាស់ឈឺច្រើនជាងស្ត្រីវ័យចាស់ ដែលនិន្នាការនេះដូចគ្នានឹងនិន្នាការនៅក្នុងរបាយការណ៍ជំបូង។ ជាក់ស្តែង៖

- កុមារាអាយុក្រោម៥ឆ្នាំ ឈឺច្រើនជាងកុមារីក្នុងវ័យដូចគ្នា៖ ២១,២% ទល់នឹង ១៣,៧% រៀងគ្នា
- កុមារាអាយុ៥-១៤ ឆ្នាំ ឈឺច្រើនជាងកុមារីក្នុងវ័យដូចគ្នា៖ ៩,២% ទល់នឹង ៧,៩% រៀងគ្នា
- បុរសអាយុ១៥-៥៤ឆ្នាំ ឈឺតិចជាងស្ត្រីក្នុងវ័យដូចគ្នា៖ ១១,៤% ទល់នឹង ១៣,៧% រៀងគ្នា
- បុរសវ័យ៥៥ឆ្នាំឡើង ឈឺច្រើនជាងស្ត្រីក្នុងវ័យដូចគ្នា៖ ២៧,២% ទល់នឹង ២០,២% រៀងគ្នា

ក្រាភិកទី ៣៩. ភាគរយអ្នកមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមភេទនិងក្រុមអាយុ




### ៣.៣.២. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ

គួរកត់សម្គាល់ផងដែរថា ប្រភេទជំងឺដែលមាននៅក្នុងអង្កេតឆ្នាំ២០១៩-២០២០ មានចំនួនច្រើន និងលម្អិតជាងប្រភេទជំងឺនៅក្នុងអង្កេតឆ្នាំ២០១៥។ ក្នុងចំណោមជនជាតិភាគតិចក្នុងស្រុកដែលធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ភាគច្រើនមានជំងឺគ្រុនផ្ដាសាយ(៣០,១%) ជំងឺគ្រុនឈាម(១៤,១%) ជំងឺគ្រុនសន្និ(៩,៩%) ជំងឺក្រពះ(៩,៣%) ជំងឺទាក់ទងនឹងសន្លាក់ឆ្អឹង(៩,២%) និងជំងឺរាគរូស(៧,៤%)។ រីឯអ្នកធ្លាប់មានជំងឺផ្លូវដង្ហើមមានតែ២,៨% ជំងឺគ្រុនចាញ់មាន២% និងជំងឺអាសន្នរោគមានត្រឹមតែ០,៧% ប៉ុណ្ណោះ (ក្រាភិកទី៤០ ខាងក្រោម)។

បើគិតតាមក្រុមអាយុនៃជនជាតិភាគតិចក្នុងស្រុកដែលធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ (ក្រាភិកទី៤១ខាងក្រោម) កុមារអាយុក្រោម៥ឆ្នាំច្រើនមានជំងឺគ្រុនផ្ដាសាយ(៥៦,៦%) ជំងឺគ្រុនឈាម(១៥%) ជំងឺរាគរូស(១១,៤%) ជំងឺផ្លូវដង្ហើម(៦,៩%) និងជំងឺអាសន្នរោគ(៤,៨%)។ កុមារអាយុ៥-១៤ឆ្នាំ ច្រើនមានជំងឺគ្រុនផ្ដាសាយ(៣៨,០%) ជំងឺគ្រុនឈាម(១៨,៥%) ជំងឺរាគរូស(១៨,៤%) ជំងឺគ្រុនចាញ់(៩,០%) និងជំងឺគ្រុនសន្និ(៦,៥%)។ រីឯក្រុមមនុស្សពេញវ័យអាយុ១៥-៥៤ឆ្នាំ ច្រើនមានជំងឺគ្រុនផ្ដាសាយ(១៥,៨%) ជំងឺគ្រុនឈាម(១៥,៤%) ជំងឺក្រពះ(១៥,៣%) ជំងឺគ្រុនសន្និ(១៤,៤%) ជំងឺសន្លាក់

(១២,៧%) និងជំងឺបេះដូងឬលើសឈាម(៧,៤%)។ ដោយឡែក ក្រុមមនុស្សវ័យចាស់អាយុ៥៥ឆ្នាំឡើង ច្រើនមានជំងឺគ្រុនផ្តាសាយ(៤៩,១%) ជំងឺសន្លាក់(១៩%) ជំងឺក្រពះ(៧,៨%) ជំងឺគ្រុនសន្ធំ(៧%) និង ជំងឺបេះដូងឬលើសឈាម (៦,៧%)។

ក្រាភិកទី ៤០. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ



ក្រាភិកទី ៤១. ជំងឺដែលឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមក្រុមអាយុ




ជំងឺស្ត្រីត្រូវបានបំបែកចេញដោយឡែកសម្រាប់ស្ត្រី (តារាងទី២៩ខាងក្រោម)។ ក្នុងចំណោមស្ត្រីជនជាតិភាគតិចក្នុងស្រុកអាយុ១៥-៥៤ឆ្នាំចំនួន៩.៧២០នាក់ ដែលធ្លាប់មានជំងឺក្នុងរយៈពេល៣០ថ្ងៃ

ចុងក្រោយ ស្ត្រីចំនួន២៨៨នាក់ (ស្មើនឹង៣,០%) មានជំងឺមហារីកកស្បូន, ស្ត្រីចំនួន ៤៣៩នាក់ (ស្មើនឹង ៤,៥%) មានជំងឺគីសឬមហារីកដៃស្បូន, និងស្ត្រីចំនួន១៧៩នាក់ (ស្មើនឹង១,៨%) មានជំងឺផ្សេងទៀតពាក់ព័ន្ធនឹងជំងឺស្ត្រី ។

តារាងទី ២៩. ជំងឺស្ត្រី

| | ចំនួន | ភាគរយ |
|---|---|---|
| សរុបស្ត្រីអាយុ១៥-៥៤ឆ្នាំ | ៧១.១២៧ | |
| សរុបស្ត្រីធ្លាប់ឈឺក្នុងអំឡុង៣០ថ្ងៃមុនអង្កេត | ៩.៧២០ | ១៣,៧% |
| ជំងឺដែលឈឺក្នុងអំឡុង៣០ថ្ងៃមុនអង្កេត | ចំនួន | ភាគរយ |
| មហារីកកស្បូន | ២៨៨ | ៣,០% |
| គីសឬមហារីកដៃស្បូន | ៤៣៩ | ៤,៥% |
| រោគស្ត្រីផ្សេងទៀត | ១៧៩ | ១,៨% |
| ជំងឺផ្សេងទៀតក្រៅពីរោគស្ត្រី | ៨.៨១៤ | ៩០,៧% |
| សរុបស្ត្រីធ្លាប់ឈឺក្នុងអំឡុង៣០ថ្ងៃមុនអង្កេត | ៩.៧២០ | ១០០,០% |

### ៣.៣.៣. ការរកសេវាពិគ្រោះនិងព្យាបាលជំងឺ

ក្រាភិកទី៤២ខាងក្រោម បង្ហាញពីទិន្នន័យពីរប្រភេទដាច់ដោយឡែកពីគ្នា តាមក្រុមអាយុនីមួយៗ របស់ជនជាតិភាគតិចក្នុងស្រុក គឺ ភាគរយអ្នកដែលមានជំងឺរយៈពេល១ឆ្នាំឡើងទៅ និងភាគរយអ្នកមានជំងឺដែលបានស្វែងរកសេវាពិគ្រោះនិងព្យាបាលជំងឺ។ ក្នុងចំណោមអ្នកមានជំងឺក្នុងក្រុមអាយុ៥៥ឆ្នាំឡើង ៧៣,៤%មានជំងឺជាងមួយឆ្នាំហើយ ដែលភាគរយនេះមានត្រឹមតែ៣០%ក្នុងក្រុមអាយុ១៥-៥៤ឆ្នាំ និង ៤,១%ក្នុងចំណោមកុមារអាយុ៥-១៤ឆ្នាំ។ ភាគរយអ្នកជំងឺដែលបានស្វែងរកសេវាពិគ្រោះនិងព្យាបាលជំងឺ មានចំនួនប្រហាក់ប្រហែលគ្នា ចំពោះក្រុមអាយុនីមួយៗ ដែលជារួមមានចំនួនជាង៩០%។ ក្រុមអាយុដែលស្វែងរកសេវាតិចជាងគេ គឺក្រុមអាយុ៥-១៤ឆ្នាំ (៩០,៤%) ឯក្រុមអាយុដែលស្វែងរកសេវាច្រើនជាងគេ គឺក្រុមអាយុ០-៤ឆ្នាំ (៩៦,១%) និងក្រុមអាយុ៥៥ឆ្នាំឡើង (៩៤,៥%)។

ក្រាភិកទី ៤២. ភាគរយរកសេវាពិគ្រោះនិងព្យាបាល និងភាគរយមានជំងឺចាប់ពី១ឆ្នាំទៅ តាមក្រុមអាយុ




សេវាពិគ្រោះនិងព្យាបាលជំងឺ ដែលអ្នកធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយបានស្វែងរកមុនគេបង្អស់ គឺឱសថស្ថាន(២៣,២%) គ្លីនិកឯកជន(២១,៧%) មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ(១៥,១%) និងមណ្ឌលសុខភាព(១៤,៤%)។ សេវាពិគ្រោះនិងព្យាបាលជំងឺ ដែលអ្នកធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយបានស្វែងរកចុងក្រោយបង្អស់ មានមន្ទីរពេទ្យបង្អែកខេត្ត(២៥,៤%) មន្ទីរពេទ្យឯកជន(១៥,៨%) គ្លីនិកឯកជន(១៤,៨%) ឱសថស្ថាន(១៤,៣%) និងមន្ទីរពេទ្យបង្អែកស្រុក(១៥,១%)។ ភាពខុសគ្នាគួរកត់សម្គាល់ គឺការស្វែងរកសេវាសុខភាពនៅឱសថស្ថាន គ្លីនិកឯកជន និងមណ្ឌលសុខភាពមានចំនួនច្រើននាពេលស្វែងរកសេវាសុខភាពលើកដំបូង និងមានចំនួនតិចជាងច្រើននាពេលស្វែងរកសេវាសុខភាពលើកចុងក្រោយបង្អស់។ ផ្ទុយទៅវិញ ការស្វែងរកសេវាសុខភាពលើកចុងក្រោយនៅមន្ទីរពេទ្យបង្អែកខេត្តមានចំនួនជិត៤ដង និងនៅមន្ទីរពេទ្យឯកជនមានចំនួន២,៥ដង ច្រើនជាងការស្វែងរកសេវាសុខភាពលើកដំបូងបង្អស់។

ក្រាភិកទី ៤៣. សេវាសុខភាពដែលបានរកមុនគេនិងក្រោយគេបង្អស់ នាពេលឈឺ៣០ថ្ងៃចុងក្រោយ




## ៣.៣.៤. ការបំបៅដោះនិងការចិញ្ចឹមកូន

ស្ត្រីជនជាតិភាគតិចក្នុងស្រុកដែលមានទារកអាយុ០-២៣ខែនាពេលអង្កេត ត្រូវបានសាកសួរអំពីការបំបៅដោះកូនក្រោយពេលកើត អំពីចំណីអាហារដែលបានផ្តល់ឱ្យទារកនាពេល១ថ្ងៃមុនអង្កេត និងអំពីការបានចាក់ថ្នាំបង្ការ។ ស្ត្រីជនជាតិភាគតិចក្នុងស្រុក ទាំងនៅទីប្រជុំជនទាំងនៅជនបទ សុទ្ធបានបំបៅដោះកូនក្រោយកើតទាំងអស់ ក៏ប៉ុន្តែពេលវេលានៃការចាប់ផ្តើមបំបៅដោះកូនខុសគ្នាខ្លះៗ។ ស្ត្រីនៅទីប្រជុំជន មិនបានចាប់ផ្តើមបំបៅដោះកូនក្នុងពេលមួយម៉ោងក្រោយកើតទេ ដែលភាគច្រើនចាប់ផ្តើមបំបៅដោះកូនក្នុងអំឡុងពី១ម៉ោងទៅ២៣ម៉ោងក្រោយកើត (៧៧,៤%) និងក្រៅពីនោះ គឺចាប់ផ្តើមបំបៅដោះកូន១ថ្ងៃក្រោយកើត។ ផ្ទុយទៅវិញ ស្ត្រីនៅជនបទចំនួន៣១% បានចាប់ផ្តើមបំបៅដោះកូនក្នុងពេលមួយម៉ោងក្រោយកើត ៥៣%បានចាប់ផ្តើមបំបៅដោះកូនក្នុងអំឡុងពី១ម៉ោងទៅ២៣ម៉ោងក្រោយកើត និង១៦%

បានចាប់ផ្តើមបំបៅដោះកូន១ថ្ងៃក្រោយកើត (តារាងទី៣០)។ លើសពីនេះទៀត ស្ត្រីជាមាតានៅទីប្រជុំជនចំនួន៧២% និងស្ត្រីនៅជនបទចំនួន១០០%នៅបន្តបំបៅដោះកូនអាយុ០-២៣ខែនាពេលធ្វើអង្កេត។

តារាងទី ៣០. ការបំបៅដោះកូនក្រោយកើតរបស់មាតាជនជាតិដើមភាគតិច

| | ទីប្រជុំជន | ជនបទ | សរុប |
|---|---|---|---|
| **ចំនួនទារក ០-២៣ខែ** | **៥២៦** | **៨.៥៧៦** | **៩.១០២** |
| **%បំបៅដោះក្រោយកើត** | **១០០%** | **១០០%** | **១០០%** |
| **ពេលវេលាចាប់ផ្តើមបំបៅដោះកូន** | | | |
| ក្នុងពេល១ម៉ោងក្រោយកើត | ០,០% | ៣១,០% | ២៩,១៨% |
| ក្នុងពេលពី១ម៉ោងទៅ១ថ្ងៃក្រោយកើត | ៧៧,៤% | ៥៣,០% | ៥៤,៣៦% |
| ចាប់ពី១ថ្ងៃក្រោយកើតទៅ | ២២,៦% | ១៦,១% | ១៦,៤៦% |
| សរុប | ១០០% | ១០០% | ១០០% |
| **%នៅបន្តបំបៅដោះ** | **៧២%** | **១០០%** | **៩៨%** |

### ៣.៣.៦. ការចាក់ថ្នាំបង្ការរបស់ទារកអាយុក្រោម២ឆ្នាំ

តារាងទី ៣១. ការចាក់វ៉ាក់សាំងបង្ការរបស់ទារកអាយុក្រោម២ឆ្នាំ

| | ទីប្រជុំជន | ជនបទ | សរុប |
|---|---|---|---|
| **ចំនួនទារក ០-២៣ខែ** | **៥២៦** | **៨.៥៧៥** | **៩.១០១** |
| **%បានចាក់វ៉ាក់សាំងបង្ការ** | **១០០,០%** | **៨៧,៨%** | **៨៨,៥%** |
| **ទីកន្លែងចាក់វ៉ាក់សាំងបង្ការចំពោះទារកបានចាក់ថ្នាំបង្ការ** | | | |
| យុទ្ធនាការ | ០,០% | ១,៤% | ១,២% |
| ចុះដល់កន្លែង | ០,០% | ២៣,៨% | ១៩,៧% |
| មណ្ឌលសុខភាព | ៧៧,៤% | ៦៩,៦% | ៦២,១% |
| មន្ទីរពេទ្យ | ២២,៦% | ៥,២% | ៥,៦% |
| គ្លីនិកឯកជន | ០,០% | ០,០% | ០,០% |
| សរុប | ១០០,០% | ១០០,០% | ១០០,០% |

ជាសរុប ៨៨,៥%នៃទារកអាយុក្រោម២ឆ្នាំក្នុងពេលធ្វើអង្កេត បានចាក់ថ្នាំបង្ការ (១០០%នៅទីប្រជុំជន និង៨៧,៨%នៅជនបទ) (តារាងទី៣១)។

ចំពោះទារកនៅទីប្រជុំជន ភាគច្រើននៃការទទួលបានការចាក់ថ្នាំបង្ការ គឺនៅមណ្ឌលសុខភាព (៧៧,៤%) និងនៅមន្ទីរពេទ្យ (២២,៦%)។ ចំពោះទារកនៅជនបទ ភាគច្រើននៃការទទួលបានការចាក់ថ្នាំបង្ការ គឺនៅមណ្ឌលសុខភាព (៦៩,៦%) ការចុះចាក់ដល់ទីកន្លែង (២៣,៨%) នៅមន្ទីរពេទ្យ (៥,២%) និងនាពេលយុទ្ធនាការចាក់វ៉ាក់សាំង (១,៤%)។ អង្កេតមិនបានប្រមូលទិន្នន័យអំពីការចាក់ថ្នាំបង្ការគ្រប់ឬមិនគ្រប់ចំនួនទេ។

### ៣.៣.៧. ពិការភាព

នៅឆ្នាំ២០១៩ ជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើងដែលមានពិការភាពណាមួយ នៅក្នុងកម្រិតណាមួយ មានចំនួន ៨.១៨៦នាក់ (ប្រុស ៣.៦៣៦នាក់ និងស្រី ៤.៥៥០នាក់) ដែលស្មើនឹង៥,៣% នៃប្រជាជនជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើងសរុប។ ភាគរយនេះខុសគ្នាតិចតួចបើធៀបទៅនឹងភាគរយប្រជាជនកម្ពុជាក្នុងវ័យដូចគ្នាដែលមានពិការភាពនៅឆ្នាំ២០១៩ ដែលមានចំនួន៤,៩%។ ក៏ប៉ុន្តែភាគរយនៅឆ្នាំ២០១៩នេះ មានទំហំធំជាងភាគរយក្នុងឆ្នាំ២០០៨និង២០១៣ ដែលអ្នកមានពិការភាពមានចំនួនតិចជាង២%[២៦]។

ស្ត្រីជនជាតិដើមភាគតិចមានពិការភាពច្រើនជាងបុរសតិចតួច គឺ៥,៧%ទល់នឹង៤,៨% ជាសរុប និងគ្រប់ប្រភេទនៃពិការភាព (តារាងទី៣២)។ លើសពីនេះទៀត ភាគរយនៃពិការភាពតាមប្រភេទពិការភាពនីមួយៗមានចំនួនខុសគ្នាតិចតួច ដែលច្រើនជាងគេគឺពិការភាពទាក់ទងនឹងការមើល (ចំនួន៣,៧% ជាសរុប ៤,២%ក្នុងចំណោមស្ត្រី និង៣,២%ក្នុងចំណោមបុរស) និងតិចជាងគេគឺពិការភាពទាក់ទងនឹងការនិយាយប្រាស្រ័យទាក់ទង (ចំនួន២,២%ជាសរុប ២,៦%ក្នុងចំណោមស្ត្រី និង១,៩%ក្នុងចំណោមបុរស)។

បើគិតតាមក្រុមអាយុ (តារាងទី៣៣) ប្រជាជនវ័យចាស់មានភាគរយអ្នកពិការច្រើនជាងគេ។ ជាក់ស្តែង ភាគរយអ្នកមានពិការភាពក្នុងចំណោមកុមារអាយុ៥-១៧ឆ្នាំមានចំនួនប្រហាក់ប្រហែល៥% ក្នុងចំណោមអាយុ១៨-៥៩ឆ្នាំមានចំនួនប្រហាក់ប្រហែល២ទៅ៣% និងក្នុងចំណោមអាយុ៦០ឆ្នាំឡើងមានចំនួនពី ១៦%ទៅ២៤%ក្នុងចំណោមបុរស និងពី ២១%ទៅ២៨%ក្នុងចំណោមស្ត្រី។ បុរសវ័យចាស់ច្រើនមានពិការភាពទាក់ទងនឹងការមើល ការស្តាប់ ការចងចាំ និងការធ្វើចលនាឬផ្លាស់ទី ច្រើនជាងពិការភាពទាក់ទងនឹងការថែទាំខ្លួនដោយខ្លួនឯង និងការនិយាយប្រាស្រ័យទាក់ទង ទាំងបុរសទាំងស្ត្រី។

---

[២៦] សូមមើលរបាយការណ៍ឆ្នាំ២០២១។

តារាងទី ៣២.  ចំនួននិងភាគរយអ្នកមានពិការភាពអាយុ៥ឆ្នាំឡើង

| ប្រភេទពិការភាព | ប្រុស | | ស្រី | | សរុប | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ការមើល | ២.៤៦៩ | ៣,២ | ៣.២៩២ | ៤,២ | ៥.៧៦១ | ៣,៧ |
| ការស្តាប់ | ២.០៨២ | ២,៧ | ២.៨៦៦ | ៣,៦ | ៤.៩៤៨ | ៣,២ |
| ការធ្វើចលនាឬផ្លាស់ទី | ១.៧៨៣ | ២,៣ | ២.៤៤៩ | ៣,១ | ៤.២៣២ | ២,៧ |
| ការចងចាំឬផ្ចង់អារម្មណ៍ | ១.៩៦៦ | ២,៦ | ២.៧៣០ | ៣,៤ | ៤.៦៩៦ | ៣,០ |
| ការថែទាំខ្លួនដោយខ្លួនឯង | ១.៤៣៩ | ១,៩ | ១.៩៩៤ | ២,៥ | ៣.៤៣៣ | ២,២ |
| ការនិយាយប្រាស្រ័យទាក់ទង | ១.៤១៥ | ១,៩ | ២.០៤០ | ២,៦ | ៣.៤៥៥ | ២,២ |
| **ជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង** | | | | | | |
| ចំនួនសរុប | ៧៦.១៥៩ | | ៧៩.២៤៣ | | ១៥៥.៤០២ | |
| ចំនួនអ្នកមានពិការភាព (គ្រប់កម្រិត) | ៣.៦៣៦ | | ៤.៥៥០ | | ៨.១៨៦ | |
| ភាគរយអ្នកមានពិការភាព | ៤,៨ | | ៥,៧ | | ៥,៣ | |
| **ប្រជាជនកម្ពុជាអាយុ៥ឆ្នាំឡើង** | | | | | | |
| ចំនួនសរុប | ៦.៨២៥.៨៧៤ | | ៧.២៧៦.១៧៨ | | ១៤.១០២.០៥២ | |
| ចំនួនអ្នកពិការ (គ្រប់កម្រិត) | ២៨៦.៦៥៩ | | ៤០២.៨៧៣ | | ៦៨៩.៥៣២ | |
| ភាគរយអ្នកពិការ | ៤,២ | | ៥,៥ | | ៤,៩ | |

តារាងទី ៣៣.  ភាគរយអ្នកមានពិការភាពតាមភេទនិងក្រុមអាយុ

| ប្រភេទពិការភាព | ប្រុស | | | ស្រី | | |
|---|---|---|---|---|---|---|
| | ៥-១៧ឆ្នាំ | ១៨-៥៩ឆ្នាំ | ៦០ឆ្នាំឡើង | ៥-១៧ឆ្នាំ | ១៨-៥៩ឆ្នាំ | ៦០ឆ្នាំឡើង |
| ការមើល | ០,៥ | ២,៨ | ២៤,១ | ០,៥ | ៣,២ | ២៨,៤ |
| ការស្តាប់ | ០,៦ | ២,២ | ២១,៣ | ០,៦ | ២,៥ | ២៦,៤ |
| ការធ្វើចលនាឬផ្លាស់ទី | ០,៥ | ១,៦ | ២០,៤ | ០,៤ | ១,៩ | ២៤,៩ |
| ការចងចាំឬផ្ចង់អារម្មណ៍ | ០,៦ | ២,០ | ២០,១ | ០,៥ | ២,៤ | ២៥,១ |
| ការថែទាំខ្លួនដោយខ្លួនឯង | ០,៦ | ១,២ | ១៦,២ | ០,៥ | ១,៤ | ២០,៩ |
| ការនិយាយប្រាស្រ័យទាក់ទង | ០,៥ | ១,២ | ១៥,៩ | ០,៥ | ១,៤ | ២១,០ |

### ៣.៣.៨. អនាម័យ

យោងតាមទិន្នន័យឆ្នាំ២០១៩ (តារាងទី ៣៤) គ្រួសារជនជាតិដើមភាគតិចប្រហែល ៥៦% គ្មានបង្គន់ប្រើប្រាស់ (ដែលមានចំនួន៣ដងច្រើនជាងកម្ពុជាសរុប ដែលមានត្រឹម១៧,២%) និងមានចំនួន ២៧,៨% ក្នុងចំណោមគ្រួសារនៅទីប្រជុំជន (៩,៦%ក្នុងចំណោមគ្រួសារកម្ពុជាសរុបនៅទីប្រជុំជន) និង ៥៨% ក្នុងចំណោមគ្រួសារនៅជនបទ (២១,៧% ក្នុងចំណោមគ្រួសារកម្ពុជាសរុបនៅជនបទ)។

ក្រៅពីនោះ គ្រួសារជនជាតិដើមភាគតិចប្រហែល២៧%មានបង្គន់បង្ហូរប្រើប្រាស់ (ប្រហែល ៦០% ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និងប្រហែល ២៤% ក្នុងចំណោមគ្រួសារនៅជនបទ) និងប្រហែល១៤%ប្រើប្រាស់បង្គន់រណ្តៅ (ប្រហែល ១០% ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និងប្រហែល ១៥% ក្នុងចំណោមគ្រួសារនៅជនបទ)។ ទោះជាមានចំនួនទាបជាងប្រជាជនកម្ពុជាសរុបក៏ដោយ ភាគរយនៃគ្រួសារជនជាតិដើមភាគតិចដែលមានបង្គន់អនាម័យប្រើប្រាស់ (បង្គន់បង្ហូរ) កើនឡើងជិត៧ដងធៀបនឹងឆ្នាំ២០០៨ និងប្រហែល២,៥ដងធៀបនឹងឆ្នាំ២០១៣ (សូមមើលរបាយការណ៍ដែលផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០២២)។

តារាងទី ៣៤. ការប្រើប្រាស់បង្គន់អនាម័យនៃគ្រួសារជនជាតិដើមភាគតិច

| | ទីប្រជុំជន | | ជនបទ | | សរុប | |
|---|---|---|---|---|---|---|
| | ជនជាតិដើមភាគតិច | កម្ពុជា | ជនជាតិដើមភាគតិច | កម្ពុជា | ជនជាតិដើមភាគតិច | កម្ពុជា |
| **ចំនួនគ្រួសារ (ពាន់)** | **២,៧១** | **១.៣២៩** | **៣៥,២២** | **២.២២៥** | **៣៧,៩៣** | **៣.៥៥៣** |
| **ភាគរយសរុប** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| គ្មានបង្គន់ប្រើប្រាស់ | ២៧,៨ | ៩,៦ | ៥៨,០ | ២១,៧ | ៥៥,៨ | ១៧,២ |
| បង្គន់ចាក់ឬចុចបង្ហូរទឹក | ២៤,០ | ៤៤,៨ | ៧,៤ | ១៩,៤ | ៨,៦ | ២៨,៩ |
| បង្គន់បង្ហូរទៅអាងឬរណ្តៅ | ២៩,៣ | ៣៤,៧ | ១១,៣ | ៣៩,៦ | ១២,៥ | ៣៧,៨ |
| បង្គន់បង្ហូរទៅកន្លែងផ្សេង | ៦,៣ | ៧,១ | ៥,៧ | ៩,៥ | ៥,៧ | ៨,៦ |
| បង្គន់រណ្តៅមានចានបង្គន់ | ៨,៣ | ២,៤ | ៧,៨ | ៥,៤ | ៧,៩ | ៤,៣ |
| បង្គន់រណ្តៅគ្មានផែនបង្គន់ | ១,៨ | ០,៦ | ៦,៧ | ២,៣ | ៦,៤ | ១,៧ |
| បង្គន់ទម្លាក់ក្នុងទឹក | ២,១ | ០,៥ | ១,៦ | ១,០ | ១,៦ | ០,៨ |
| ផ្សេងទៀត | ០,៤ | ០,៣ | ១,៤ | ១,១ | ១,៤ | ០,៨ |

ចំពោះប្រភពទឹកស្អាតសម្រាប់បរិភោគ (តារាងទី៣៥) គ្រួសារជនជាតិដើមភាគតិចច្រើនប្រើប្រាស់ទឹកអណ្ដូង គឺជាសរុបមានចំនួនប្រហែល៥២% រាប់ទាំងអណ្ដូងស្នប់ អណ្ដូងមានគម្រប និងអណ្ដូងគ្មានគម្រប (ប្រហែល៣៦%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និងប្រហែល៥៤%ក្នុងចំណោមគ្រួសារនៅជនបទ)។ រីឯគ្រួសារមានទឹកបំពង់បណ្ដាញប្រើប្រាស់ មានចំនួនជិត១០%ប៉ុណ្ណោះជាសរុប (ប្រហែល២៧%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និងប្រហែល៨%ក្នុងចំណោមគ្រួសារនៅជនបទ) ដែលតិចជាងកម្ពុជាសរុបប្រហែល៣ដង ដែលមានចំនួន៣៣% (៥៧%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង១៩%ក្នុងចំណោមគ្រួសារនៅជនបទ)។ ការប្រើប្រាស់ទឹកលើដី (មានទឹកទន្លេ បឹង ស្ទឹង ព្រែក ជាដើម) មានចំនួនជិត១ភាគ៤នៃគ្រួសារជនជាតិដើមភាគតិចទាំងអស់ (២៣%ជាសរុប, ១២,៦%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន, និងជិត២៤%ក្នុងចំណោមគ្រួសារនៅជនបទ)។ ជារួម បើប្រៀបធៀបជាមួយនឹងរបាយការណ៍ផ្សព្វផ្សាយនៅឆ្នាំ២០២២ ភាគរយគ្រួសារជនជាតិដើមភាគតិចដែលមានប្រភពទឹកស្អាតប្រើប្រាស់ បានកើនឡើង។

តារាងទី ៣៥.   ប្រភពទឹកស្អាតសម្រាប់ទទួលទាន

| | ទីប្រជុំជន | | ជនបទ | | សរុប | |
|---|---|---|---|---|---|---|
| | ជនជាតិដើមភាគតិច | កម្ពុជា | ជនជាតិដើមភាគតិច | កម្ពុជា | ជនជាតិដើមភាគតិច | កម្ពុជា |
| **ចំនួនគ្រួសារ (ពាន់)** | **២,៧០៩** | **១.៣២៩** | **៣៥,២២០** | **២.២២៥** | **៣៧,៩២៩** | **៣.៥៥៣** |
| **ប្រភពទឹកស្អាត %សរុប** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| ទឹកបំពង់បណ្តាញដល់ក្នុងផ្ទះ | ២១,២ | ៤៦,៧ | ៤,១ | ១២,៨ | ៥,៣ | ២៥,៥ |
| ទឹកបំពង់បណ្តាញក្នុងបរិវេណផ្ទះ | ៣,៨ | ៤,៩ | ១,៧ | ២,៩ | ១,៨ | ៣,៦ |
| កបំពង់សាធារណៈ | ២,៣ | ៥,៧ | ២,៦ | ២,៨ | ២,៦ | ៣,៩ |
| អណ្តូងស្នប់/ខួង | ១៦,៦ | ១២,៩ | ២០,៦ | ៣២,៦ | ២០,៣ | ២៥,២ |
| អណ្តូងមានគម្រប | ១៥,៤ | ២,២ | ១៤,១ | ៥,៩ | ១៤,២ | ៤,៥ |
| អណ្តូងគ្មានគម្រប | ៤,២ | ១,៤ | ១៨,៨ | ៨,៦ | ១៧,៧ | ៥,៩ |
| ទឹកចេញក្រោមដីមានការការពារ | ០,៥ | ០,២ | ០,៩ | ០,៤ | ០,៨ | ០,៣ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,៦ | ០,១ | ៣,៨ | ០,៥ | ៣,៦ | ០,៣ |
| ទឹកភ្លៀង | ០,៤ | ១,៥ | ០,៣ | ៣,៥ | ០,៣ | ២,៨ |
| ទឹកឡានស៊ីទែន(ទិញ) | ៤,០ | ៤,៨ | ២,៩ | ៥,០ | ៣,០ | ៤,៩ |
| ទឹកធុងរទេះ(ទិញ) | ១០,០ | ៤,០ | ២,៤ | ៥,៣ | ២,៩ | ៤,៨ |
| ទឹកលើដី (ទន្លេ បឹង ស្ទឹង...) | ១២,៦ | ៥,៤ | ២៣,៨ | ១៣,៧ | ២៣,០ | ១០,៦ |
| ទឹកពិសាដប | ៧,៧ | ៩,៨ | ២,៩ | ៥,៤ | ៣,២ | ៧,១ |
| ផ្សេងទៀត | ០,៩ | ០,៦ | ១,២ | ០,៧ | ១,២ | ០,៦ |

## ៣.៤. សាសនានិងជំនឿ

ទិន្នន័យជំរឿនឆ្នាំ២០១៩(តារាងទី៣៦) បង្ហាញថាជនជាតិដើមភាគតិចដែលកាន់ព្រះពុទ្ធសាសនាមានចំនួន៥៤,៨% កាន់ឥស្លាមសាសនាមានចំនួន០,៥% កាន់គ្រឹស្តសាសនាមានចំនួនជិត៥% និងកាន់សាសនាផ្សេងទៀតមានចំនួនជិត៤០%។ នេះបញ្ជាក់ថា ជនជាតិដើមភាគតិចមានសាសនាផ្សេងៗទៀតជាច្រើន ដែលជាជំនឿនិងសាសនារបស់អំបូរខ្លួនជាយូរលង់មកហើយ។

គួរកត់សម្គាល់ថា ទិន្នន័យជំរឿននិងអង្កេតដែលបានប្រើប្រាស់សម្រាប់របាយការណ៍នេះ ពុំមានទិន្នន័យអំពីជំនឿនិងសាសនាផ្សេងទៀតទាំងនោះ ដែលជនជាតិដើមភាគតិចបាននិងកំពុងប្រតិបត្តិទេ។ ដូចនេះ ការស្រាវជ្រាវបន្ថែមអំពីសាសនានិងជំនឿរបស់ជនជាតិដើមភាគតិចនៅកម្ពុជា គួរតែជាប្រធានបទស្រាវជ្រាវដោយឡែកនិងចាំបាច់ សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត។

តារាងទី ៣៦. សាសនា

| | ២០០៨ | | ២០១៩ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ពុទ្ធសាសនា | ៨២.២២៤ | ៤៥,៩ | ៩៤.៧៥៣ | ៥៤,៨ |
| ឥស្លាមសាសនា | ៤៣០ | ០,២ | ៨៩៧ | ០,៥ |
| គ្រិស្តសាសនា | ៥.៥១៣ | ៣,១ | ៨.៤៩០ | ៤,៩ |
| សាសនាផ្សេងទៀត | ៩១.០២៦ | ៥០,៨ | ៦៨.៨៤០ | ៣៩,៨ |
| សរុប | ១៧៩.១៩៣ | ១០០,០ | ១៧២.៩៨០ | ១០០,០ |

# ៤. លំនៅឋាន ដីធ្លី និងកម្មសិទ្ធសម្ភារភាព

ព័ត៌មានអំពីលំនៅឋាន រួមទាំងប្រភពភ្លើងបំភ្លឺ ប្រភពឋាមពលចម្អិនអាហារ និងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន ត្រូវបានទាញចេញពីទិន្នន័យគ្រួសារនៃជំរឿនឆ្នាំ២០១៩ (និងឆ្នាំ២០០៨ និងឆ្នាំ២០១៣ សម្រាប់ការប្រៀបធៀប)។ ទិន្នន័យអំពីគ្រួសារកម្ពុជាសរុប ក៏បានបង្ហាញសម្រាប់ឆ្នាំ២០១៩ សម្រាប់ការប្រៀបធៀបផងដែរ។ រីឯព័ត៌មានអំពីដីនិងកម្មសិទ្ធសម្ភារភាព ត្រូវបានប្រមូលពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងដែនដី សំណង់និងនគរូបនីយកម្ម និងក្រសួងមហាផ្ទៃ ជាដើម។

## ៤.១. ស្ថានភាពលំនៅឋាន

### ៤.១.១. ស្ថានភាពកាន់កាប់លំនៅឋាន

យោងតាមទិន្នន័យគ្រួសារឆ្នាំ២០១៩ ជាង៩៣%នៃគ្រួសារជនជាតិដើមភាគតិចមានលំនៅឋានខ្លួនឯង (៩៣,%ក្នុងចំណោមគ្រួសារនៅជនបទ និង៨៩,១%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន)។ គ្រួសារជនជាតិដើមភាគតិចដែលរស់នៅក្នុងលំនៅឋានគេឱ្យស្នាក់នៅមានចំនួន៥,៨% (៥,៩%ក្នុងចំណោមគ្រួសារនៅជនបទ និង៤,១%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន)។ គ្រួសារជនជាតិដើមភាគតិចដែលជួលផ្ទះគេនៅមានចំនួន០,៧% (០,៣%ក្នុងចំណោមគ្រួសារនៅជនបទ និង៦,៦%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន)។

ធៀបនឹងទិន្នន័យឆ្នាំកន្លងមក ភាគរយគ្រួសារមានលំនៅឋានខ្លួនឯង ថយចុះតិចតួច។ រីឯភាគរយនៃគ្រួសារដែលជួលផ្ទះគេនៅក្នុងទីប្រជុំជនមានភាគរយខ្ពស់នៅឆ្នាំ២០១៩ គឺ៦,៦% (បើធៀបនឹងឆ្នាំ២០០៨ និងឆ្នាំ២០១៣ ដែលមានចំនួនតិចជាង១%) ដែលអាចជាប់ទាក់ទងនឹងការធ្វើទេសន្តរប្រវេសន៍ក្នុងចំណោមគ្រួសារយុវវ័យមកកាន់ទីប្រជុំជន។

តារាងទី ៣៧. ស្ថានភាពសិទ្ធិកាន់កាប់លំនៅឋានរបស់ជនជាតិដើមភាគតិច

| | ឆ្នាំ២០១៩ | | | ឆ្នាំ២០១៣ | ឆ្នាំ២០០៨ |
|---|---|---|---|---|---|
| | ទីប្រជុំជន | ជនបទ | សរុប | សរុប | សរុប |
| ផ្ទះខ្លួនឯង | ៨៩,១ | ៩៣,៥ | ៩៣,២ | ៩៥,៥ | ៩៦,៣ |
| ផ្ទះជួល | ៦,៦ | ០,៣ | ០,៧ | ០,២ | ០,៦ |
| ផ្ទះគេឱ្យស្នាក់នៅ | ៤,១ | ៥,៩ | ៥,៨ | ៣,៩ | ២,៦ |
| ផ្សេងទៀត | ០,៣ | ០,៣ | ០,៣ | ០,៤ | ០,៥ |
| ភាគរយសរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| **ចំនួនគ្រួសារ** | **២.៧០៩** | **៣៥.២២០** | **៣៧.៩២៩** | **៣៧.២០១** | **៣៣.៨២០** |

### ៤.១.២. ប្រភពភ្លើងបំភ្លឺនិងប្រភពថាមពលចម្អិន

ទិន្នន័យអំពីប្រភពភ្លើងបំភ្លឺ ប្រភពឋាមពលចម្អិនអាហារ និងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន (តារាងទី៣៨ ទី៣៩ និងទី៤០ ខាងក្រោម) បង្ហាញពីស្ថានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់នៃគ្រួសារជនជាតិដើមភាគតិច ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ជាពិសេស គឺចំពោះគ្រួសារជនជាតិដើមភាគតិចដែលរស់នៅក្នុងទីប្រជុំជន។

ប្រភពចម្បងនៃភ្លើងបំភ្លឺរបស់គ្រួសារជនជាតិដើមភាគតិច នៅឆ្នាំ២០០៨ គឺចង្កៀងប្រេងកាត (៦៦,២%) និងនៅឆ្នាំ២០១៣ គឺអាគុយ(៤១,៦%) និងចង្កៀងប្រេងកាត(៣៣,៧%)។ នៅឆ្នាំ២០១៩ ប្រភពភ្លើងបំភ្លឺចម្បងរបស់គ្រួសារជនជាតិដើមភាគតិច គឺអាគុយ(៦១%) [ដែលភាគច្រើនមានចំពោះគ្រួសារនៅជនបទ(៦៤,១%)] និងអគ្គិសនីរដ្ឋ(៣១,៣%) [ដែលភាគច្រើនមានចំពោះគ្រួសារនៅទីប្រជុំជន(៧៣,១%)]។ ភាគរយនៃគ្រួសារជនជាតិដើមភាគតិចមានភ្លើងអគ្គិសនីរដ្ឋប្រើប្រាស់ កើនឡើងពីប្រហែល៥% នៅឆ្នាំ២០០៨ មក ១១,៥% នៅឆ្នាំ២០១៣ និងដល់៣១,៣% នៅឆ្នាំ២០១៩ (២៨% ក្នុងចំណោមគ្រួសារនៅជនបទ និង៧៣,១%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន ក្នុងឆ្នាំ២០១៩)។ គ្រួសារជនជាតិដើមភាគតិចដែលប្រើប្រាស់ចង្កៀងប្រេងកាតនិងទៀនជាប្រភពថាមពលបំភ្លឺ មានចំនួនប្រហែល ២%ប៉ុណ្ណោះនៅឆ្នាំ២០១៩ ដែលថយចុះពីប្រហែល៣៦%នៅឆ្នាំ២០១៣ និងពី៦៨% នៅឆ្នាំ២០០៨។

តារាងទី ៣៨. ប្រភពភ្លើងបំភ្លឺ

| | ជនជាតិដើមភាគតិច | | | | | កម្ពុជា |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៩ | | | ឆ្នាំ២០១៣ | ឆ្នាំ២០០៨ | ឆ្នាំ២០១៩ |
| | ទីប្រជុំជន | ជនបទ | សរុប | សរុប | សរុប | សរុប |
| ភ្លើងអគ្គិសនីរដ្ឋ | ៧៣,១ | ២៨,០ | ៣១,៣ | ១១,៥ | ៤,៩ | ៧៩,៦ |
| ម៉ាស៊ីនភ្លើង | ២,៣ | ០,៧ | ០,៨ | ៩,១ | ២,៣ | ១,៦ |
| ភ្លើងអគ្គិសនីរដ្ឋ និងម៉ាស៊ីនភ្លើង | ១,០ | ០,៩ | ០,៩ | ០,៤ | ០,៧ | ២,៨ |
| ចង្កៀងប្រេងកាត | ០,៧ | ០,៨ | ០,៨ | ៣៣,៧ | ៦៦,២ | ០,៦ |
| ទៀន | ០,៧ | ១,៣ | ១,២ | ២,០ | ១,៥ | ០,៣ |
| អាគុយ | ២០,៧ | ៦៤,១ | ៦១,០ | ៤១,៦ | ១១,៦ | ១៣,៤ |
| ផ្សេងទៀត | ១,៦ | ៤,២ | ៤,០ | ១,៧ | ១២,៨ | ១,៦ |
| ភាគរយសរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

ឧស នៅបន្តជាប្រភពចម្បងនៃឋាមពលចម្អិនអាហាររបស់គ្រួសារជនជាតិភាគតិច (៩២,៥% នៅឆ្នាំ២០១៩ ៩៤,៩%នៅឆ្នាំ២០១៣ និង៩៦,៩%នៅឆ្នាំ២០០៨) ពិសេសគឺគ្រួសារដែលរស់នៅជនបទ។ ក្រៅពីឧស ការប្រើប្រាស់ហ្គាសជាប្រភពចម្អិនមានចំនួន៣,៤% (២៨,៣%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង១,៥%នៅជនបទ) ធ្យូងមានចំនួន៣% (៨,២%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង២,៦%នៅជនបទ) និងអគ្គិសនីមានចំនួនតិចជាង១% (២,៥%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង០,៥%នៅជនបទ)។

តារាងទី ៣៩. ប្រភពឋាមពលចម្អិន

| | ជនជាតិដើមភាគតិច | | | | | កម្ពុជា |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៩ | | | ឆ្នាំ២០១៣ | ឆ្នាំ២០០៨ | ឆ្នាំ២០១៩ |
| | ទីប្រជុំជន | ជនបទ | សរុប | សរុប | សរុប | សរុប |
| ឧស | ៦០,៧ | ៩៤,៩ | ៩២,៥ | ៩៤,៩ | ៩៦,៩ | ៦០,៩ |
| ធ្យូង | ៨,២ | ២,៦ | ៣,០ | ១,៦ | ១,០ | ៧,៨ |
| ប្រេងកាត | ០,៣ | ០,១ | ០,១ | ១,១ | ០,៤ | ០,៣ |
| ហ្គាស | ២៨,៣ | ១,៥ | ៣,៤ | ១,៦ | ១,២ | ២៧,៧ |
| អគ្គិសនី | ២,៥ | ០,៥ | ០,៦ | ០,៦ | ០,១ | ៣,០ |
| គ្មាន | ០,០ | ០,៤ | ០,៤ | ០,១ | ០,១ | ០,១ |
| ផ្សេងទៀត | ០,០ | ០,០ | ០,០ | ០,១ | ០,៣ | ០,១ |
| ភាគរយសរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

### ៤.១.៣. សម្ភារៈប្រើប្រាស់ក្នុងផ្ទះ

តារាងខាងក្រោម បង្ហាញពីភាគរយនៃគ្រួសារជនជាតិដើមភាគតិចដែលមានសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ទៅតាមប្រភេទសម្ភារៈនីមួយៗនៅឆ្នាំ២០១៩ (ទាំងនៅជនបទនិងនៅទីប្រជុំជន) ឆ្នាំ២០១៣ និងឆ្នាំ២០០៨ និងគ្រួសារកម្ពុជាសរុបឆ្នាំ២០១៩ សម្រាប់ការប្រៀបធៀប។ ជារួម តារាងខាងក្រោមបង្ហាញពីស្ថានភាពល្អប្រសើរឡើងនៃជីវភាពគ្រួសារជនជាតិដើមភាគតិច តាមរយៈការមានសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ដែលកើនឡើងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ ទោះជាការមានសម្ភារៈទាំងនោះ នៅមានភាគរយតិចជាងគ្រួសារកម្ពុជាសរុបក៏ដោយ។

ជាក់ស្តែង ជិត១ភាគ៤នៃគ្រួសារជនជាតិដើមភាគតិចមានទូរទស្សន៍ប្រើប្រាស់ (២៣,៣%ជាសរុប ៥២,៣%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង២១,១%ក្នុងចំណោមគ្រួសារនៅជនបទ), ៧៨,៧% មានទូរស័ព្ទដៃប្រើប្រាស់ (៨៥,៨%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង៧៨,២%ក្នុងចំណោមគ្រួសារនៅជនបទ), ៧៨,៥%មានម៉ូតូ (៨៣,៥%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង៧៨,១%ក្នុងចំណោមគ្រួសារនៅជនបទ), ២,៧%មានរថយន្ត (១០,៧%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង២,១%ក្នុងចំណោមគ្រួសារនៅជនបទ), ៣,៦%មានទូរទឹកកក (១៨,៦%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង ២,៥%ក្នុងចំណោមគ្រួសារនៅជនបទ), ២,៣%មានកុំព្យូទ័រ (១០,៥%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង១,៧%ក្នុងចំណោមគ្រួសារនៅជនបទ), និង២០,១%មានគោយន្ត (៦,១%ក្នុងចំណោមគ្រួសារនៅទីប្រជុំជន និង២១,២%ក្នុងចំណោមគ្រួសារនៅជនបទ)។

តារាងទី ៤០. សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

| | ជនជាតិដើមភាគតិច | | | | កម្ពុជា |
|---|---|---|---|---|---|
| | ឆ្នាំ២០១៩ | | | ឆ្នាំ២០០៨ | ឆ្នាំ២០១៩ |
| | ទីប្រជុំជន | ជនបទ | សរុប | សរុប | សរុប |
| វិទ្យុ | ១២,៣ | ១២,៤ | ១២,៤ | ៣៨,៩ | ១៦,២ |
| ទូរទស្សន៍ | ៥២,៣ | ២១,១ | ២៣,៣ | ១៩,២ | ៦៧,៥ |
| ទូរស័ព្ទលើតុ | ២,១ | ០,៨ | ០,៩ | ០,៦ | ១,៦ |
| ទូរស័ព្ទដៃ | ៨៥,៨ | ៧៨,២ | ៧៨,៧ | ១៥,៩ | ៩១,៩ |
| កុំព្យូទ័រ | ១០,៥ | ១,៧ | ២,៣ | ១,៣ | ៨,០ |
| កង់ | ២៨,៧ | ២២,៩ | ២៣,៣ | ៤៨,៩ | ៥៥,២ |
| ម៉ូតូ | ៨៣,៥ | ៧៨,១ | ៧៨,៥ | ៤៦,៩ | ៨០,១ |
| ទូរទឹកកក | ១៨,៦ | ២,៥ | ៣,៦ | - | ១៦,៤ |
| ម៉ាស៊ីនបោក | ១១,៧ | ០,៥ | ១,៣ | - | ៩,៥ |
| កង្ហាល់ | ៥៤,៨ | ២០,២ | ២២,៦ | - | ៧៩,៣ |
| ម៉ាស៊ីនត្រជាក់ | ៨,៨ | ០,៣ | ០,៩ | - | ៧,២ |
| រថយន្ត | ១០,៧ | ២,១ | ២,៧ | ១,៩ | ១០,១ |
| ទូក | ០,៧ | ២,៤ | ២,៣ | ៣,៨ | ៣,២ |
| ត្រាក់ទ័រ | ០,៣ | ០,៤ | ០,៤ | ០,៤ | ១,០ |
| គោយន្ត | ៦,១ | ២១,២ | ២០,១ | ៤,០ | ១៤,១ |

គ្រួសារជនជាតិដើមភាគតិចនៅឆ្នាំ២០១៩មានស្ថានភាពរីកចម្រើនល្អប្រសើរជាងនៅឆ្នាំ២០០៨ តាមរយៈការកើនឡើងនៃភាគរយគ្រួសារមានទូរទស្សន៍ ទូរស័ព្ទដៃ ម៉ូតូ រថយន្ត និងគោយន្ត និងការថយចុះនៃភាគរយគ្រួសារប្រើប្រាស់វិទ្យុនិងកង់។

## ៤.២. ការចុះបញ្ជីសហគមន៍និងកម្មសិទ្ធិដីសមូហភាព

ដូចបានរៀបរាប់ក្នុងជំពូកទី១ខាងដើម រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តយកចិត្តទុកដាក់ទៅលើការប្រឹងប្រែងលើកកម្ពស់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ដែលជាក្រុមមួយងាយរងហានិភ័យ និងការការពារផលប្រយោជន៍សមូហភាពជនជាតិដើមភាគតិច។ ការផ្តល់ការទទួលស្គាល់អត្តសញ្ញាណជាជនជាតិដើមភាគតិច និងនីតិបុគ្គលនៃសហគមន៍ជនជាតិដើមតិច រួមទាំងការចុះបញ្ជីដីសមូហភាព គឺជាឧទាហរណ៍មួយនៃកិច្ចប្រឹងប្រែងនេះ។

ទិន្នន័យអំពីដីធ្លីនិងកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច បានពីកំណត់ត្រារដ្ឋបាលស្តីពីការទទួលស្គាល់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ ការចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ និងការចុះបញ្ជីទទួលស្គាល់ដីធ្លីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

